

# ព្រឹត្តិបត្រប្រចាំខែ
Monthly Newsletter

# ការអប់រំ និង បច្ចេកវិទ្យា
# Education & Technology







ឆ្នាំទី៣ លេខ០០៨ ចេញផ្សាយប្រចាំខែឧសភា-ឧ្ស


ការិយាល័យ: សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពងចាម។
ប្រអប់សំបុត្រ: P.O Box ១៦២១ ភ្នំពេញ កម្ពុជា 042 941 481/042 941 918។
kape@kapekh.org www.kapekh.org www.facebook.com/kapeaction www.twitter.com/KAPECambodia
www.youtube.com/TheKapeCambodia www.linkedin.com/in/kapecambodia/

# មាតិកា

ទំព័រ


១ អំពីអង្គការ ខេប, ចំនួនគម្រោងកំពុងប្រតិបត្តិ, អ្នកទទួលផល
២ ម្ចាស់ជំនួយក្នុងឆ្នាំ២០២២

**១. ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ ( NGS )**

៤ កម្មវិធីទិវាជួបឪពុកម្តាយ
៦ ពិធីសម្ពោធដាក់ឱ្យដំណើរការឯកសារស្តីពី ការសិក្សាបែបគម្រោង
៨ កម្មវិធីពិព័រណ៍ស្នាដៃសិស្សនៅសាលារៀនជំនាន់ថ្មីក្នុងក្រុងកំពង់ចាម
៨ សន្និសីទអន្តរជាតិស្តីពីសាលារៀនស្វយ័តជាគន្លឹះដើម្បីកំណែទម្រង់ការអប់រំ

**២. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការអប់រំ**

១១ ហេតុអ្វីកម្មវិធីប្រព័ន្ធរំឭកទុកជាមុនមានតួនាទីសំខាន់ក្នុងសាលារៀន?
១២ តើអ្វីទៅជាការសិក្សាមុខវិជ្ជាអប់រំបំណិនជីវិតមូលដ្ឋានដោយប្រើប្រាស់ទម្រង់មជ្ឈមណ្ឌលសិក្សាតាមអេឡិចត្រូនិក?
១៣ សេវាប្រឹក្សាជាអាជីពជាអ្វីនៅក្នុងវិស័យអប់រំ?
១៤ ការកែសម្រួលខ្លឹមសារឯកសារគោលរបស់កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ
១៤ តើកម្មវិធីត្រីវិស័យជាអ្វី?
១៥ គោលនយោបាយទប់ស្កាត់ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទ (PSEA)
១៥ បរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ

**៣. ការអភិវឌ្ឍគ្រូបង្រៀន**

១៨ គ្រូបង្រៀនកិច្ចសន្យានៅតំបន់គោលដៅទទួលបានការគាំទ្រពីគម្រោង
១៩ តើការអប់រំបរិយាបន្នជាអ្វី?
១៩ ហេតុអ្វីបានជាសិស្សានុសិស្សត្រូវស្វែងយល់ពីកម្មវិធីត្រីវិស័យ?
២០ សេវាប្រឹក្សាជាអាជីពជាអ្វីនៅក្នុងវិស័យអប់រំ?
២១ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងតាមសាលារៀន(វគ្គទី៣)
២២ ការពង្រឹងសមត្ថភាពគ្រូបង្រៀនកិច្ចសន្យានៅសាលារៀនរដ្ឋ
២២ វគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធរំឭកជាមុន (EWS)
២៣ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
២៣ ការសិក្សាមុខវិជ្ជាអប់រំបំណិនជីវិតតាមមូលដ្ឋាន
២៤ ការកសាងសមត្ថភាពស្តីពី អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងឌីជីថល
២៥ វឌ្ឍនភាពសាលារៀនជាមួយអ្នកពាក់ព័ន្ធសំខាន់ៗក្នុងគម្រោង
២៦ ការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន (EWS )

**៤. កម្មវិធីអប់រំបរិយាប័ន្ន**

២៨ ការគាំទ្រដល់កុមារងាយរងគ្រោះបានលើកទឹកចិត្តសិស្សក្នុងការសិក្សា
៣០ ការផ្ទេរភារកិច្ចទទួលខុសត្រូវនៃការប្រតិបត្តិគម្រោងទៅដៃគូពាក់ព័ន្ធ
៣៣ វគ្គបំប៉នដល់គ្រូមត្តេយ្យសិក្សារដ្ឋស្តីពីសៀវភៅសិក្សាគោល

**៥. កម្មវិធីអំណានថ្នាក់ដំបូង**

៣៦ ហេតុអ្វីបានជាមានសិស្សរៀនយឺតនៅក្នុងសាលារៀន?

**៦. កម្មវិធីមត្តេយ្យសិក្សា**

៣៨ វគ្គបំប៉នដល់គ្រូមត្តេយ្យសិក្សារដ្ឋស្តីពីសៀវភៅសិក្សាគោល

**៧. រចនាបថហេដ្ឋារចនាសម្ព័ន្ធ**

៤០ ការធ្វើទំនើបកម្មបណ្ណាល័យក្នុងតំបន់ដាច់ស្រយាល

**៨. ការអភិវឌ្ឍបណ្ណាល័យ**

៤២ ហេតុអ្វីបានបណ្ណាល័យមានតួនាទីសំខាន់ក្នុងសាលារៀន?

## ៩. កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព

៤៤ ហេតុអ្វីសិស្សត្រូវយល់ដឹងអំពីការប្រើប្រាស់ធុងចម្រោះទឹកស្អាត?
៤៥ វគ្គបណ្តុះបណ្តាលគ្រូបង្គោលកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E.

## ១០. កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩

## ១១. ព្រឹត្តិការណ៍ ការស្រាវជ្រាវចំណេះដឹង និងការកំសាន្តផ្សេងៗ

៤៨ អបអរសាទរទិវាកុមារអន្តរជាតិ
៤៩ ដំណើរទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយក្នុងសាលារៀននៅខេត្តក្រចេះ
៥១ កម្មវិធីផ្លាស់ប្តូរការសិក្សាពីសាលារៀនមួយទៅសាលារៀនក្នុងគម្រោង
៥២ កម្មវិធីផ្លាស់ប្តូរការសិក្សាពីសាលារៀនមួយទៅសាលារៀនក្នុងគម្រោង
៥៣ ការបង្ហាញលទ្ធផលរបស់គម្រោងទៅដល់ភាគគីពាក់ព័ន្ធ
៥៥ ដំណើរទស្សនកិច្ចសិក្សាទីប្រឹក្សាអង្គការអប់រំកុមារ (EAC)តំបន់គោលដៅ
៥៥ ដំណើរទស្សកិច្ចសិក្សារបស់ម្ចាស់ជំនួយ មកពីប្រទេសអ៊ីតាលី
៥៦ កម្មវិធីជួបសំណេះសំណាលរវាងនិស្សិតអាហារូបករណ៍ជាមួយគណៈប្រតិភូ
៥៧ ការកៀរគរសិស្សក្រៅសាលាឱ្យពួកគេបានត្រឡប់មកចូលរៀនវិញ
៥៨ កិច្ចប្រជុំឆ្លុះបញ្ចាំងអំពីសកម្មភាពរបស់គម្រោងក្នុងសាលារៀនគោលដៅ
៥៨ កម្មវិធីផ្លាស់ប្តូរការសិក្សាជូនដល់លោកគ្រូអ្នកគ្រូសាលារៀនគោលដៅ
៥៩ កិច្ចប្រជុំឆ្លុះបញ្ចាំងអំពីសកម្មភាពរបស់គម្រោងក្នុងសាលារៀនគោលដៅ
៦១ ដំណើរទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយអង្គការឆាលហ្វានកូរ៉េ
៦១ កម្មវិធីសម្ពោធអគារសិក្សាថ្មី និងសមិទ្ធផលនានានៅក្នុងសាលារៀន
៦៣ ការជួបសម្តែងការគួរសមជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាល
៦៤ ការជួបសម្តែងការគួរសមនិងពិភាក្សាការងារអប់រំជាមួយឯកឧត្តម ពុធ សាមិត្ត
៦៤ គម្រោងFOSTER ទទួលបានប័ណ្ណសរសើរក្នុងកម្មវិធីរំលឹកខួបលើកទី២០
៦៥ វេទិកាភាពជាដៃគូដើម្បីចីរភាពកម្ពុជា បច្ចុប្បន្ន និងថ្ងៃអនាគត



## ព្រឹត្តិបត្រ "ការអប់រំ និងបច្ចេកវិទ្យា"
## រៀបចំផលិត និងចេញផ្សាយដោយ

| | | |
|---|---|---|
| **លោក អឿ សាវីន** | មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ | រៀបចំផែនការ បង្កើតទម្រង់ និងរចនា |
| **លោក ឈួន តារា** | មន្ត្រីបច្ចេកវិទ្យាព័ត៌មានជាន់ខ្ពស់ | ជំនួយការបច្ចេកទេស |
| **លោក វ៉ាន់ សុខសារៈ** | មន្ត្រីតាមដាន & វាយតម្លៃ និងគ្រប់គ្រងទិន្នន័យជាន់ខ្ពស់ | ជំនួយការផ្នែកទិន្នន័យ |
| **លោក ម៉ៃ សុខឃា** | មន្ត្រីព័ត៌មានវិទ្យា | ជំនួយការបច្ចេកទេស |
| **កញ្ញា ជ្រន ភាត់ថា** | ជំនួយការផ្នែកទំនាក់ទំនង | ប្រមូល និងសរសេរព័ត៌មាន |

## ត្រួតពិនិត្យ និងកែសម្រួលខ្លឹមសារដោយ

**លោក ស សុផាណាក់**
ប្រធានសម្របសម្រួលផ្នែកបច្ចេកវិទ្យាសម្រាប់ការអប់រំ

# អំពីអង្គការ ខេប

ខេប គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ នៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ និងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ១៥០០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ដែលបង្រៀននៅជាង ៤០០សាលាក្នុង១៣រាជធានី-ខេត្ត។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់អង្គការ ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនងាយរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី ឬច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

**ការអភិវឌ្ឍមនុស្ស ប្រកបដោយសេចក្តីថ្លៃថ្នូរ!**

## លំដាប់គម្រោងតាមផ្នែកបច្ចេកទេសរបស់អង្គការ ខេប ក្នុងឆ្នាំ២០២៣

| គម្រោងរបស់អង្គការ ខេប ក្នុងឆ្នាំ២០២៣ | ពាក្យបំព្រួញ | ការអភិវឌ្ឍសាលារៀនគំរូថ្មី | ICT សម្រាប់ការអប់រំ | ការអភិវឌ្ឍគ្រូបង្រៀន | កម្មវិធីអប់រំបរិយាបន្ន | កម្មវិធីអំណានថ្នាក់ដំបូង | កម្មវិធីមត្តេយ្យសិក្សា | ហេដ្ឋារចនាសម្ព័ន្ធ | ការអភិវឌ្ឍស្ថាប័ន | កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព |
|---|---|---|---|---|---|---|---|---|---|---|
| ១. កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន | ADLP | | ✓ | | | | | | | |
| ២. គម្រោង សៀវភៅសម្រាប់កម្ពុជា | BfC | | | | | | | | ✓ | |
| ៣. គម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម | COSAVED | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ៤. គម្រោង ងាយស្រួលរៀន – ខេត្តព្រៃវែង | E2L-PV | | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៥. គម្រោង ងាយស្រួលរៀន – ខេត្តក្រចេះ | E2L-Kr | | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៦. គម្រោង ពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា | EQUAL | | | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៧. កម្មវិធីអក្ខរកម្មហិរញ្ញវត្ថុ | FLP | | | ✓ | | | | | | ✓ |
| ៨. គម្រោង សហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិចតំបន់១ | FOSTER | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ៩. គម្រោង កុមារកម្ពុជារីករាយ | HCC | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ១០. កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ | KDLP | | ✓ | ✓ | | | | | | ✓ |
| ១១. កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន | LLSP | | | ✓ | | | | | | ✓ |
| ១២. គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី | LSLAG | | | | ✓ | | | | | ✓ |
| ១៣. គម្រោងអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន | MDL | | ✓ | ✓ | | | | | | ✓ |
| ១៤. កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈភាពជាអ្នកដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា | MLPDP | | ✓ | | ✓ | | | | | |
| ១៥. មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | NGPRC | ✓ | ✓ | ✓ | | | | | | |
| ១៦. កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតបឋមសិក្សា) | NGS-P | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| ១៧. កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតមធ្យមសិក្សា) | NGS-S | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ |
| ១៨. បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | REACHIV | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ២៩.គម្រោង វាយតម្លៃការសិក្សាថ្នាក់ដំបូង | EGLA | | | | | ✓ | | | | |
| ២០. គម្រោង អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ២ | USE-SDP2 | | ✓ | ✓ | | | | ✓ | ✓ | ✓ |
| សរុបគម្រោងកំពុងដំណើរការក្នុងផ្នែកនីមួយៗ | | 3 | 10 | 15 | 11 | 9 | 4 | 4 | 11 | 15 |

# ចំនួនអ្នកទទួលផលផ្ទាល់







**១២០៨៣១** សិស្សានុសិស្ស

**២៨០៦** គ្រូបង្រៀន/នាយក

**១៤៩៦** ភាគីពាក់ព័ន្ធ

# ចំនួនសាលាគោលដៅ



**១១០** មធ្យមសិក្សា

**១៧២** បឋមសិក្សា

**៤២** មត្តេយ្យសិក្សា

**១** ឧត្តមសិក្សា

# ម្ចាស់ជំនួយអង្គការ ខេប ក្នុងឆ្នាំ២០២១

unicef for every child

GPE Transforming Education

GVC | WeWorld

This project is co-funded by the European Union

EDUCATE A CHILD — A programme of education above all

Aide et Action — Changing the world through Education

THE PHOENIX FOUNDATION

ChildFund Cambodia

ADB

The Asia Foundation — Improving Lives, Expanding Opportunities

OXFAM

lotus outreach INTERNATIONAL

lotus outreach SOCIETY CANADA

USAID FROM THE AMERICAN PEOPLE

pact building local promise.

Oaktree

UNESCO

FFF | Franks Family Foundation

Gap Inc.

P.A.C.E. Gap Inc. Advancing Women to Advance the World

# តំបន់គោលដៅអនុវត្តគម្រោងក្នុងឆ្នាំ២០២១ របស់អង្គការ ខេប មានចំនួន ១៣ រាជធានី-ខេត្ត



អនុវិស័យទី ១

# ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ

"បង្កើតសាលារៀនរដ្ឋជាមួយនឹងស្តង់ដាសាលារៀនឯកជន"

# Charter School Development

*Creating Public Schools with Private School Standards*













# កម្មវិធីទិវាជួបឪពុកម្ដាយ

កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២៣ កម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀបបានរៀបចំ **កម្មវិធីទិវាជួបឪពុកម្ដាយ** ដើម្បីដាក់តាំងពិព័រណ៍ស្នាដៃសិស្សប្រចាំឆ្នាំ២០២៣ ក្រោយអធិបតីភាព **ឯកឧត្តម វង ភិរុណ** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាទីប្រឹក្សាកម្មវិធីសាលារៀនជំនាន់ថ្មី ព្រមទាំងមានការអញ្ជើញចូលរួមពីក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មីថ្នាក់ជាតិ អង្គការ ខេប ដៃគូសហការ មាតាបិតាសិស្ស និងលោកគ្រូ អ្នកគ្រូ ព្រមទាំងអ្នកពាក់ព័ន្ធផ្សេងៗទៀត។



ឯកឧត្តម វង ភិរុណ អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អញ្ជើញចូលរួមជាអធិបតីភាពក្នុងកម្មវិធីទិវាជួបឪពុកម្ដាយ នៅវិទ្យាល័យព្រែបលៀប។

កម្មវិធីនេះ មានគោលបំណងដាក់តាំងបង្ហាញអំពីសមិទ្ធផលនៃការងារគម្រោងការងារក្លឹប និងការស្រាវជ្រាវរបស់សិស្សសម្រាប់មួយឆមាសសិក្សាដើម្បីបង្ហាញជូនដល់មាតាបិតា អាណាព្យាបាលសិស្ស បានទស្សនា និងបានបង្កើតទំនាក់ទំនងរវាងសាលារៀនជាមួយសហគមន៍កាន់តែល្អប្រសើរឡើង។

ឯកឧត្តម **វង ភិរុណ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាទីប្រឹក្សាសាលារៀនជំនាន់ថ្មី បានមានប្រសាសន៍ថា "**កម្មវិធីសាលារៀនជំនាន់ថ្មីមានលក្ខណៈទំនើបខុសពីសាលារៀនធម្មតា ដោយសារតែលោកគ្រូអ្នកគ្រូមានវិធីសាស្រ្តបង្រៀនចម្រុះដែលធ្វើឱ្យសិស្សានុសិស្សចូលរួមយ៉ាងសកម្មនៅក្នុងថ្នាក់ តាមរយៈការផ្តល់កិច្ចការឱ្យសិស្សធ្វើការក្រុម ការងារគម្រោង និងដឹកនាំក្លឹបសិក្សា ហើយលោកគ្រូអ្នកគ្រូមានតួនាទីជាអ្នកណែនាំ និងតម្រង់ទិសជួយឱ្យពួកគាត់សម្រេចបាននូវការងារទាំងនោះ ដូច្នេះហើយ ធ្វើឱ្យកម្មវិធីសាលារៀនជំនាន់ថ្មីមានលក្ខណៈខុសប្លែកពីគេ**"។

លោក ធុំ សុភក្តិ នាយកវិទ្យាល័យព្រែកលៀបបានមានប្រសាសន៍ថា **"សម្រាប់កម្មវិធីពិព័រណ៍ស្នាដៃសិស្សក្នុងឆ្នាំនេះ សាលារៀនមានគម្រោងសរុបចំនួន៣១១ គម្រោង និងមានក្លឹបសិក្សាចំនួន១៦ ដែលបានដាក់តាំង**

**សូមអានបន្តទំព័រ៥**



ក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មីថ្នាក់ជាតិ អង្គការ ខេប ដៃគូសហការ មាតាបិតាសិស្ស និងលោកគ្រូអ្នកគ្រូបានទស្សនាការតាំងពិព័រណ៍ស្នាដៃសិស្ស។

*តពីទំព័រ៤* បង្ហាញស្នាដៃជូនដល់អាណាព្យាបាលសិស្ស និងសាធារណៈជនឱ្យបានយល់ដឹងកាន់តែច្បាស់អំពីសាលារៀនជំនាន់ថ្មី និងសមត្ថភាពសិស្សដែលពួកគាត់អាចផលិតសម្ភារៈទាំងអស់នេះបាន។ កម្មវិធីសាលារៀនជំនាន់ថ្មីដំណើរការទៅបានដោយសារមានការគាំទ្របច្ចេកទេសពីខាងអង្គការ ខេប ដែលបានធ្វើការយ៉ាងជិតស្និតជាមួយក្រសួងអប់រំ យុវជន និងកីឡាដើម្បីកែលម្អគុណភាពអប់រំឱ្យកាន់តែល្អប្រសើរតាមរយៈកម្មវិធីសាលារៀនជំនាន់ថ្មី"។



អង្គការ ខេប អាណាព្យាបាល ឪពុកម្តាយសិស្ស អាជ្ញាធរមូលដ្ឋាន ព្រះសង្ឃបានចូលរួមយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍសាលារៀន។

លោក **ហ៊ិន ស៊ីមហួន** អនុប្រធានអង្គការខេប និងជាប្រធានសម្របសម្រួលកម្មវិធីសាលារៀនជំនានថ្មី បានមានប្រសាសន៍ **"កម្មវិធីសាលារៀនជំនាន់ថ្មី ជាកម្មវិធីកំណែទម្រង់មួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតសាលារៀនសាធារណស្វយ័តមួយដែលមានសិទ្ធិច្នៃប្រឌិត និងកែលម្អគុណភាពអប់រំ។ ក្នុងកម្មវិធីនេះ យើងតែងតែនាំយកកម្មវិធីសិក្សាល្អៗ និងមានទស្សនកិច្ចសិក្សាទៅក្រៅប្រទេសជូនដល់លោកគ្រូអ្នកគ្រូ ដើម្បីផ្តល់ឱកាសឱ្យពួកគាត់បានរៀនសូត្រនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗ ក្នុងន័យជំរុញឱ្យមានការគិតបែបស៊ីជម្រៅ ចេះច្នៃប្រឌិតសកម្មភាពក្នុងថ្នាក់អំពីការបង្រៀន និងរៀនជាមួយវិធីសាស្ត្រល្អៗ ដើម្បីយកមកអនុវត្តន៍នៅក្នុងថ្នាក់រៀន ដូច្នេះហើយធ្វើឱ្យកម្មវិធីសាលារៀនជំនាន់ថ្មីមានភាពលេចធ្លោនៅថ្នាក់ជាតិ "។**

កម្មវិធីសាលារៀនជំនាន់ថ្មីដាក់ដំណើរការក្នុងវិទ្យាល័យព្រែកលៀបក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ដោយចាប់ផ្តើមអនុវត្តន៍ត្រឹមតែថ្នាក់ទី៧ និងទី៨ និងបានពង្រីកដល់ថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា២០២១-២០២២ បន្តដល់បច្ចុប្បន្ននេះ៕




*ការសិក្សាបែបគម្រោងធ្វើឱ្យសិស្សនៅសាលារៀនជំនាន់ថ្មីចេះសម្រួលខ្លួនធ្វើការងារក្រុម និងបានផ្តល់ឱកាសដល់សិស្សសំយោគចំណេះដឹងពីផ្នែកផ្សេងៗនៃការសិក្សា រួចអនុវត្តនៅក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃប្រកបដោយការវិភាគ និងច្នៃប្រឌិត ជាពិសេសពួកគេបានបង្កើតស្នាដៃសម្រាប់តាំងបង្ហាញជូនដល់សាធារជនបានទស្សនា។*

# ពិធីសម្ពោធដាក់ឱ្យដំណើរការឯកសារស្ដីពី ការសិក្សាបែបគម្រោង



*ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាបានចូលរួមជាអធិបតីភាពក្នុងកម្មវិធីសម្ពោធដាក់ឱ្យដំណើរការឯកសារស្ដីពីការសិក្សាបែបគម្រោង នៅសាលារៀនជំនាន់ថ្មី។*

ក្រសួងអប់រំ យុវជន និងកីឡាបាន រៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការឯកសារ ស្ដីពី ការសិក្សាបែបគម្រោង ដោយមានការ សម្របសម្រួលពីអង្គការសកម្មភាពសម្រាប់ ការអប់រំនៅកម្ពុជា (ខេប) ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅ សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប និងអមដំណើរដោយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ដែលមកពី២៥រាជធានី-ខេត្ត ថ្នាក់ ដឹកនាំជាន់ខ្ពស់របស់អង្គការ ខេប លោកគ្រូ អ្នកគ្រូ និងមន្ត្រីពាក់ព័ន្ធផ្សេងៗ។ ពិធីសម្ពោធ នេះបានរៀបចំឡើងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០២៣ ក្នុងគោលបំណងផ្សព្វផ្សាយអំពីឯក សារការសិក្សាបែបគម្រោងដល់ប្រធានមន្ទីរ អប់រំ យុវជន និងកីឡាគ្រប់រាជធានី-ខេត្ត បានយល់ដឹងពីអត្ថប្រយោជន៍ និងរៀបចំ ផែនការបណ្ដុះបណ្ដាលការសិក្សាបែប គម្រោងដល់មន្ត្រីអប់រំដទៃទៀត ដើម្បីឱ្យការ ប្រើប្រាស់ឯកសារនេះកាន់តែទូលំទូលាយ ជា ពិសេសលោកគ្រូអ្នកគ្រូនឹងទទួលបាននូវ សមត្ថភាពបន្ថែមក្នុងការលើកកម្ពស់វិធីសា ស្ត្របង្រៀនបែបថ្មី។ សិស្សនៅសាលារៀន គោលដៅនៃកម្មវិធីសាលារៀនជំនាន់ថ្មី ដែល បានអនុវត្តការសិក្សាបែបគម្រោងនាពេល កន្លងមក បានផលិតចេញជាស្នាដៃ ហើយ បានយកមកដាក់តាំងបង្ហាញនៅក្នុងពិធីនេះ ដែលបង្ហាញនូវសមិទ្ធផលនៃការខិតខំសិក្សា របស់ពួកគេ។

យោងទៅលើលទ្ធផលដែលទទួលបាន ក្រោយអនុវត្តសាកល្បងការសិក្សាបែប គម្រោងរបស់កម្មវិធីសាលារៀនជំនាន់ថ្មី ជា ពិសេសប្រសិទ្ធភាពរបស់គ្រូបង្រៀន ឯក ឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន បាន ដាក់ចេញនូវវិធានការណ៍ចំនួន៨ចំណុចក្នុង ការបញ្ចូលឯកសារនេះទៅក្នុងកម្មវិធីបណ្ដុះប ណ្ដាលគ្រូបង្រៀន **សូមអានបន្តទំព័រ៧**



*ការតាំងបង្ហាញស្នាដៃសិស្សពីអំពូលតជាស៊េរី និងខ្មែងដែលជាស្នាដៃរបស់សាលារៀនជំនាន់ថ្មីវិទ្យាល័យគោកព្រីង។*




*ឯកឧត្តមបណ្ឌិតសភាចារ្យ អមដំណើរដោយលោក សៅ វណ្ណា ទស្សនាការតាំងបង្ហាញស្នាដៃសិស្សតាមស្តង់ពិព័រណ៍តាមសាលារៀនជំនាន់ថ្មីនីមួយៗ។*

**តពីទំព័រ៦** និងបង្រៀនសិស្ស ដូចខាងក្រោម៖ ១)ដាក់បញ្ចូលវិធីសាស្ត្របង្រៀន និងរៀនបែបថ្មី គឺការសិក្សាបែបគម្រោង ការសិក្សាបែបស្ថាបនានិយម ការសិក្សាបែបចម្រុះទៅក្នុងវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ។ ២)ដាក់ឱ្យអនុវត្តវិធីសាស្ត្របង្រៀនថ្មីដូចសាលារៀនជំនាន់ថ្មី នៅសាលារៀនគំរូ។ ៣)អនុវត្តវិធីសាស្ត្រថ្មីនៅតាមសាលារៀនមួយចំនួនក្រៅពីសាលារៀនជំនាន់ថ្មី ដូចជាសាលារៀនគំរូ និងសាលាធនធាន។ ៤)រៀបចំផលិតជាវីដេអូស្តីពីវិធីសាស្ត្របង្រៀនបែបថ្មី ទាំងកម្រិតបឋម និងមធ្យមសិក្សាដល់លោកគ្រូអ្នកគ្រូ។ ៥)ចុះវាយតម្លៃលើលទ្ធផល និងលើកទឹកចិត្តគ្រូក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីនេះ។ ៦)បន្តធ្វើការស្រាវជ្រាវគរុកោសល្យ ជាពិសេសនៅតាមសាលារៀនផ្សេងៗ ដែលវាជាការចូលរួមចំណែកជួយកែលម្អដល់ការអប់រំ។ ៧)បង្កើតទំនាក់ទំនងរវាងអង្គការ ខេប និងក្រសួង ព្រមទាំងវិទ្យាស្ថានបណ្តុះបណ្តាលគ្រូដែលធ្វើការជាប្រព័ន្ធមួយស្របគ្នា និង៨)រៀបចំជាប្រព័ន្ធគ្រប់គ្រងមួយសម្រាប់គាំទ្រដល់ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី។

ឯកឧត្តមបណ្ឌិតសភាចារ្យបានស្នើសុំឱ្យប្រធានមន្ទីរអប់រំ យុវជន និងកីឡាទាំងអស់ សាកល្បងយកវិធីសាស្ត្រថ្មី អនុវត្តនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ព្រោះវាជាការឆ្លើយតបទៅនឹងគោលដៅចិត្តសាស្ត្រអប់រំ ដើម្បីបណ្តុះសិស្សានុសិស្សឱ្យចេះរៀនដោយខ្លួនឯងក្នុងសម័យបច្ចេកវិទ្យាឬឌីជីថលនេះ។

ការសិក្សាបែបគម្រោង គឺជួយដល់គ្រូបឋមសិក្សា និងគ្រូមធ្យមសិក្សាទាំងអស់លើកកម្ពស់វិធីសាស្ត្របង្រៀន ដោយជ្រើសរើសការបង្រៀនតាមរយៈការងារគម្រោងដែលផ្តល់ឱកាសដល់សិស្ស ក្នុងការសំយោគចំណេះដឹងពីផ្នែកផ្សេងៗនៃការសិក្សា រួចអនុវត្តនៅក្នុងសកម្មភាពប្រចាំថ្ងៃប្រកបដោយការវិភាគ និងច្នៃប្រឌិត៕




*បន្លែលើទឹក ឬហៅថាហៃដ្រូប៉ូនិក ជាស្នាដៃរបស់សិស្សានុសិស្សនៅសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រែកលៀប។*

# កម្មវិធីពិព័រណ៍ស្នាដៃសិស្សនៅសាលារៀនជំនាន់ថ្មីក្នុងក្រុងកំពង់ចាម



សិស្សសាលារៀនជំនាន់ថ្មីតម្រូវឱ្យពួកគេអនុវត្តទ្រឹស្តីចេញពីមេរៀនដើម្បីឆ្លើយតបនឹងតម្រូវការជីវភាពរស់នៅជាក់ស្តែង។

នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣ សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានរៀបចំកម្មវិធីពិព័រណ៌ស្នាដៃសិស្សក្នុងគោលបំណងផ្តល់ឱកាសឱ្យឪពុកម្តាយ អាណាព្យាបាល និងភាគីពាក់ព័ន្ធនានា បានមកទស្សនាផ្ទាល់នូវអ្វីដែលកូនៗរបស់គាត់ និងសិស្សានុសិស្សដទៃទៀត បានសិក្សា និងចេះបង្កើតស្នាដៃនៅក្នុងរយៈពេលពេញមួយឆ្នាំនេះ។

នៅក្នុងកម្មវិធីនេះមានការសម្តែងជាច្រើន ការបង្ហាញសមត្ថភាពតាមរយៈក្លឹបសិក្សានីមួយៗ ដែលបានបង្កើតឡើងចំនួន១២ក្លឹប រួមមាន៖ ប្រវត្តវិទ្យា វិទ្យាសាស្ត្រ និពន្ធ ភាសាអង់គ្លេស អេឡិចត្រូនិក បច្ចេកវិទ្យាព័ត៌មានជាដើម។ល។ ដោយផ្តោតទៅលើគម្រោងចំនួន១១៥ និងមានវត្តមានអ្នកចូលរួមជាសិស្សនៅវិទ្យាល័យនេះចំនួន៦៣៦នាក់ ឪពកុម្តាយ និងអ្នកពាក់ព័ន្ធជាច្រើនអ្នកទៀត។ គោលបំណងមួយទៀតដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងឪពុកម្តាយ និងសាលារៀន បង្កើនការគាំទ្រពីឪពុកម្តាយសិស្សក្នុងការអភិវឌ្ឍសាលារៀន។

កម្មវិធីនេះត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ដោយមានការគាំទ្រពីឪពុកម្តាយ និងអ្នកពាក់ព័ន្ធនានា។ ចាប់តាំងពីពេលដំណើរការកម្មវិធីនេះមក ការបង្ហាញស្នាដៃសិស្សនេះមានលក្ខណៈធំធេងណាស់ ដោយរាប់បញ្ចូលទាំងការប្រគល់រង្វាន់ និងលិខិតសរសើរដល់សិស្សដែលទទួលបានជ័យលាភីក្នុងការសិក្សាល្អ ការប្រកួតថ្នាក់ជាតិ និងអន្តរជាតិ ហើយបានធ្វើឱ្យឪពុកម្តាយ អាណាព្យាបាល និងអ្នកពាក់ព័ន្ធមានការសប្បាយចិត្តយ៉ាងខ្លាំងចំពោះអ្វីដែលកូនៗរបស់ពួកគាត់អាចធ្វើបាន និងដាក់តាំងបង្ហាញនៅថ្ងៃនេះ។

# សន្និសីទអន្តរជាតិស្តីពីសាលារៀនស្វយ័តជាគន្លឹះដើម្បីកំណែទម្រង់ការអប់រំ



ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអមដំណើរដោយថ្នាក់ដឹកនាំសំខាន់ៗក្នុងក្រសួងអប់រំ អង្គការ ខេប អង្គការ ឆាលហ្វានកម្ពុជា និងអង្គការដៃគូ ចូលរួមក្នុងសន្និសីទអន្តរជាតិស្តីពីសាលារៀនស្វយ័តជាគន្លឹះដើម្បីកំណែទម្រង់ការអប់រំ ។

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា បានរៀបចំសន្និសីទអន្តរជាតិមួយស្តីពី "សាលារៀនស្វយ័តជាគន្លឹះដើម្បីកំណែទម្រង់ការអប់រំ" ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអមដំណើរដោយថ្នាក់ដឹកនាំសំខាន់ៗក្នុងក្រសួងអប់រំ អង្គការ ខេប អង្គការ ឆាលហ្វានកម្ពុជា និងអង្គការដៃគូជាច្រើន នៅរាជធានីភ្នំពេញ។ សន្និសីទនេះ រៀបចំឡើងក្នុងគោលបំណង៖ ១.បង្កើតក្រុមបណ្តាញទំនាក់ទំនងអន្តរជាតិពេញលេញមួយដែលអាចគាំទ្រកំណែទម្រង់អប់រំសាលារៀនស្វយ័តប្រកបដោយប្រសិទ្ធភាព។ ២.ចងក្រងគំនិតច្នៃប្រឌិតផ្សេងៗអំពីប្រធានបទចម្រុះ ទាក់ទងនឹងសាលារៀនស្វយ័តតាមរយៈការបោះពុម្ពផ្សាយប្រចាំឆ្នាំក្នុងមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី។

**សូមអានបន្តទំព័រ៩**

**សូមអានបន្តទំព័រ៨** ៣.បង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍សម្រាប់សាលារៀនស្វយ័តនៅកម្ពុជា ដើម្បីគាំទ្រដល់កំណែទម្រង់សាលារៀនស្វយ័ត។

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** បានមានប្រសាសន៍ថា **"កំណែទម្រង់សាលារៀនជំនាន់ថ្មី គឺផ្តោតសំខាន់លើការពន្លឿននៃការផ្លាស់ប្តូរវិធីសាស្ត្រក្នុងការអនុវត្តលើការបង្រៀន ការកែលម្អអភិបាលកិច្ច និងការកែលម្អលទ្ធផលសិក្សានៅចុងឆ្នាំសិក្សា ដែលយើងបានសង្កេតក្នុងរយៈពេលប្រាំបីឆ្នាំចុងក្រោយនេះ។ ការបង្កើតមូលដ្ឋានធនធានមនុស្សដ៏រឹងមាំនៅក្នុងប្រទេសកម្ពុជា វាមិនមែនជាអ្វីដែលអាចសម្រេចបានតាមរយៈគម្រោងរយៈពេលប្រាំឆ្នាំនោះទេ។ ផ្ទុយទៅវិញពេលវេលាដែលពាក់ព័ន្ធនឹងសាលារៀនជំនាន់ថ្មី ទំនងជាត្រូវបានវាស់វែងជាទសវត្សរ៍។ ទោះបីជាចំនួនសាលារៀនដែលគាំទ្រដោយផ្ទាល់នៅក្នុងប្រព័ន្ធ NGS នៅតែមានចំនួនតិចតួចក៏ដោយ កំណែទម្រង់ទាំងនេះ ឥឡូវនេះកំពុងឈានទៅដល់ការពង្រីកដ៏ធំមួយ។ លោកបន្តទៀតថា កម្មវិធីសាលារៀនជំនាន់ថ្មីដំណើរការទៅបាន ដោយសារក្រសួងមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយមូលនិធិឯកជនអន្តរជាតិមួយចំនួនផងដែរ ដូចជាមូលនិធិគ្រួសារក្រេតូលហ្វ្រែង និងអង្គការឆាលហ្វានកម្ពុជា ដែលបានរួមចំណែកជាយុទ្ធសាស្ត្រយ៉ាងខ្ពស់មួយចំនួន ចំពោះដំណើរការកំណែទម្រង់ទាំងនេះ។ សាលារៀនជំនាន់ថ្មីមិនត្រឹមតែផ្តល់សេវាកម្មដែលមានគុណភាពខ្ពស់ដល់សិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវបទពិសោធន៍ ឯកសារ និងការយល់ដឹងដែលជួយសម្រួលដល់ការកែទម្រង់ទៅកាន់តំបន់ដទៃ និងអនុវិស័យផ្សេងៗ"**។

លោក **សៅ វណ្ណា** នាយកប្រតិបត្តិអង្គការខេប បានមានប្រសាសន៍ថា **"សន្និសីទថ្ងៃនេះផ្តោតលើសាលារៀនស្វយ័តដែលត្រូវបានកំពុងលើកកម្ពស់កែលម្អការអប់រំមិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍។ ម្យ៉ាងទៀត ជាពិសេសសន្និសីទនេះ ព្រោះបើតាមដឹង គ្មានសន្និសីទណាដែលលើកយកប្រធានបទនេះពីមុនមកទេ ប្រាកដណាស់មិនមែននៅកម្ពុជាទេ។ សន្និសីទនេះក៏មានលក្ខណៈពិសេសទៅតាមវិធីផ្សេងៗ ខ្ញុំសង្ឃឹមថាសន្និសីទនេះអាចជាជំហានដំបូងឆ្ពោះទៅរកការកសាងបណ្តាញអចិន្ត្រៃយ៍ដែលភ្ជាប់ការងាររបស់ប្រទេសកម្ពុជាលើសាលារៀនស្វយ័តទៅនឹងការងារដែលកំពុងធ្វើនៅប្រទេសដទៃ"**។

លោក សៅ វណ្ណា បានបន្តទៀតថា កម្មវិធីសាលារៀនជំនាន់ថ្មីបានរៀនសូត្រច្រើនពីបទពិសោធន៍ និងមេរៀនរបស់ប្រទេសផ្សេងដែលមានកំណែទម្រង់ស្រដៀងគ្នានេះ ដូចជាប្រទេសថៃ សិង្ហបុរី និងប្រទេសលោកខាងលិចខ្លះ។ យើងក៏បានចែករំលែកបញ្ហាប្រឈម និងភាពជោគជ័យផ្ទាល់ខ្លួនរបស់យើងក្នុងការអភិវឌ្ឍប្រព័ន្ធសាលារៀនស្វយ័តមួយដែលសាកសមនឹងបរិបទ និងតម្រូវការផ្ទាល់ខ្លួនរបស់យើង។ យើងជឿថាប្រទេសនីមួយៗគួរតែស្វែងរកវិធីផ្ទាល់ខ្លួនដើម្បីបង្កើតសាលារៀនស្វយ័តដែលដំណើរការសម្រាប់ពួកគេ។ យើងមានមោទនភាពចំពោះផលជះ និងលទ្ធផលនៃសាលាស្វយ័តរបស់យើង។ ពួកយើងបានធ្វើឱ្យប្រសើរឡើងនូវសមិទ្ធផលសិស្ស គុណភាពគ្រូបង្រៀន ការគ្រប់គ្រងសាលារៀន និងការអភិវឌ្ឍធនធានមនុស្ស។ ពួកយើងក៏បានបង្កើតចំនួនដ៏សំខាន់នៃនិស្សិតបញ្ចប់ការសិក្សាដែលមានគុណភាពខ្ពស់ដែលអាចក្លាយជាគ្រូបង្រៀន និងអ្នកដឹកនាំនាពេលអនាគត។ ពួកគេក៏បានបំផុសគំនិតច្នៃប្រឌិត និងបទពិសោធន៍ក្នុងវិស័យផ្សេងៗ និងអនុវិស័យនៃការអប់រំផងដែរ។

កម្មវិធីសន្និសីទនេះ ប្រព្រឹត្តទៅនៅថ្ងៃទី២៨-២៩ ខែកញ្ញា ឆ្នាំ២០២៣ នៅសណ្ឋាគារសុខា ដែលមានសិក្ខាកាមប្រហែល ១០០នាក់រួមមាន៖ ក្រសួងអប់រំយុវជន និងកីឡា អង្គការដៃគូជាតិ និងអន្តរជាតិ និងលោកគ្រូអ្នកគ្រូ។

កម្មវិធីសាលារៀនជំនាន់ថ្មីសំដៅលើការកែទម្រង់វិស័យអប់រំ ដោយក្រសួង អប់រំយុវជន និងកីឡានៅឆ្នាំ២០១៥ ដើម្បីបង្កើតសាលារៀនសាធារណៈស្វយ័តមួយដែលមានសិទ្ធិច្នៃប្រឌិត និងកែលម្អគុណភាពអប់រំ ព្រមទាំងមានស្តង់ដារវិជ្ជាជីវខ្ពស់ និងអភិបាលកិច្ចល្អ៕




*កិច្ចជជែកពិភាក្សាស្តីពីសាលារៀនស្វយ័ត ជាគន្លឹះដើម្បីកំណែទម្រង់ការអប់រំដែលធ្វើឡើងនៅសណ្ឋាគារសុខា រាជធានីភ្នំពេញ។*

អនុវិស័យទី ២

# បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍សម្រាប់ការអប់រំ

“បច្ចេកវិទ្យានឹងមិនអាចជំនួសគ្រូដ៏ឆ្នើមៗបានទេ ប៉ុន្តែគ្រូឆ្នើមៗក៏មិនអាចអត់បច្ចេកវិទ្យាសម្រាប់បរិវត្តកម្មបានដែរ”

# Information and Communication Technology (ICT) in Education

*Technology will never replace great teachers, but in the hands of great teachers, it's transformational*



# ហេតុអ្វីកម្មវិធីប្រព័ន្ធរំឭកទុកជាមុនមានតួនាទីសំខាន់ក្នុងសាលារៀន?




*ការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន (EWS) ជួយគ្រូក្នុងការតាមដានសិស្សងាយរងគ្រោះក្នុងការបោះបង់ការសិក្សា និងរបាយការណ៍គ្រប់គ្រងសាលារៀនដូចជា អវត្តមានសិស្ស ឥរិយាបថ លទ្ធផលសិក្សាប្រចាំខែ តារាងកិត្តិយ និងសៀវភៅតាមដានការសិក្សាកាន់តែមានភាពងាយស្រួលក្នុងសាលារៀន។*

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(ខេប) បានរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពី ការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន (EWS App) ដែលធ្វើឡើងនៅសាលប្រជុំក្រុមហ៊ុនធីធីអូក្នុងក្រុងកំពង់ចាម ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ២៨ នាក់ ជាបុគ្គលិកអង្គការ ខេប ភាគច្រើនព្រមទាំងលោកគ្រូអ្នកគ្រូ។

វគ្គបណ្តុះបណ្តាលនេះ ប្រព្រឹត្តទៅនៅថ្ងៃទី ៩-១០ ខែឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណង ផ្តល់ឱ្យសិក្ខាកាម៖ ១-បានស្វែងយល់ពីប្រព័ន្ធរំឭកទុកជាមុន (EWS)។ ២-កសាងសមត្ថភាពគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ប្រព័ន្ធរំឭកទុកជាមុន និងមានលទ្ធភាពអាចបណ្តុះបណ្តាលជាមួយនឹងសាលារៀន។ ៣-កំណត់អត្តសញ្ញាណសិស្សងាយរងគ្រោះក្នុងការបោះបង់ការសិក្សា និងរបាយការណ៍គ្រប់គ្រងសាលារៀន៖ អវត្តមានសិស្ស ឥរិយាបថ លទ្ធផលសិក្សាប្រចាំខែ តារាងកិត្តិយស និងសៀវភៅតាមដានការសិក្សា និងរៀបចំផែនការបណ្តុះបណ្តាលកម្មវិធីប្រព័ន្ធរំឭកទុកជាមុនជាមួយសាលាគោលដៅរបស់គម្រោងនៃអង្គការ ខេប។

សិក្ខាកាមទទួលបានចំណេះដឹងល្អៗជាច្រើនក្នុងការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន ដើម្បីកំណត់អត្តសញ្ញាណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា និងចាត់វិធានការទប់ស្កាត់មិនឱ្យពួកគេបោះបង់ការសិក្សា ក៏ដូចជាធានាបាននូវសិទ្ធិរបស់កុមារក្នុងការទទួលបានយ៉ាងហោចណាស់ការអប់រំមូលដ្ឋាន៕



*មន្ត្រីគម្រោងរបស់អង្គការ ខេប បានខិតខំប្រឹងប្រែងធ្វើការងារជាមួយសាលារៀនយ៉ាងសកម្មដើម្បីជួយគាំទ្រផ្នែកបច្ចេកទេសធ្វើយ៉ាងណាឱ្យសាលារៀនអាចប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុនក្នុងការគ្រប់គ្រងទិន្នន័យសាលារៀន។*

# តើអ្វីទៅជាការសិក្សាមុខវិជ្ជាអប់រំបំណិនជីវិតមូលដ្ឋានដោយប្រើប្រាស់ទម្រង់មជ្ឈមណ្ឌលសិក្សាតាមអេឡិចត្រូនិក ?



*ការពង្រឹងសមត្ថភាពដល់គ្រូជាសកម្មភាពដ៏សំខាន់មួយរបស់គម្រោងដើម្បីធ្វើយ៉ាងណាឱ្យសិស្សានុសិស្សនៅក្នុងតំបន់គោលដៅទទួលបានសេវាអប់រំប្រកបដោយបរិយាបន្ន។*

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍ ប្រកបដោយចេរភាពនិងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម (CO-SAVED) សហការជាមួយក្រុមការងារបច្ចេកទេស AEA រៀបចំវគ្គតម្រង់ទិសមួយស្តីពី ការសិក្សាមុខវិជ្ជាអប់រំបំណិនជីវិតមូលដ្ឋានដោយប្រើទម្រង់មជ្ឈមណ្ឌលសិក្សាតាមរយៈ អេឡិចត្រូនិករបស់ក្រសួងអប់រំ តាមរយៈប្រព័ន្ធអនឡាញ។ សិក្ខាកាមចូលរួមសរុបចំនួន ៦២៥ នាក់ (ស្រី២១៥) រួមមាន៖ នាយកសាលាអនុវិទ្យាល័យ-បឋមសិក្សា គ្រូបង្រៀនថ្នាក់ទី៥-៦ និងប្រធានមន្ទីរ-ការិយាល័យ អប់រំ យុវជន និងកីឡាខេត្ត-ស្រុក។

វគ្គតម្រង់ទិសនេះរៀបចំឡើងក្នុងគោលបំណង ផ្តល់ឱ្យសិក្ខាកាមនូវចំណេះដឹង និងបានសិក្សាស្វែងយល់បន្ថែមពីរបៀបនៃការសិក្សាតាមទម្រង់មជ្ឈមណ្ឌលសិក្សាតាមរយៈអេឡិចត្រូនិករបស់ក្រសួង ជាពិសេសវគ្គសិក្សាបំណិនជិវិតតាមមូលដ្ឋាន។

លោក **នួន វណ្ណសឿន** អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ បានមានប្រសាសន៍ថា **"កម្មវិធីបំណិនជីវិតពិតជាមានសារៈសំខាន់ណាស់ ជួយសិស្សានុសិស្សមានបំណិនពេញបរិបូរណ៍នៃការរស់នៅប្រចាំថ្ងៃ។ ការបង្រៀនកម្មវិធីបំណិនជីវិតក្នុងសាលារៀនជាផ្នែកមួយជួយឱ្យសិស្សបានស្វែងយល់បន្ថែមពីមូលដ្ឋានបំណិនជីវិត ដែលអាចយកចំណេះដឹងទាំងអស់នោះមកប្រើប្រាស់ជាក់ស្តែង។ម្យ៉ាងវិញទៀត បំណិនជីវិត ជាវិជ្ជាមួយកំពុងតែអនុវត្តក្នុងប្រទេសជិតខាង ហើយក្រសួងអប់រំក៏បានដាក់កម្មវិធីនេះទូទាំងប្រទេសកម្ពុជាផងដែរ ដោយធ្វើការសហការជាមួយអង្គការដៃគូ និងភាគគីពាក់ព័ន្ធនានា"។**

មជ្ឈមណ្ឌលសិក្សាតាមអេឡិចត្រូនិក ជាគេហទំព័រមួយផ្តល់ជូនលោកគ្រូអ្នកគ្រូនូវធនធានឌីជីថលដ៏សម្បូរបែបដែលអាចជួយសម្រួលការបង្រៀន។ សម្ភារសិក្សាជាច្រើនដូចជា ពហុមេឌៀអន្តរកម្ម ផ្ទាំងរូបភាពកិច្ចតែងការវីដេអូអប់រំខ្លីៗ និងឯកសារយោងនានាដែលពាក់ព័ន្ធដែលបានមកពីក្រសួងអប់រំក៏ដូចជាតំណភ្ជាប់ទៅកាន់គេហទំព័រដ៏ទៃផ្សេងទៀត។

សិក្ខាកាមទទួលបានចំណេះដឹងនិងបទពិសោធន៍ថ្មីៗសម្រាប់ការចែករំលែកដល់សិស្សានុសិស្ស និងសហគមន៍។ បំណិននេះនឹងផ្តល់ភាពងាយស្រួល សម្រាប់លោកគ្រូអ្នកគ្រូ សិស្សានុសិស្សក្នុងការបង្រៀន និងរៀន ហើយវា ជាបំណិនថ្មីមួយដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ជាជំនួយក្នុងការស្វ័យសិក្សា។

ជាលទ្ធផល សិក្ខាកាមបានយល់ដឹងកាន់តែច្បាស់ពីកម្មវិធីបំណិនជីវិត និងរៀបចំផែនការចុះឈ្មោះរៀនក្នុងប្រព័ន្ធ E-learning life-skill platform៕

គម្រោងទទួលហិរញ្ញប្បទានពីសហភាពអឺរ៉ុប/អង្គការ Aide et Action(AeA)៕

# បណ្តុះបណ្តាលពីការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន



*លោកគ្រូអ្នកគ្រូនៅសាលារៀនគោលដៅតែងតែទទួលបានវគ្គបណ្តុះបណ្តាលផ្នែកជំនាញជាប្រចាំដើម្បីឱ្យការបង្រៀន និងរៀនមានភាពថ្មៃប្រឌិត។*

គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពី ការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន (EWS) ដែលធ្វើឡើងនៅបីទីកន្លែងផ្សេងៗគ្នារួមមាន ៖ សាលាបឋមសិស្សាលោ សាលាបឋមសិក្សាស្វាយតាម៉ែក និងសាលាបឋមសិក្សាទឹកជ្រៅ។ សិក្ខាកាមចូលរួមសរុបចំនួន ៦៦ នាក់ ស្រី៣១ នាក់ រួមមាន៖ មន្ត្រីតំណាងពីខាងមន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡា ខេត្ត-ស្រុក នាយក នាយករង និងលោកគ្រូអ្នកគ្រូដែលមកពីសាលារៀនគោលដៅទាំងប្រាំក្នុងខេត្តត្បូងឃ្មុំ។

វគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងនៅថ្ងៃទី ២៥ រហូតដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០២៣ ដែលមានគោលបំណងផ្តល់ឱ្យសិក្ខាកាម៖១-បានស្វែងយល់ពីប្រព័ន្ធរំឭកទុកជាមុន(EWS)។២-បង្កើនសមត្ថភាពលើការប្រើប្រាស់ប្រព័ន្ធរំឭកទុកជាមុន និងមានលទ្ធភាពអាចបណ្តុះបណ្តាលជាមួយនឹងសាលារៀន។ ៣-កំណត់អត្តសញ្ញាណសិស្សងាយរងគ្រោះសិស្សបោះបង់ការសិក្សា និងរបាយការណ៍គ្រប់គ្រងសាលារៀនដូចជា អវត្តមានសិស្សឥរិយាបថ លទ្ធផលសិក្សាប្រចាំខែ តារាងកិត្តិយស និងសៀវភៅតាមដានការសិក្សា និងផែនការបណ្តុះបណ្តាលកម្មវិធីប្រព័ន្ធរំឭកទុកជាមុនជាមួយសាលាគោលដៅរបស់គម្រោង។

សិក្ខាកាមបានយល់ដឹងពីវិធីប្រើប្រាស់ឧបករណ៍សំខាន់ៗក្នុងកម្មវិធីប្រព័ន្ធរំឭកទុកជាមុន រួមមាន៖ ការបង្កើតព័ត៌មានទូទៅរបស់សាលារៀន គណនីនាយក គ្រូ និងបង្កើតព័ត៌មានសិស្ស រៀបចំទិន្នន័យគ្រូ និងទាញគណនីគ្រូ និងសិស្សចូលតាមថ្នាក់ បង្កើតកាលវិភាគបង្រៀន កំណត់អវត្តមានសិស្សជាប្រចាំ និងការដាក់ពិន្ទុប្រចាំខែ។

សិក្ខាកាមទទួលបានចំណេះដឹងល្អៗជាច្រើនអំពីការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន ដើម្បីកំណត់អត្តសញ្ញណសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា និងចាត់វិធានការទប់ស្កាត់មិនឱ្យពួកគេបោះបង់ការសិក្សា ក៏ដូចជាធានាឱ្យបាននូវសិទ្ធិកុមារ ដើម្បីទទួលបានយ៉ាងហោចណាស់ការអប់រំមូលដ្ឋាន។

គួររម្លឹកផងដែរថា គម្រោងកុមារកម្ពុជារីករាយ ទទួលហិរញ្ញប្បទានពីមូលនិធិគីនឆាន់ ដែលមានគោលបំណងពង្រឹងលទ្ធភាពទទួលបានសេវាអប់រំឱ្យមានភាពប្រសើរឡើងនៅតំបន់គោលដៅ ជាពិសេសកុមារី និងកុមារងាយរងគ្រោះនៅតំបន់ដាចស្រយោល៕



*ការពង្រឹងលទ្ធភាពទទួលបានសេវាអប់រំឱ្យមានភាពល្អប្រសើរឡើងនៅតំបន់គោលដៅជាសកម្មភាពដ៏សំខាន់មួយដែលគម្រោងផ្តោតយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ការអប់រំ។*

# ការកែសម្រួលខ្លឹមសារឯកសារគោលរបស់កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ




*ការកែសម្រួលខ្លឹមសារតាមម៉ូឌុលនីមួយៗដើម្បីកាន់តែមានភាពងាយស្រួលដល់លោកគ្រូអ្នកគ្រូក្នុងការបង្រៀន។*

កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ(KDLP) បានរៀបចំកិច្ចពិគ្រោះយោបល់ស្តីពី ការកែសម្រួលខ្លឹមសារឯកសារគោលដោយមានម៉ូឌុលចំនួនប្រាំមួយ ដែលធ្វើឡើងនៅខេត្តកំពត ដោយមានសិក្ខាកាមជាក្រុមការងារស្នូលរបស់គម្រោង ដែលជាបុគ្គលិកអង្គការ ខេប។

កិច្ចពិគ្រោះយោបល់នេះ ធ្វើឡើងកាលពីថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងពិនិត្យ និងកែសម្រួលខ្លឹមសារលើឯកសារតាមម៉ូឌុលនីមួយៗដែលបានជ្រើសរើសធនធានសិក្សាចេញពីកម្មវិធី WeThinkDigital (WTD) ដែលនឹងត្រូវយកទៅប្រើប្រាស់ក្នុងបរិបទសាលារៀនជំនាន់ថ្មី។

សិក្ខាកាមបានពិភាក្សា និងពិនិត្យទៅលើធនធានសិក្សាពីកម្មវិធីWTD ដែលត្រូវបានជ្រើសរើសសម្រាប់ការអភិវឌ្ឍន៍ជាកញ្ចប់ធនធានសិក្សា ដែលមានប្រាំមួយម៉ូឌុលរួមមាន៖ ១)ការណែនាំអំពីការរៀនបែបឌីជីថល។ ២)មូលដ្ឋានគ្រឹះចំណេះដឹងឌីជីថល។ ៣)សុខុមាលភាពឌីជីថល។ ៤)ការផ្សារភ្ជាប់ទៅនឹងពិភពឌីជីថល ៥)ការពង្រឹងសិទ្ធិអំណាចឌីជីថល និងឱកាសឌីជីថល។ ដូចនេះបង្ករភាពងាយស្រួលដល់លោកគ្រូអ្នកគ្រូសម្រាប់បង្រៀន និងរៀនតាមម៉ូឌុលនីមួយៗ ដែលនឹងត្រូវអនុវត្តន៍សាកល្បងកម្មវិធីសិក្សាឌីជីថលថ្មីនេះទៅដល់សិស្សានុសិស្ស ប្រមាណ៣០០០ ទៅ ៥០០០នាក់ ក្នុងរយៈពេល៤ខែ នៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីទាំងអស់។

កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ(KDLP) ទទួលបានហិរញ្ញប្បទានពីក្រុមហ៊ុនមេតា (Meta) ដែលមានគោលបំណងក្នុងការផ្តល់សទិទានភាព និងការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា ICT សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៧-៩) នៅក្នុងសាលារៀនជំនាន់ថ្មី៕

# តើកម្មវិធីត្រីវិស័យជាអ្វី ?





*លោក សុខ សំណាង តំណាងមន្ទីរអប់រំយុវជននិងកីឡាខេត្តកំពតបានចូលរួមជាគណៈអធិបតីភាពក្នុងវគ្គបណ្តុះបណ្តាលស្តីពី កម្មវិធីត្រីវិស័យ។*

គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម(CO-SAVED) បានសហការជាមួយអង្គការ អេដ អេ អាកស្យុង រៀបចំវគ្គបណ្តុះបណ្តាលគ្រូប្រឹក្សាអាជីពមួយស្តីពី ការប្រើប្រាស់កម្មវិធីត្រីវិស័យ នៅសាលប្រជុំមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពត។ សិក្ខាកាមចូលរួមសរុបចំនួន៤៣ ស្រី ១០ នាក់ រួមមាន៖ នាយក នាយិកា លោកគ្រូអ្នកគ្រូប្រឹក្សាអាជីពដែលមកពីសាលារៀនគោលដៅក្នុងខេត្តកំពត និងខេត្តកែប។

វគ្គបណ្តុះបណ្តាលនេះ បានប្រព្រឹត្តទៅនៅថ្ងៃទី១២-១៣ ខែមិថុនា ឆ្នាំ ២០២៣ ដើម្បីកសាងសមត្ថភាពគ្រូប្រឹក្សាអាជីព នាយកនាយិកា មន្ត្រីតំណាងមន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក បានដឹងពីវិធីផ្តល់ការប្រឹក្សាដល់សិស្សតាមរយៈការប្រើប្រាស់កម្មវិធីត្រីវិស័យ។

**លោក សុខ សំណាង** តំណាងមន្ទីរអប់រំយុវជននិងកីឡាខេត្តកំពតបានមានប្រសាសន៍ "**កម្មវិធីត្រីវិស័យ ពិតជាមានសារសំខាន់ខ្លាំងណាស់ សម្រាប់ជួយតម្រង់ទិសសិស្សានុសិស្សត្រៀមខ្លួនជ្រើសរើសជំនាញនាពេលអនាគត ឱ្យត្រូវនឹងសមត្ថភាពរបស់សិស្ស។ ម្យ៉ាងទៀត កម្មវិធីនេះ ត្រូវបានក្រសួងប្រកាសដាក់ឱ្យវិទ្យាល័យធនធានទូទៅប្រទេសបានអនុវត្តន៍តាំងពីឆ្នាំ២០២១ ដូច្នេះ សូមឱ្យលោកគ្រូអ្នកគ្រូចូលរួមយ៉ាងសកម្មជាមួយគម្រោង ដើម្បីបណ្តុះទម្លាប់ឱ្យសិស្សានុសិស្សចាប់ផ្តើមរៀបចំផែនការអនាគត ជាពិសេស ត្រៀមខ្លួនសម្រាប់អាជីពការងារដែលពួកគេស្រឡាញ់ពេញចិត្ត**"។

កម្មវិធីត្រីវិស័យ ជាកម្មវិធីមួយដែលផ្តល់ការប្រឹក្សាពីជំនាញ និងការងារដោយមិនត្រូវការអ៊ីនធើណែត ដែលអាចផ្តល់ជូនចំណេះដឹង និងព័ត៌មានដែលចាំបាច់ដើម្បីកំណត់គោលដៅ និងបង្កើតផែនការសម្រាប់អនាគតដល់សិស្សានុសិស្ស៕

# គោលនយោបាយទប់ស្កាត់ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទ (PSEA)

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប/KAPE) បានរៀបចំវគ្គបណ្តុះបណ្តាលការកសាងសមត្ថភាពលើគោលនយោបាយទប់ស្កាត់ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទ (PSEA) ដែលធ្វើឡើងនៅក្នុងវិទ្យាស្ថានបច្ចេកវិទ្យាគិរីរម្យ ខេត្តកំពង់ស្ពឺ ដោយទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ។ សិក្ខាកាមចូលរួមសរុបចំនួន ៣៥ នាក់ (ស្ត្រី ១៤ នាក់) រួមមាន៖ ថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ប្រធានគម្រោង និងមន្ត្រីគម្រោងរបស់អង្គការខេប។


កិច្ចពិភាក្សាក្រុមលើករណីសិក្សាដែលកម្មវិធីបានផ្តល់ជូនដល់សិក្ខាកាមដោយផ្អែកលើគោលនយោបាយ PSEA។

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណង៖ ១- ស្វែងយល់ពីគោលការណ៍សំខាន់ៗ អំពីគោលនយោបាយការទប់ស្កាត់កេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទ (PSEA)។ ២-បញ្ជ្រាបគោលនយោបាយនេះទៅកាន់ថ្នាក់ដឹកនាំ ប្រធានគម្រោង និងមន្ត្រីកម្មវិធី អំពីការទប់ស្កាត់កេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទ និង៣-ធ្វើឱ្យបុគ្គលិកយល់ដឹងបន្ថែមពីក្រមសីលធម៌របស់អង្គការ ខេប និងព្រមព្រៀងក្នុងការអនុវត្តគោលនយោបាយដែលបានបង្កើតឡើង។

ការកសាងសមត្ថភាពទទួលបានលទ្ធផលល្អគួរឱ្យកត់សម្គាល់ ហើយសង្ឃឹមថាគោលនយោបាយនេះនឹងត្រូវបានចែករំលែកជាមួយអ្នកពាក់ព័ន្ធដទៃទៀតកាន់តែទូលំទូលាយនាពេលអនាគត ជាពិសេសបុគ្គលិកទាំងអស់ប្តេជ្ញានឹងអនុវត្ត និងបញ្ជ្រាប PSEA ទៅក្នុងការងាររបស់គាត់៕

# បរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំសង្គមដែលប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែកទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំពិសេស គឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិ និងឧត្តមប្រយោជន៍របស់ប្រទេស។ ជាតុចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិ គឺជាសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។

ការវិវត្តយ៉ាងរហ័សបំផុត និងភាពបន្ទាន់បំផុតនៃបច្ចេកវិទ្យាអប់រំនៅកម្ពុជាក្នុងឆ្នាំ២០២០ បានធ្វើឱ្យរបត់នៃបរិវត្តកម្មឌីជីថលក្លាយទៅជាជីពចរនៃការនិទស្សន៍លើសន្ទុះនៃកំណែទម្រង់វិស័យអប់រំ។ ការបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំ មិនមែនកើតឡើងត្រឹមមួយថ្ងៃ ហើយក៏មិនមែនកើតឡើងដោយសារបរិការណ៍នៃការផ្ទុះឡើង និងការីករាលដាលនៃជំងឺកូវីដ១៩នោះដែរ។ បរិវត្តកម្មនេះ កាន់តែមិនមែនជាការកសាងមូលដ្ឋាននៃការអប់រំថ្មីមួយ ដោយបែងចែកដាច់ចេញពីគ្រឹះដ៏រឹងមាំនៃការអប់រំនៅកម្ពុជា ជាពិសេសដែលបានអភិវឌ្ឍ សូមអានបន្តទំព័រ១៦


ធនធានមនុស្សដែលមានទេពកោសល្យផ្នែកឌីជីថល ជាតួអង្គដ៏សំខាន់នៅក្នុងបរិបទនៃបរិវត្តកម្មឌីជីថលទាំងនៅក្នុងអេកូស៊ីស្តែមនៃវិស័យអប់រំ និងទាំងនៅក្នុងវិស័យសេដ្ឋកិច្ច។




*បច្ចុប្បន្ន តាមការប៉ាន់ស្មាន កម្ពុជាមានធនធានមនុស្សដែលមានទេពកោសល្យផ្នែកឌីជីថលប្រមាណ ៥០០០០ នាក់ ខណៈដែលកម្លាំងពលកម្មនៅក្នុងវិស័យ ICT ភាគច្រើន ជំនាញផ្សេងទៀតនៅមានកម្រិតមធ្យម។*

**តពីទំព័រ១៥** នៅ៤០ឆ្នាំចុងក្រោយនេះដែរ។ ផ្ទុយទៅវិញ ប្រហែលជាបរិការណ៍កូវីដ-១៩ ជាចលករដែលនាំឱ្យមានការបន្សាំយ៉ាងលឿន និងសមាហរណកម្មយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាអប់រំ គួបផ្សំជាមួយនឹងកិច្ចខិតខំប្រឹងប្រែងនៃកំណែទម្រង់វិស័យអប់រំនៅប្រមាណ៧ឆ្នាំចុងក្រោយនេះ ដែលធ្វើឱ្យការអប់រំឌីជីថលនៅកម្ពុជា ហាក់ដូចជាវិវត្តបាន១០ឆ្នាំលឿនជាងការរំពឹងទុក។

ការអប់រំឌីជីថលជាផ្នត់គំនិត ដូច្នេះ បរិវត្តកម្មនៃអេកូស៊ីស្តែមនៃការអប់រំឌីជីថល គឺមានន័យថាជាការធ្វើឱ្យប្រសើរឡើងចំពោះជាតុទាំងឡាយនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ( សិស្ស គ្រូ សកម្មភាពថ្នាក់រៀន និងកម្មវិធីសិក្សា ) ដោយផ្នត់គំនិតថ្មីមួយ។

ព្រះរាជាណាចក្រកម្ពុជាមានបំណងប្រាថ្នាដ៏ថ្លៃថ្លា ក្នុងការប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។ ដើម្បីសម្រេចបានមហិច្ឆតានេះ កម្ពុជាត្រូវពង្រឹងអភិវឌ្ឍឿនសេដ្ឋកិច្ចដែលប្រកបដោយពុទ្ធិ ជំរុញដោយបច្ចេកវិទ្យា និងពោរពេញដោយឋាមវន្តដែលទ្រទ្រង់ និងដឹកនាំដោយមូលធនមនុស្សដែលមានជំនាញ និងមានផលិតភាពខ្ពស់។ ការអភិវឌ្ឍនៅក្នុងវិស័យបច្ចេកវិទ្យាអប់រំបានផ្តល់លទ្ធភាពដល់គ្រូក្នុងការបង្កើត និងផ្តល់បទពិសោធនៃការអប់រំកាន់តែសម្បូរបែបដល់សិស្ស។ ម៉្យាងទៀត ចាប់ពីពេលនេះតទៅ សិស្សនឹងចម្រើនវ័យជាមួយសម្ភារ និងឧបករណ៍ដែលតភ្ជាប់ជាមួយនឹងបណ្តាញ Internet ទាំងនៅក្នុងផ្ទះ និងទាំងនៅសាលារៀន ហើយដែលធ្វើឱ្យរបៀបនៃការរៀនរបស់ពួកគេត្រូវមានការផ្លាស់ប្តូរ។ ដោយសារតែអនាគតនៃការអប់រំនឹងពឹងផ្អែកយ៉ាងខ្លាំងទៅលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដូច្នេះការធានាឱ្យបានថាឧបករណ៍ សម្ភារ វេទិកា មាតិកា និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល នឹងត្រូវបានប្រើប្រាស់ប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន សម្រាប់ការអប់រំពេញមួយជីវិត គឺទាមទារឱ្យគ្រូត្រូវធ្វើជាម្ចាស់ ត្រូវមានសមត្ថភាពអក្ខរកម្មឌីជីថល និងដឹកនាំការបង្រៀនសម្រាប់ពលរដ្ឋឌីជីថល។

ដោយមានកិច្ចសហការជាមួយធនាគារអភិវឌ្ឍអាស៊ី ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០ ដែលបានកំណត់អាទិភាពសំខាន់ៗ៨ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអប់រំមធ្យមសិក្សា និងជំរុញឱ្យកម្ពុជាឆ្ពោះទៅសម្រេចចក្ខុវិស័យក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ អាទិភាពសំខាន់ៗទាំង៨ រួមមាន៖១-បង្កើនការចូលរៀន និងគុណភាពនៃការអប់រំមធ្យមសិក្សាចំណេះទូទៅ រួមទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។ ២-បន្តផ្តោតការយកចិត្តទុកដាក់ជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ និងគ្រប់គ្រង។ ៣-បន្សីកម្មវិធីសិក្សា ការបង្រៀន និងវាយតម្លៃគ្រប់មុខវិជ្ជា ជាពិសេស វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ឱ្យស្របតាមគុណភាពអប់រំសម្រាប់សតវត្សទី២១។ ៤ -បញ្ចូលការអប់រំឌីជីថលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា។ ៥-រៀបចំ និងអនុវត្តគោលនយោបាយគ្រូបង្រៀនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ៦-បន្តផ្តោតការយកចិត្តទុកដាក់ជាប្រព័ន្ធលើការលើកកម្ពស់ការអប់រំគ្រូមធ្យមសិក្សា។ ៧-ធ្វើពិពិធកម្ម និងពង្រឹងលទ្ធផលនៃការអប់រំបច្ចេកទេសមធ្យមសិក្សា ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងទីផ្សារការងារក្នុងមូលដ្ឋាន និងបង្កើនសហការរវាងការអប់រំមធ្យមសិក្សា និងក្រោមមធ្យមសិក្សា និងការចូលរួមពីតួអង្គពាក់ព័ន្ធ។

ការអប់រំឌីជីថល សំដៅដល់ការធ្វើអ្វីមួយក្នុងការអប់រំដោយបច្ចេកវិទ្យាឌីជីថលជាជាងនៅត្រឹមតែជាអ្វីមួយនៃបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ។ **(អត្ថបទដកស្រង់ចេញពីសៀវភៅ ការអប់រំឌីជីថល)**

អនុវិស័យទី ៣

# ការអភិវឌ្ឍគ្រូបង្រៀន

"គ្រូដែលល្អមិនមែនគ្រាន់តែជាអ្នកប្រាប់ ជាអ្នកពន្យល់ និងបង្ហាញនោះទេ តែជាអ្នកជំរុញលើកទឹកចិត្តសិស្ស"

## Teacher Development

*The mediocre teacher tells. The good teacher explains.*
*The superior teacher demonstrates. The great teacher inspires.*



# គ្រូបង្រៀនកិច្ចសន្យានៅតំបន់គោលដៅទទួលបានការគាំទ្រពីគម្រោង



ដើម្បីកសាងសមត្ថភាពគ្រូកិច្ចសន្យា គម្រោងតែងតែផ្ដល់វគ្គបណ្ដុះបណ្ដាលក្នុងការលើកកម្ពស់ការអនុវត្តគរុកោសល្យបង្រៀនរបស់ពួកគេ។

គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំសិក្ខាសាលាមួយស្ដីពី គ្រូបង្រៀនកិច្ចសន្យាជំនាន់ទី១ ឆ្នាំទី៣ ដែលធ្វើឡើងនៅសាលាបឋមសិក្សាស្វាយសរ ។ សមាសភាពអ្នកចូលរួមសរុបចំនួន ១៦ នាក់ រួមមាន៖ មន្ត្រីការិយាល័យអធិការកិច្ច មន្ទីរអប់រំ យុវជន និងកីឡាខេត្ត មន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡាស្រុកក្រឡាញ់ និងវ៉ារិន និងលោកគ្រូអ្នកគ្រូកិច្ចសន្យា ដែលមកពីសាលារៀនគោលដៅចំនួន៦ ខេត្តសៀមរាប។

សិក្ខាសាលានេះ ប្រព្រឹត្តទៅមានរយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី២៥-២៦ ខែឧសភា ឆ្នាំ២០២៣ មានគោលបំណងបង្ហាញគំនិតសំខាន់ៗមុនសរសេរកិច្ចតែងការបង្រៀន និងពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូលើការផលិតសម្ភារឧបទេស និងការប្រើប្រាស់ប្រកបដោយគុណភាព និងមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀន។

លោកគ្រូអ្នកគ្រូទទួលបានចំណេះដឹងជាច្រើនដូចជា ការរៀបចំកិច្ចតែងការបង្រៀន និងសម្ភារឧបទេស ការបានអនុវត្តផ្ទាល់លើការបង្រៀនតាមតំណាងក្រុមនីមួយៗ និងមានវិធីសាស្ត្របង្រៀនល្អៗដើម្បីធ្វើឱ្យសិស្សមានការចូលរួមក្នុងការសិក្សាប្រកបដោយបរិយាកាសសប្បាយរីករាយ។

ទន្ទឹមនឹងនេះ វគ្គសិក្ខាសាលានេះនឹងបន្តបណ្ដុះបណ្ដាលដល់គ្រូកិច្ចសន្យាតាមខេត្តផ្សេងៗក្នុងសាលារៀនគោលដៅរបស់ខ្លួន ដូចជា ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ និងខេត្តរតនគិរី ដែលបានចាប់ផ្ដើមតាំងពីថ្ងៃទី២៤ ខែឧសភា រហូតដល់ថ្ងៃទី០១ ខែមិថុនា ដើម្បីបង្កើនចំណេះដឹងបន្ថែមដល់លោកគ្រូអ្នកគ្រូលើការបង្រៀន និងរៀន។

ការពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូលើវិធីសាស្ត្របង្រៀនជាសកម្មភាពដ៏សំខាន់នៅតាមសាលារៀនគោល៕



គម្រោងបានជួលគ្រូប្រឹក្សាគរុកោសល្យពេញម៉ោង ដើម្បីពង្រឹងសមត្ថភាពក្នុងការបង្រៀន និងរៀន និងផ្ដល់ការគាំទ្រដល់គ្រូកិច្ចសន្យា ព្រមទាំងបច្ចេកទេសក្នុងការគ្រប់គ្រងសិស្ស។

# តើការអប់រំបរិយាបន្នជាអ្វី ?



*ការអប់រំបរិយាបន្នផ្តល់វិធីបង្រៀនផ្សេងៗដែលគ្រូឧទ្ទេសអាចប្រើប្រាស់ដើម្បីអភិវឌ្ឍសមត្ថភាពនៅក្នុងការអប់រំ។*

ការពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូបង្គោលនូវទស្សនទានថ្មីៗ នៃការអប់រំបរិយាបន្ន និងវិធីសាស្ត្រនៃការសម្របសម្រួលថ្នាក់ ការអប់រំបែបបរិយាបន្នគឺជាសកម្មភាពដែលចាំបាច់សម្រាប់ឆ្លើយតបនឹងតម្រូវការនៅតាមសាលាគោលដៅក្នុងខេត្តសៀមរាប។ វគ្គបណ្តុះបណ្តាលនេះពិតជាមានសារៈសំខាន់ដើម្បីផ្តល់ចំណេះដឹង និងបទពិសោធន៍ស្តីពីការអប់រំបរិយាបន្នផ្សព្វផ្សាយដល់សាលាគោលដៅ និងការផ្លាស់ប្តូរឥរិយាបថក្នុងសហគមន៍។

គម្រោងសហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិច តំបន់១ ឬហៅកាត់ថា គម្រោង FOSTER បានរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការអប់រំបរិយាបន្ន នៅសាលប្រជុំរដ្ឋបាលខេត្តសៀមរាប កាលពីថ្ងៃទី២៥-២៧ ខែឧសភា ឆ្នាំ២០២៣។ វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមប្រមាណជា៦០នាក់ ដែលជាប្រធានការិយាល័យបឋមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប មន្ត្រីការិយាល័យ DTMT នាយក/នាយិកាសាលាបឋមសិក្សាគោលដៅគម្រោងទាំង៣១សាលា និងគ្រូបង្គោលទទួលបន្ទុកសម្របសម្រួលថ្នាក់អប់រំបែបបរិយាបន្នមកពីសាលាគោលដៅចំនួន២១។ ការអប់រំបរិយាបន្ន គឺជាវិធីសាស្ត្រសកម្មនៃការឆ្លើយតបដោយវិជ្ជមានទៅកាន់ភាពចម្រុះគ្នានៃសិស្ស និងការមើលឃើញភាពខុសគ្នារបស់សិស្សមិនមែនជាបញ្ហា ប៉ុន្តែជាឱកាសសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង។

វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងសហប្រតិបត្តិដោយអង្គការ AeA អង្គការប្រតិបត្តិការកុមារកម្ពុជា អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) និងអង្គការ Oxfam៕

# ហេតុអ្វីបានជាសិស្សានុសិស្សត្រូវស្វែងយល់ពីកម្មវិធីត្រីវិស័យ ?

គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED) បានសហការជាមួយអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម និងសមាគមន៍បណ្តុះកុមារ បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូប្រឹក្សាអាជីពតាមសាលារៀនស្តីពី ការប្រើប្រាស់កម្មវិធីត្រីវិស័យ ដែលធ្វើឡើងនៅខេត្តកោះកុង និងខេត្តព្រះសីហនុ កាលពីថ្ងៃទី០២-០៣ និងថ្ងៃទី០៥-០៦ ខែមិថុនា ឆ្នាំ២០២៣។

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងកសាងសមត្ថភាពគ្រូប្រឹក្សាអាជីព នាយកនាយិកា មន្ត្រីតំណាងខាងមន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក ពីការប្រឹក្សាអាជីពដល់សិស្ស ដោយប្រើប្រាស់កម្មវិធីត្រីវិស័យដើម្បីតម្រង់ទិសសិស្សានុ-សិស្សក្នុងការជ្រើសរើសជំនាញឱ្យបានត្រឹមត្រូវនាពេលអនាគតដោយផ្អែកលើមុខវិជ្ជាដែលខ្លួនពូកែ និងសមស្របតាមបុគ្គលិកលក្ខណៈរបស់ខ្លួន។

**លោក ហ៊ុន សាម៉យ** តំណាងមន្ទីរអប់រំយុវជននិងកីឡាខេត្តកោះកុង បានមានប្រសាសន៍ថា **"ធ្លាប់តែឮត្រីវិស័យ ជាឧបករណ៍ចង្អុលទិសតាមដែនម៉ាញ៉េតិចទៅទិសខាងជើង តែនៅថ្ងៃនេះអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដែលជាស្ថាបនិករៀបចំដំបូងរហូតដល់បានបង្កើតកម្មវិធីនេះ និងបាននវានុវត្តន៍ក្លាយទៅជាប្រព័ន្ធមួយដ៏ល្អក្នុងការវាយតម្លៃសមត្ថភាពសិស្សសមស្របទៅនឹងជំនាញសិក្សា។ ឧបករណ៍នេះ បានដើរតួនាទីយ៉ាងសំខាន់ ជួយសិស្សនៅកម្រិតមធ្យមសិក្សាក្នុងការជ្រើសរើសជំនាញកាន់តែមានច្បាស់ ដើម្បីសម្រេចគោលបំណងរបស់ពួកគាត់ទៅថ្ងៃអនាគត។"**

កម្មវិធីត្រីវិស័យ ជាកម្មវិធីមួយដែលផ្តល់ជំបូន្មានពីជំនាញ និងការងារដោយមិនត្រូវការអ៊ីនធើណែត ដែលអាចផ្តល់ជូនចំណេះដឹង និងព័ត៌មានដែលចាំបាច់ដើម្បីកំណត់គោលដៅ និងបង្កើតផែនការសម្រាប់អនាគតដល់សិស្សានុសិស្ស៕


*លោកគ្រូអ្នកគ្រូនឹងធ្វើការផ្សព្វផ្សាយទៅដល់សិស្សនៅតាមសាលារៀនរបស់ពួកគាត់តាំងពីកម្រិតអនុវិទ្យាល័យ។*

# បណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង



*ដើម្បីឱ្យសាលារៀនគោលដៅមានភាពរីកចម្រើន គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់នាយកជាទុនដែលអាចយកទៅប្រើប្រាស់ក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀន។*

កាលពីថ្ងៃទី១៣-១៤ ខែមិថុនា ឆ្នាំ ២០២៣ គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពី ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង (វគ្គទី៤) នៅសាលាបឋមសិក្សាសំបូរ ដោយមានសិក្ខាកាមចូលរួមដូចជានាយក នាយករង មន្ត្រីមន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡា និងលោកគ្រូអ្នកគ្រូដែលមកពីសាលារៀនចំនួនប្រាំពីរក្នុងស្រុកក្រឡាញ់ និងវ៉ារិនក្នុងខេត្តសៀម-រាប។

វគ្គបណ្តុះបណ្តាលនេះ ផ្តល់ឱ្យសិក្ខាកាម៖១-យល់កាន់តែស៊ីជម្រៅនូវគំនិត និងបំណិនទាំងឡាយដែលបានសិក្សានៅភាពជាអ្នកដឹកនាំទី១ ២ និង៣។ ២-កំណត់បាននូវវិធីដើម្បីប្រែក្លាយគំនិតដែលបានសិក្សាក្នុងសិក្ខាសាលានេះឱ្យទៅជាការអនុវត្តជាក់ស្តែង និងសកម្មភាពដែលនាយកសាលាអាចប្រតិបត្តិនៅសាលារៀន។ ៣-យល់នូវវិធីដែលនាយកសាលាត្រូវធ្វើដើម្បីគៀករការចូលរួមរបស់សហគមន៍។ ៤-យល់នូវវិធីធ្វើខ្លួនជាអ្នកផ្តល់ការប្រឹក្សាជួយគ្រូថ្មីៗទើបចេញពីសាលារៀន និងឱ្យយល់កាន់តែច្បាស់នូវភាពចាំបាច់ដែលឱ្យសិស្សមានការគិតកម្រិតខ្ពស់ដែលជាវិធីមួយជួយឱ្យវិស័យអប់រំនៅកម្ពុជាកាន់តែប្រសើរឡើង។

ប្រធានបទល្អៗជាច្រើនដែលសិក្ខាកាមទទួលបានតាមរយៈការពិភាក្សាក្រុម និងការចែករំលែកបទពិសោធន៍ក្នុងការដឹកនាំ រួមមាន៖ សារសំខាន់នៃការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍, នាយកសាលាជាគំរូ, ការប្រឹក្សាជួយគ្រូបង្រៀន, នាយកសាលាត្រូវមានវត្តមានបង្ហាញមុខ កែលម្អទំនាក់ទំនង និងត្រូវចេះច្នៃប្រឌិត, ការវិភាគទិន្នន័យដើម្បីកែលម្អការរៀនរបស់សិស្សទាមទារនូវការច្នៃប្រឌិតរបស់នាយក,ជំហានប្រាំនៃការបង្រៀន,ការជួយសិស្សឱ្យមានការគិតកម្រិតខ្ពស់, ការងារក្រុមតូច និងមានផ្សេងៗជាច្រើនទៀត។

សិក្ខាកាមបានស្វែងយល់បន្ថែមទៀតពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដែលពួកគាត់នឹងរៀបចំបង្កើតផែនការសកម្មភាពមួយសម្រាប់កែលម្អភាពជាអ្នកដឹកនាំនៅតាមសាលារៀនរៀងៗខ្លួនឱ្យមានលក្ខណៈរីកចម្រើន៕



*គម្រោងមិនត្រឹមតែផ្តល់វគ្គបណ្តុះបណ្តាលដល់គណៈគ្រប់គ្រងសាលារៀនប៉ុណ្ណោះទេ ថែមទាំងគាំទ្រគ្រប់សកម្មភាពសាលារៀនដើម្បីជួយសាលារៀនមានភាពឯករាជ្យក្នុងការដឹកនាំ និងគ្រប់គ្រងនាពេលអនាគត។*

# ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងតាមសាលារៀន (វគ្គទី៣)



សាលារៀនលូតលាស់រីកចម្រើនទៅបាន ដោយសារតែមានមេដឹកនាំល្អចេះបង្កើតទំនាក់ទំនងជាមួយសហគមន៍ អង្គការដៃគូ និងចេះដឹកនាំក្រុមដើរលើទស្សនវិស័យតែមួយរបស់សាលារៀន។

ភាពជាអ្នកដឹកនាំ គឺជាការយល់ពីរបៀបនៃការគ្រប់គ្រងមនុស្ស និងអាចទំនាក់ទំនងជាមួយនឹងមនុស្សបានគ្រប់ប្រភេទ ព្រមទាំងជំរុញឱ្យមនុស្សមួយក្រុមខិតខំធ្វើការដើម្បីឆ្ពោះទៅរកការសម្រេចគោលដៅរួមមួយ នឹងធ្វើយ៉ាងណាឱ្យសាលារៀនមានការផ្លាស់ប្តូរ និងរីកចម្រើន។ ចំណែកឯ ការគ្រប់គ្រងតាមសាលារៀន គឺជាមធ្យោបាយមួយផ្តល់ធម្មនុញ្ញសាលារៀន ដែលគណៈនាយក គ្រូបង្រៀន មាតាបិតាសិស្ស សមាជិកសហគមន៍ មានការគ្រប់គ្រងទៅលើអ្វីៗដែលកើតឡើងក្នុងសាលារៀន។ ដើម្បីជំរុញឱ្យសាលារៀនគោលដៅមានការអភិវឌ្ឍប្រកបដោយចីរភាព គម្រោងកុមារកម្ពុជារីករាយ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងតាមសាលារៀន(វគ្គទី៣) នៅសាលាបឋមសិក្សាស្វាយតាមែក ដោយមានសិក្ខាកាមចូលរួមចំនួន២៨ នាក់ (ស្រី ៧ នាក់) រួមមាន៖ នាយក នាយករង មន្ត្រីតំណាងការិយអប់រំ យុវជន និងកីឡាស្រុកតំបែរ និងពញាក្រែក និងមន្ត្រីការិយាល័យបឋមសិក្សា ព្រមទាំងលោកគ្រូអ្នកគ្រូដែលមកពីសាលារៀនគោលដៅចំនួន១២ក្នុងខេត្តត្បូងឃ្មុំ។

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងផ្តល់ឱ្យសិក្ខាកាម៖១-រំឭកឡើងវិញនូវប្រធានបទទាំងបួនដែលបានសិក្សាហើយក្នុងភាពជាអ្នកដឹកនាំទី១ និងទី២។ ២-យល់កាន់តែស៊ីជម្រៅនូវភាពជាអ្នកដឹកនាំដើម្បីកែលម្អការបង្រៀន និងរៀន និងទទួលបានវិធីសាស្ត្រ ល្អៗសម្រាប់អនុវត្តន៍។ ៣-យល់ពីសារសំខាន់នៃចក្ខុវិស័យ និងវិធីបង្កើតផែនការដើម្បីធ្វើឱ្យសម្រេចចក្ខុវិស័យ។ ៤-កាន់តែមានភាពច្នៃប្រឌិត និងមានឆន្ទៈហ៊ានប្រថុយ។ ៥-ពង្រឹងសមត្ថភាពក្នុងការដឹកនាំការប្រជុំក្រុមបច្ចេកទេស និងសង្កេតថ្នាក់រៀន ដើម្បីជួយទ្រទ្រង់ឱ្យកាន់តែមានប្រសិទ្ធភាព និងការផ្តល់ព័ត៌មានត្រឡប់ជូនគ្រូបង្រៀន ពោរពេញទៅដោយការជួយទ្រទ្រង់ដែលនឹងធ្វើឱ្យការបង្រៀន និងរៀនកាន់តែបានល្អប្រសើរឡើង។

សិក្ខាកាមទទួលបានចំណេះដឹង និងបទពិសោធន៍ល្អៗបន្ថែមទៀតពីភាពជាដឹកនាំ និងការគ្រប់គ្រងដូចជា បង្កើតចក្ខុវិស័យក្នុងសាលារៀន មានគំនិតច្នៃប្រឌិត និងហ៊ានប្រថុយឱ្យមានការផ្លាស់ប្តូរ សង្កេត និងតាមដានសកម្មភាពក្នុងថ្នាក់ដែលទ្រទ្រង់ការរៀនរបស់សិស្ស ផ្តល់ព័ត៌មានត្រឡប់ យល់ពីវិធីជំរុញទឹកចិត្តគ្រូ យល់ពីការគិតកម្រិតខ្ពស់ និងចេះបង្កើតផែនការសកម្មភាពថ្មីមួយសម្រាប់កែលម្អភាពជាអ្នកដឹកនាំរបស់សិក្ខាកាម។

គម្រោងកុមារកម្ពុជារីករាយ ទទួលហិរញ្ញប្បទានពីមូលនិធិគីនធាន ដើម្បីកែលម្អសមត្ថភាពគ្រប់គ្រងដៃគូនៅមូលដ្ឋាន បង្កើនលទ្ធភាពទទួលបានសេវាអប់រំ និងគុណភាពបង្រៀន និងរៀន ក៏ដូចជាការផ្សព្វផ្សាយនៅតាមសហគមន៍៕



លោក ម៉ៃ សារិទ្ធិ ជាអ្នកសម្របសម្រួលបច្ចេកទេស និងតស៊ូមតិអង្គការខេប កំពុងធ្វើបទបង្ហាញស្តីពីភាពជាអ្នកដឹកនាំ។

# ការពង្រឹងសមត្ថភាពគ្រូបង្រៀនកិច្ចសន្យានៅសាលារៀនរដ្ឋ

គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (BMZ/REACH IV) បានរៀបចំវគ្គតម្រង់ទិសដល់គ្រូកិច្ចសន្យាវគ្គ២ ស្តីពី វិធីសាស្ត្របង្រៀន និងរៀន ដែលធ្វើឡើងនៅសាលប្រជុំការិយាល័យអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង។

វគ្គតម្រង់ទិសធ្វើឡើងកាលពីថ្ងៃទី ១៥-១៦ ខែកញ្ញា ឆ្នាំ២០២៣ មានគោលបំណងពង្រឹងសមត្ថភាពគ្រូកិច្ចសន្យាឱ្យក្លាយទៅជាគ្រូបង្រៀននៅសាលាបឋមសិក្សារដ្ឋស្របតាមគរុកោសល្យអប់រំប្រកបដោយគុណភាព និងមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀន។

សិក្ខាកាមចូលរួមសរុបចំនួន ២៤ នាក់ មកពីសាលារៀនគោលដៅរបស់គម្រោងដើម្បីធ្វើការឆ្លុះបញ្ចាំងពីសកម្មភាពដែលបាន



ដើម្បីឱ្យការបង្រៀន និងរៀនក្នុងសាលារៀនរដ្ឋកាន់តែល្អប្រសើរ គម្រោងបានផ្តល់វគ្គបំប៉នសមត្ថភាពដល់គ្រូកិច្ចសន្យាប្រចាំ។

បណ្តុះបណ្តាលនៅវគ្គទី១ អំពីការរៀបចំកិច្ចតែងការបង្រៀន ការងាររដ្ឋបាលរបស់គ្រូបន្ទុកថ្នាក់ ការប្រើប្រាស់សំណួរ ការស្រាវជ្រាវ ផលិត និងប្រើប្រាស់សម្ភារឧបទេស ព្រមទាំងវិធីសាស្ត្របង្រៀន។

ការកសាងសមត្ថភាពគ្រូបង្រៀ និងអ្នកគ្រប់គ្រងសាលារៀនលើវិធីសាស្ត្របង្រៀនថ្មី និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំជាសកម្មដ៏សំខាន់មួយរបស់គម្រោង៕

# វគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធរំឭកជាមុន (EWS)

គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម(CO-SAVED)បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធរំឭកជាមុន (EWS) ដែលធ្វើឡើងនៅពីរទីតាំងក្នុងខេត្តខេត្តព្រះសីហនុ និងកោះកុងដែលធ្វើឡើងនៅថ្ងៃទី២១ និងថ្ងៃទី២៣ខែកញ្ញាឆ្នាំ២០២៣។ សិក្ខាកាមចូលរួមសរុបចំនួន ៥៥ នាក់ រួមមាន៖ នាយក នាយិកា និងលោកគ្រូអ្នកគ្រូដើម្បីរំឭកពីការប្រើប្រាស់កម្មវិធី។ វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងពង្រឹងសមត្ថភាពលោកនាយក និងគ្រូបង្គោលក្នុងការប្រើប្រាស់ឧបករណ៍គាំទ្រការកត់ត្រាប្រចាំថ្ងៃនៅក្នុងប្រព័ន្ធរំឭកជាមុន ពីក្រុមប្រឹក្សាកុមារ គ្រូបន្ទុកថ្នាក់ ការរៀបចំផែនការចុះអន្តរាគមន៍សិស្សងាយរងគ្រោះតាមលក្ខខណ្ឌប្រព័ន្ធរំឭកជាមុនដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន។

លោក ហួរ សុភាព អនុប្រធានការិយាល័យមធ្យមសិក្សាខេត្តព្រះសីហនុ



ដើម្បីចូលរួមកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្ស គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់លោកគ្រូអ្នកគ្រូសម្រាប់ជួយអន្តរាគមន៍ដល់សិស្សងាយរងគ្រោះ។

បានមានប្រសាសន៍ថា “**ការបោះបង់ការសិក្សាជារឿងមួយដែលថ្នាក់ដឹកនាំសាលារៀនត្រូវយកចិត្តទុកដាក់ និងតាមដានការសិក្សារបស់សិស្ស ។ កន្លងមកថ្នាក់ដឹកនាំខេត្ត បានចូលរួមសកម្មភាពជាច្រើនដើម្បីដោះស្រាយបញ្ហាប្រឈមនានា ដោយផ្តោតលើសម្មតិកម្ម៤យ៉ាងគឺ ទី១ សិស្សខ្លួនឯង ទី២ សាលារៀន ទី៣ ការចូលរួមអាណាព្យាបាល និងការចូលរួមពីសហគមន៍។ ប្រព័ន្ធរំឭកជាមុននេះបានជួយលោកគ្រូអ្នកគ្រូតាមដានការសិក្សារបស់សិស្សឱ្យកាន់តែច្បាស់ ដូចជា អវត្តមានប្រចាំថ្ងៃ ឥរិយាបថ និងលទ្ធផលសិក្សា។ ដូច្នេះចំណេះដឹងក្នុងវគ្គបណ្តុះបណ្តាលនេះនឹងជួយឱ្យសិក្ខាកាមចេះប្រើប្រាស់ឧបករណ៍ EWS ដើម្បីចូលរួមទប់ស្កាត់អត្រាបោះបង់ការសិក្សា**”។

គម្រោងCOSAVEDប្រតិបត្តិគម្រោងនៅក្នុងតំបន់ឆ្នេរនៃប្រទេសកម្ពុជាជាមួយនឹងដៃគូអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនដទៃទៀត ដើម្បីរួមសហការគ្នាក្នុងការអភិវឌ្ឍការអប់រំ និងការផ្តល់សេវាបៃតង ផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ

# ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង


ការកសាងសមត្ថភាពដល់គណៈគ្រប់គ្រងសាលារៀនជាផ្នែកមួយល្អដែលបានចូលរួមអភិវឌ្ឍវិស័យអប់រំ និងបានបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងសង្គម។

ការកែលម្អសមត្ថភាពគ្រប់គ្រងដៃគូនៅមូលដ្ឋាន ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាអប់រំ និងគុណភាពបង្រៀន និងរៀនជាគោលបំណងដ៏សំខាន់មួយរបស់គម្រោងកុមារកម្ពុជារីករាយ (HCC)។ កាលពីថ្ងៃទី១១-១២ ខែតុលា ឆ្នាំ២០២៣ គម្រោង HCC បានរៀបចំវគ្គសិក្ខាសាលាមួយស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង (វគ្គ១) ជូនដល់នាយក នាយករង លេខា និងមន្ត្រីពាក់ព័ន្ធ។

សិក្ខាសាលានេះត្រូវបានធ្វើឡើងនៅសាលាបឋមសិក្សា អង្គនារាម ស្ថិតក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដោយមានគោលបំណងផ្តល់ឱ្យសិក្ខាកាម នូវគន្លឹះសំខាន់ៗដូចខាងក្រោម៖ ១)ស្វែងយល់ពីនិយមន័យនៃភាពជាអ្នកដឹកនាំ និងអាចកំណត់បាននូវភាពខុសគ្នារវាង ការដឹកនាំ និង ការគ្រប់គ្រង ។ ២)យល់ពីសារៈសំខាន់នៃការជឿជាក់មួយចំនួនដែលអាចជួយលើកកម្ពស់ភាពជាអ្នកដឹកនាំ ។ ៣) មានសមត្ថភាពអាចអនុវត្តបាននូវការជឿជាក់បួនគឺ ចក្ខុវិស័យ, ការបង្ហាញមុខ ,ទំនាក់ទំនង និងការសិក្សា។ ៤)មានសមត្ថភាពកសាងអាំងឌីកាទ័រ និងវិភាគអាំងឌីកាទ័រ។ ៥)មានសមត្ថភាពជំរុញឱ្យសហគមន៍ចូលរួមពេញលេញក្នុងការជួយកុមារឱ្យរៀនបានល្អ និងអាចធ្វើផែនការអភិវឌ្ឍសាលារៀនដោយផ្អែកលើចក្ខុវិស័យ និងអាំងឌីកាទ័រ ។

សិក្ខាកាមនឹងយកចំណេះដឹងល្អៗទៅរៀបចំធ្វើផែនការអភិវឌ្ឍសាលារៀន និងបង្កើតផែនការសកម្មភាពសម្រាប់ការដឹកនាំ និងគ្រប់គ្រងសាលារៀនឱ្យមានភាពរីកចម្រើនលូតលាស់ ជាពិសេសនាយកសាលារៀនគោលដៅទាំងអស់នឹងទទួលបានការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំជាបន្តបន្ទាប់ ដើម្បីជួយឱ្យពួកគាត់ធ្វើការងារកាន់តែជិតស្និទ្ធជាមួយសហគមន៍មូលដ្ឋាន៕

# ការសិក្សាមុខវិជ្ជាអប់រំបំណិនជីវិតតាមមូលដ្ឋាន


ពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូក្នុងសាលារៀនគោលដៅរបស់គម្រោងលើការប្រើប្រាស់មជ្ឈមណ្ឌលសិក្សាតាមរយៈប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួង អប់រំ យុវជន និងកីឡា។

គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED) បានរៀបចំវគ្គតម្រង់ទិសមួយស្តីពី ការសិក្សាមុខវិជ្ជាអប់រំបំណិនជីវិតតាមមូលដ្ឋាន ដោយប្រើប្រាស់មជ្ឈមណ្ឌលសិក្សាតាមរយៈប្រព័ន្ធអេឡិចត្រូនិករបស់ ក្រសួង អប់រំ យុវជន និងកីឡា សម្រាប់ខេត្តគោលដៅចំនួនបួនរួមមាន ៖ កំពត កែប ព្រះសីហនុ និងកោះកុង ដែលស្ថិតនៅតំបន់មាត់សមុទ្រ។

វគ្គតម្រង់ទិសនេះ មានគោលបំណងផ្តល់ឱ្យសិក្ខាកាមបានយល់ដឹងអំពីមុខវិជ្ជាអប់រំបំណិនជីវិតតាមមូលដ្ឋាន បញ្ញត្តិនៃការអប់រំបំណិនជីវិត និងការអប់រំបំណិនទន់ ព្រមទាំងសកម្មភាពសម្រាប់ការបង្រៀននិងរៀន។ មួយវិញទៀត សិក្ខាកាមនឹងដឹងកាន់ច្បាស់ក្នុងដំណើរការជ្រើសរើសប្រធានបទសម្រាប់កម្មវិធីសិក្សាប្រចាំឆ្នាំ វិធីសាស្ត្រ ការវាយតម្លៃនៃការសិក្សាលើមុខវិជ្ជាអប់រំបំណិនជីវិតតាមមូលដ្ឋាន និងរៀបចំកាលវិភាគសិក្សាឱ្យបានច្បាស់លាស់ក្នុងសាលាជាមួយធនធានសហគមន៍មានស្រាប់។

មជ្ឈមណ្ឌលសិក្សាតាមរយៈអេឡិចត្រូនិក គឺជាមធ្យោបាយនៃការសិក្សាដោយខ្លួនឯងក្នុងបរិយាកាសមួយដែលផ្តល់ការសិក្សាយ៉ាងសម្បូរបែប តាមរយៈមាតិកាអប់រំឌីជីថល រួមមាន៖ ខ្លឹមសារមេរៀនជាវីដេអូ សំណួរ ពង្រឹងសមត្ថភាពខ្លីៗ លក្ខណៈជាអន្តរកម្ម

សូមអានបន្តទំព័រ២៤

**តពីទំព័រ២៣** ហើយវាមាន គោលបំណងសំខាន់ៗរួមមាន៖(១) លើកស្ទួយគុណភាព និងសមធម៌នៃការអប់រំនៅកម្ពុជាតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និង(២) មានមាតិកាអប់រំបែបឌីជីថល ដែលសិក្សានុសិក្សអាចធ្វើការស្វ័យសិក្សាបានដោយបើកចំហនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង និងប្រកបដោយសមធម៌។

វគ្គតម្រង់ទិសនេះ បានប្រព្រឹត្តទៅនៅថ្ងៃទី២៨ និងទី៣០ ខែតុលា ឆ្នាំ ២០២៣ នៅសាលប្រជុំ សាលាបឋមហ៊ុនសែនវាលវិញ ខេត្តព្រះសីហនុ និងនៅសាលប្រជុំសាលាបឋមសិក្សាអង្គរភ្នំក្នុង ខេត្តកោះកុង ដោយមានអ្នកចូលសរុបចំនួន ៧៤នាក់ ជាមន្ត្រីការិយាល័យអប់រំស្រុកគោលដៅ នាយកនាយិកា និងលោកគ្រូអ្នកគ្រូកម្មវិធីបំណិនជីវិតទាំងកម្រិតបឋម និងមធ្យមសិក្សា។



*លោក ផល សុវណ្ណធី អ្នកឯកទេសគុណភាពអប់រំ បានបង្ហាញពីការប្រើប្រាស់មជ្ឈមណ្ឌលសិក្សាតាមរយៈតាម ប្រព័ន្ធអេឡិចត្រូនិក ដែលវាជាមធ្យោបាយនៃការសិក្សាដោយខ្លួនឯងក្នុងបរិយាកាសមួយដែលផ្តល់ការសិក្សាយ៉ាងសម្បូរបែបតាមរយៈមាតិកាអប់រំ ឌីជីថល រួមមាន ខ្លឹមសារមេរៀនជាវីដេអូ សំណួរ ពង្រឹងសមត្ថភាពខ្លីៗ លក្ខណៈជាអន្តរកម្ម។*

អង្គការដៃគូ អេដ អេ អាក់ស្យុង (AEA), អង្គការសកម្មភាពព្រះសាសនាដើម្បីអភិវឌ្ឍន៍សង្គម(BSDA), អង្គការបណ្តុះកុមារ(BK) នឹងបន្តតម្រង់ទិសតាមស្រុកគោដៅរបស់ខ្លួន ចាប់ពីថ្ងៃទី០១-០២ ខែវិច្ឆិកា ឆ្នាំ ២០២៣ ក្រោមការជួយគាំទ្របច្ចេកទេសពីក្រុមការងារបច្ចេកទេសអង្គការខេបនៃគម្រោង ខូសេវ (CO-SAVED)។

គម្រោងCO-SAVED ទទួលបានហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងអង្គការអេដ អេ អាក់ស្យុង(AEA ) ដែលបានធ្វើការជាមួយនឹងអង្គការដៃគូ និងវិស័យឯកជនដទៃទៀត ដើម្បីរួមសហការគ្នាក្នុងការអភិវឌ្ឍការអប់រំ និងការផ្តល់សេវាបៃតងផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រកបដោយនិរន្តរភាព៕

# ការកសាងសមត្ថភាពស្តីពី អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងឌីជីថល

ដោយទទួលបានហិរញ្ញប្បទានគាំទ្រពីអង្គការយូណេស្កូប្រចាំប្រទេសកម្ពុជា អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) បានផ្តល់វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពស្តីពី អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងឌីជីថល(MIDL លើកទី១)ទៅដល់អង្គការជនមានពិការភាព (OPDs) ដែលធ្វើឡើងនៅសាលារៀនជំនាន់ថ្មីវិទ្យាល័យហ៊ុន សែនកំពង់ចាម។ សិក្ខាកាមចូលរួមសរុបចំនួន ៥៨ នាក់ ដែលមកពីរាជធានីខេត្ត ចំនួន១៤។

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងផ្តល់ឱ្យអង្គការជនពិការភាពនូវចំណេះដឹងចាំបាច់ ធនធាន និងសមត្ថភាពក្នុងការពង្រឹងជំនាញអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងឌីជីថលក្នុងចំណោមជនមានពិការភាព ព្រមទាំងជំរុញការអភិវឌ្ឍជំនាញឌីជីថលនៅតាមស្ថាប័នរបស់ពួកគេនៅពេលអនាគត។

សិក្ខាកាមទទួលបានចំណេះដឹងសំខាន់ជាច្រើនរួមមាន៖ ស្វែងយល់ពីមូលដ្ឋានគ្រឹះនៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មានខុស ព័ត៌មានមិនពិត និងការនិយាយសម្អប់ ឥទ្ធិផលព័ត៌មាន យុគសម័យព័ត៌មានមិនពិត ឱកាស និងបញ្ហាប្រឈមរបស់អ៊ីនធឺណិត។

អង្គការជនមានពិការភាពនឹងទទួលបានវគ្គបណ្តុះបណ្តាលចំនួន៤លើក ដើម្បីជំរុញការតភ្ជាប់ប្រកបដោយអត្ថន័យដែលជាគោលដៅសម្រាប់ការប្រើប្រាស់អ៊ីនធឺណិត និងដោះស្រាយបញ្ហាគម្លាតយេនឌ័រ៕



*សិក្ខាកាមនឹងទទួលបានចំណេះដឹងចាំបាច់មួយចំនួន និងឧបករណ៍ឌីជីថលសំខាន់ៗជាច្រើនដែលអាចអនុញ្ញាតឱ្យពួកគាត់ប្រើប្រាស់ធនធានដែលមានស្រាប់ និងបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយថ្មីៗ ដែលអាចជួលសម្រួលដល់ការរស់នៅកាន់តែល្អប្រសើរឡើង។*

# វឌ្ឍនភាពសាលារៀនជាមួយអ្នកពាក់ព័ន្ធសំខាន់ៗក្នុងគម្រោង

គម្រោងងាយស្រួលរៀន (ក្រចេះ) បានរៀបចំវគ្គសិក្ខាសាលាថ្នាក់ក្រោមជាតិស្តីពី វឌ្ឍនភាពសាលារៀនជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដែលធ្វើឡើងនៅសាលាស្រុកសំបូរ ខេត្តក្រចេះ នៅថ្ងៃទី១៥ ខែធ្នូ ២០២៣។ សិក្ខាកាមចូលរួមដូចជា នាយកសាលារៀនចំនួន៩ក្នុងស្រុកសំបូរ និងក្រុមគ្រូតពិនិត្យតាមដានការបំប៉នថ្នាក់ស្រុក (DTMT)។

សិក្ខាសាលាមានគោលបំណង៖ ១)បង្ហាញលទ្ធផល និងពិនិត្យវឌ្ឍនភាពនៃ DTMT ដែលគាំទ្រជួយសាលាក្នុងគម្រោង។ ២) ការដឹកនាំ និងគ្រប់គ្រងសាលារៀនឱ្យមានប្រសិទ្ធភាព។ ៣)ដំណើរការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព មានគុណភាពខ្ពស់ (សិស្សធំជួយសិស្សតូច បណ្ណាល័យ និងសកម្មភាពផ្សេងៗ) ។ ៤)ភាពរីកចម្រើនរបស់សាលារៀន (ហេដ្ឋារចនាសម្ព័ន្ធ និងទិន្នន័យសិក្សា) និង ៥) លើកឡើងពីបញ្ហាប្រឈមសំខាន់ៗ និងស្វែងយល់អំពីអនុសាសន៍ថ្មីៗដើម្បីរៀបផែនការយុទ្ធសាស្ត្រ។

សិក្ខាកាមតាមសាលារៀននីមួយៗ បានធ្វើការបង្ហាញផែនការយុទ្ធសាស្ត្រសាលារៀន ការដឹកនាំ និងគ្រប់គ្រងសាលារៀន គុណភាពអប់រំកម្រិតសាលារៀន ការចូលរួមរបស់សហគមន៍ ផែនការសកម្មភាពក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី និងកម្មវិធីសាលាកុមារមេត្រី។ សិក្ខាកាមបានចែករំលែកពីវិធីសាស្ត្រជួយសិស្ស វិធីសាស្ត្ររៀន និងបង្រៀនសកម្មភាពបណ្ណាល័យ និងអំណាន។

ការជំរុញដំណើរការការចូលរៀនរបស់កុមារគ្រប់អាយុឱ្យបានចូលរៀនទាំងអស់គ្នានៅសាលាបឋមសិក្សាគោលដៅឱ្យប្រសើរឡើង និងកែលម្អបរិស្ថានសាលារៀន ព្រមទាំងការបង្រៀន និងរៀនស្របតាមគោលនយោបាយសាលាកុមារមេត្រីនៅក្នុងសាលាគោលដៅ។

គម្រោងងាយស្រួលរៀន (ក្រចេះ) ទទួលបានហិរញ្ញប្បទានពីអង្គការឆាលហ្វានកូរ៉េ ដែលមានគោលបំណងចម្បងផ្តោតលើការលើកកម្ពស់គុណភាពនៃការអប់រំបឋមសិក្សាសម្រាប់កុមារទាំងអស់នៅស្រុកសំបូរ ខេត្តក្រចេះ៕



*សាលារៀនអភិវឌ្ឍន៍ និងរីកចម្រើន ដោយសារមានសមាសភាពចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដូចជា គណៈគ្រប់គ្រងសាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន គ្រូបង្រៀន សប្បុរសជន អាជ្ញាធរមូលដ្ឋាន និងសហគមន៍។*

# ការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន (EWS)

កាលពីចុងខែធ្នូ ឆ្នាំ២០២៣ គម្រោង FOSTER ដែលទទួលបានជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប (EU), EAC និងសហប្រតិបត្តិដោយអង្គការ AEA, អង្គការប្រតិបត្តិការកុមារកម្ពុជា (OEC), អង្គការខេប និងអង្គការ Oxfam បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី៖ ការប្រើប្រាស់កម្មវិធីប្រព័ន្ធរំឭកទុកជាមុន (EWS) ស្ថិតនៅក្នុងមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ក្នុងគោលបំណងផ្សព្វផ្សាយអំពីការស្វែងយល់ និងការកសាងសមត្ថភាពសម្រាប់ប្រើប្រាស់ប្រព័ន្ធរំឭកទុកជាមុនឱ្យបានគ្រប់ជ្រុងជ្រោយ និងកំណត់អត្តសញ្ញាណសិស្សងាយរងគ្រោះដែលនឹងបោះបង់ការសិក្សា។

វគ្គនេះក៏បានបង្ហាញអំពីរបាយការណ៍គ្រប់គ្រងសាលារៀនដោយផ្តោតសំខាន់ទៅលើអវត្តមានសិស្ស ឥរិយាបថលទ្ធផលសិក្សាប្រចាំខែ តារាងកិត្តិយស និងសៀវភៅតាមដានការសិក្សា។ វគ្គបណ្តុះបណ្តាលនេះមានសារៈសំខាន់ចំពោះប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធានការិយាល័យមធ្យមសិក្សាចំណេះទូទៅ ប្រធានការិយាល័យបឋមសិក្សា មន្ត្រីការិយាល័យ នាយកអនុវិទ្យាល័យ នាយកបឋមសិក្សា គ្រូទទួលបន្ទុកកម្មវិធីប្រព័ន្ធរំឭកទុកជាមុន រួមទាំងតំណាងពាក់ព័ន្ធមកពីអង្គការ AEA, អង្គការ Oxfam និងក្រុមការងារ OEC ដើម្បីយកទៅអនុវត្ត តាមដាន និងវាយតម្លៃអំពីការសិក្សារបស់សិស្សនៅតាមសាលារៀនគោលដៅ។

លទ្ធផលពីវគ្គបណ្តុះបណ្តាលនេះ គ្រប់អ្នកចូលរួមដែលពាក់ព័ន្ធទាំងអស់បានឯកភាពគ្នាត្រួតពិនិត្យឡើងវិញនូវរបាយការណ៍ និងរៀបចំជាផែនការចុះគាំទ្របន្តពង្រឹងសមត្ថភាពសម្រាប់ប្រើប្រាស់ប្រព័ន្ធរំឭកទុកជាមុនជាមួយសាលារៀនគោលដៅនានារបស់គម្រោង FOSTER ឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន៕




*កម្មវិធីប្រព័ន្ធរំឭកទុកជាមុន ជាកម្មវិធីមួយសម្រាប់ឱ្យគណៈគ្រប់គ្រងសាលារៀនជួយលុបបំបាត់សិស្សបោះបង់ការសិក្សាតាមសាលារៀន និងអាចជួយកុមារទាន់ពេល។*

អនុវិស័យទី ៤

# កម្មវិធីអប់រំបរិយាប័ន្ន

"ភាពចម្រុះ និងការអប់រំបរិយាប័ន្នផ្តល់តម្លៃដល់មនុស្សគ្រប់រូបមិនថាយើងមានភាពខុសគ្នាយ៉ាងណាក៏ដោយ"។

# Inclusive Education

*Diversity and Inclusion are about giving value to every human being, no matter our differences.*



# ការគាំទ្រដល់កុមារងាយរងគ្រោះបានលើកទឹកសិស្សក្នុងការសិក្សា




សែម ថុង អាយុ១៦ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី៦ នៅសាលាបឋមសិក្សា ជុំគ្រៀល។ ថុងជាក្មេងកំព្រាដោយសារឪពុកម្ដាយបានលះលែងគ្នាតាំងពីគាត់មានអាយុជាង១ខួបម្លេះ។ បច្ចុប្បន្ននេះ គាត់រស់នៅជាមួយជីដូនជីតាដែលជាកសិករក្រីក្រ ក្នុងឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត។ ថុងមានការលំបាកខ្លាំងក្នុងការធ្វើដំណើរទៅសាលារៀនដែលមានចម្ងាយប្រមាណជាង៣គីឡូម៉ែត្រ ផ្លូវលំបត់បែន និងមិនសូវមានសុវត្ថិភាពថ្មើជើងទេ។ ជីតាបានជូនគាត់ទៅសាលារៀនពេលខ្លះទៅជាមួយមិត្តភក្រ ឬថ្មើជើង។ ជីតាគ្មានលទ្ធភាពទិញកង់ឱ្យចៅជិះទៅរៀនទេ ដែលជាហេតុធ្វើឱ្យថុងឧស្សាហ៍អវត្តមាន និងទៅសាលារៀនយឺតច្រើនដង។

នៅមុនពេលគម្រោងមិនទាន់ផ្តល់អាហារូបករណ៍ជាកង់ ថុងទៅសាលារៀនយឺតត្រូវដើរកាត់ភ្លឺស្រែ មិនទៀងទាត់ ហើយជីវភាពគ្រួសារក្រលំបាក។ ក្រៅពីធ្វើស្រូវស្រែរួច ជីតាគាត់បានទៅធ្វើកម្មករប្រមូលអំបិលឱ្យគេ រីឯយាយជាមេផ្ទះ និងមិនអាចដើរឆ្ងាយបាន។ ដោយសារចំណូលតិចតួចស្តួចស្តើងពេក ជីតាគ្មានលទ្ធភាពផ្គត់ផ្គង់ឱ្យចៅទៅរៀនបានគ្រប់គ្រាន់នោះទេ។ ថុងរៀនខ្សោយផ្នែកភាសាខ្មែរជាងគេ និងជាប់ចំណាត់ថ្នាក់លេខ២០ ចំណែកមុខវិជ្ជាផ្សេងៗក៏មិនសូវពូកែ។ ថុងបានខកខានមកសាលារៀនញឹកញាប់ ពេលខ្លះមិនចង់មកសាលារៀនទៀតផង ដោយសារការលំបាកនៅក្នុងគ្រួសារ។ ថុងរស់នៅជាមួយជីតាប្រៀបដូចជាឪពុកម្តាយរបស់គាត់បង្កើត។

ក្រោយពេលថុងទទួលបានអាហារូបករណ៍ជាកង់ពីគម្រោង COSAVED នៅឆ្នាំ២០២២ ការសិក្សារបស់ថុងមានភាពល្អប្រសើរឡើងវិញ មករៀនទៀងទាត់ លទ្ធផលសិក្សាកើនឡើង រីឯចំណាត់ថ្នាក់បានហក់មកជាប់លេខ១៦។ ថុងមានការសប្បាយចិត្តយ៉ាងខ្លាំងដោយសារបានកង់ធ្វើជាមធ្យោយងាយស្រួល និងចំណាយតិចជាងមុនដើម្បីទៅសាលារៀន ជាពិសេសទទួលបានការលើកទឹកចិត្តពីគម្រោង។ ថុងបាននិយាយថា **“វាប្លែកជាងមុន ខ្ញុំឃើញសាលាជួសជុលដាក់កម្រាលបេតុង រៀបចំបណ្ណាល័យ មានគ្រូចុះដល់ផ្ទះខ្ញុំ។ ឥឡូវនេះ ខ្ញុំមានកង់ជិះមកសាលាងាយស្រួល ខ្ញុំឈប់ដើរកាត់ភ្លឺស្រែទៅសាលារៀនដូចមុនទៀតហើយ។ ខ្ញុំសប្បាយចិត្ត ហើយនឹងខិតរៀនសូត្រ។ នៅថ្ងៃអនាគត ខ្ញុំចង់ក្លាយទៅជានគរបាល”**។

លោកតារបស់ថុងបានមានប្រសាសន៍ថា **“លទ្ធផលសិក្សាពីមុនបានតែ៤០%ទេ ប៉ុន្តែឥឡូវនេះបានកើនឡើងជាង៨០%។ ខ្ញុំក៏សប្បាយរីករាយដោយសារគម្រោងបានផ្តល់កង់ដល់ចៅខ្ញុំ ហើយបានជួយសម្រួលបន្ទុករបស់ខ្ញុំមួយផ្នែក។ ខ្ញុំបានក្រើនរំលឹកដាស់តឿនចៅមើលមេរៀន និងធ្វើលំហាត់បន្ថែមនៅផ្ទះពេលទំនេរ ”**។

**សូមអានបន្តទំព័រ២៩**



*ថុងកំពុងមើលគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យាយ៉ាងយកចិត្តទុកដាក់ ខណៈដែលមិត្តភក្រផ្សេងៗក៏កំពុងផ្ចង់អារម្មណ៍មើលការពន្យល់លោកគ្រូ នៅថ្នាក់ទី៦ នៃសាលាបឋមសិក្សា និងអនុវិទ្យាល័យ ហ៊ុន សែន ម៉ារីកូ ជុំគ្រៀល។*

**តទំព័រ២៨** គ្រូបន្ទុកថ្នាក់ និងលោកនាយកតែងតែជួយជំរុញលើកទឹកចិត្តឱ្យថុងខិតខំប្រឹងប្រែងរៀនសូត្រកាន់តែប្រសើរឡើង។ លោក ឈឹម ធីវ ជានាយកសាលាបឋមសិក្សា-អនុវិទ្យាល័យ ហ៊ុហ៊ុន សែន ម៉ារីកូ ជុំគ្រៀល បានមានប្រសាសន៍ថា **"បច្ចុប្បន្ននេះថុងបានមកសាលារៀនទៀងទាត់ពេលវេលាឡើងវិញ មិនអវត្តមានដូចមុន លទ្ធផលសិក្សាកើនឡើង។ ថុងមានការសប្បាយចិត្តច្រើន ព្រោះគាត់លែងពិបាកធ្វើដំណើរមកសាលារៀនដូចមុនទៀតហើយ "។**

គម្រោងCOSAVEDត្រូវបានប្រតិបត្តិដោយអង្គការ ខេប ដោយសហការជាមួយអង្គការ AeA ក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប/Educate a Child។ គម្រោង COSAVED បានផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀន នាយកសាលា បណ្ណារក្ស ការប្រជុំឪពុកម្តាយ គណៈកម្មការគ្រប់គ្រងសាលារៀន ប្រព័ន្ធរំលឹកទុកជាមុន សម្ភារអាហារូបករណ៍ ជួសជុលអគារសិក្សា បណ្ណាល័យ ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់សាលាមត្តេយ្យសហគមន៍ ជួសជុលនិងកសាងបង្គន់អនាម័យ ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំសម្រាប់សិស្សកូនអ្នកនេសាទនៅក្នុងគម្រោង ដោយធ្វើសកម្មភាពសំខាន់ៗបង្កើនការចុះឈ្មោះចូលរៀន និងពង្រឹងគុណភាពសិក្សារបស់កុមារថ្នាក់បឋមសិក្សានៅក្នុងតំបន់ និងបង្កើនការចុះឈ្មោះចូលរៀន និងពង្រឹងគុណភាពសិក្សាសម្រាប់សិស្សអនុវិទ្យាល័យនៅក្នុងតំបន់គម្រោង CO-SAVED។ ទោះបីរស់នៅជាកុមារកំព្រាឪពុកម្តាយក៏ដោយ តែថុងមានការព្យាយាមតស៊ូខិតខំប្រឹងប្រែងរៀនសូត្រ ត្រូវការជំនួយស្មារតី សម្ភារៈសិក្សា និងមធ្យោបាយសម្រាប់ធ្វើដំណើរទៅសាលារៀន៕



*នេះគឺជាទិដ្ឋភាពផ្ទះរបស់ជីដូនជីតាដែលថុងកំពុងរស់នៅជាមួយ ដែលស្ថិតនៅក្នុងឃុំជំគ្រៀល ស្រុកឈូក ខេត្តកំពត។*

# ការផ្ទេរភារកិច្ចទទួលខុសត្រូវនៃការប្រតិបត្តិគម្រោងទៅដៃគូពាក់ព័ន្ធ




គណៈអធិបតី អាជ្ញាធរមូលដ្ឋាន មេឃុំ អង្គការដៃគូ លោកគ្រូអ្នកគ្រូ សហការយ៉ាងល្អជាមួយគម្រោងក្នុងដំណើរការអភិវឌ្ឍសាលារៀននិងបន្តអនុវត្តសកម្មភាពពីគម្រោង។

ការរៀបចំកម្មវិធីសិក្ខាសាលាឆ្លុះបញ្ចាំង និងការផ្ទេរភារកិច្ចទទួលខុសត្រូវនៃការប្រតិបត្តិគម្រោងទៅដៃគូពាក់ព័ន្ធធ្វើបន្តគឺជាការក្សាបាននូវនិរន្តរភាពសកម្មភាពគម្រោងក្នុងការជួយអភិវឌ្ឍការអប់រំកុមារនៅកម្ពុជាឱ្យនៅតែដំណើរការល្អ។ គម្រោងងាយស្រួលរៀន ឬហៅកាត់ថា E2L ដែលបានប្រតិបត្តិដោយអង្គការ ខេប ចាប់តាំងពីខែកក្កដា ឆ្នាំ២០២១មក បានធ្វើឱ្យសាលារៀនគោលដៅទាំង១១នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង មានការរីកចម្រើនទាំងឥរិយាបទសហគមន៍ និងអាជ្ញាធរមូលដ្ឋានចូលរួមការងារសាលារៀន។ គម្រោងនេះបានផ្លាស់ប្តូរទម្លាប់បង្រៀនរបស់គ្រូ ការគ្រប់គ្រងសាលារៀនរបស់នាយក/នាយិកា បណ្ណារក្ស ហេដ្ឋារចនាសម្ព័ន្ធ សម្ភាររៀន និងបង្រៀន ការរៀបចំថ្នាក់រៀន ការជួយកុមារពិការ កម្មវិធីប្រឹក្សាកុមារី កម្មវិធីអាហារូបករណ៍ កម្មវិធីបំណិនជីវិត ការកៀរគររកប្រភពថវិកាអភិវឌ្ឍន៍សាលា កិច្ចសហការរវាងគណៈកម្មការគ្រប់គ្រងសាលារៀន និងឪពុកម្តាយសិស្ស ជាពិសេសគម្រោងបានផ្តល់នូវវគ្គបណ្តុះបណ្តាលសមត្ថភាពដល់ក្រុមគោលដៅទាំងអស់។

លោក **វ៉ែន ប្រណី** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែងបានមានប្រសាសន៍ថា **"ពេលវេលាថ្លៃជាងមាសប្រាក់ បើចាយអស់ហើយ មិនអាចរកមកវិញបានទេ ប៉ុន្តែមាសប្រាក់ លុយកាក់ ចាយអស់ហើយ យើងអាចរកមកវិញបាន។ យើងមិនភ្លេចទេចំពោះការចំណាយពេលវេលាចំនួន៣ឆ្នាំរបស់អង្គការឆាលហ្វាន កម្ពុជា និងអង្គការ ខេប ដែលបានជួយដល់សាលាគោលដៅទាំង១១ឱ្យមានដំណើរការលឿនជាងសាលាដទៃ"។**

ការធ្វើឱ្យប្រសើរឡើងនូវការចូលប្រើប្រាស់ និងរក្សាទុកកុមារី និងកុមារដែលមានអាយុចូលសាលាបឋមសិក្សាដែលមាន និងគ្មានពិការភាពនៅក្នុងសាលាគោលដៅ ដោយបានជួយគូសផែនទីសាលារៀន យុទ្ធនាការចុះឈ្មោះ និងកំណត់អាយុកុមារចូលរៀន ការឧបត្ថម្ភលើតម្រូវការកុមារងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងពិការ ការផ្តល់សេវាអប់រំដល់កុមារនៅក្នុងភូមិជាប់សាលារៀន អំឡុងពេលរាតត្បាតពីជំងឺកូវីដ-១៩ ជាសកល។ ការកែលម្អបរិស្ថានសាលារៀន ការបង្រៀន និងរៀនស្របតាមគោលនយោបាយសាលាកុមារមេត្រី បរិយាកាសសិក្សាក្នុងថ្នាក់រៀន ការលើកកម្ពស់ទម្លាប់អានតាមរយៈការបង្កើតបណ្ណាល័យជាកន្លែងសិក្សាបែបបត់បែន ការបណ្តុះបណ្តាលផ្នែក ICT ពង្រឹងប្រព័ន្ធក្នុងសាលាដើម្បីដោះស្រាយបញ្ហាសិស្សរៀនខ្សោយ និងការធ្វើតេស្តវាយតម្លៃជាប្រចាំ។

**សូមអានបន្តទំព័រ៣១**



ក្រុមប្រឹក្សាកុមារធ្វើបទបង្ហាញអំពីផែនការអភិវឌ្ឍន៍សាលារៀនរបស់ពួកគាត់ទៅកាន់មិត្តបន្ទាប់ពីពិភាក្សាជាមួយសមាជិកក្រុម។



សិក្ខាកាមទាំងអស់ត្រូវបានអញ្ជើញចាប់ក្រុមពិភាក្សាដើម្បីបង្កើតផែនការសកម្មភាពសម្រាប់ធ្វើបទបង្ហាញក្នុងសិក្ខាសាលា។

**តពីទំព័រ៣០** ការពង្រឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន ដើម្បីធានាបាននូវគណនេយ្យភាព ភាពជាម្ចាស់ និងការឆ្លើយតបយេនឌ័រ ជាពិសេសការពង្រឹងសមត្ថភាពគណៈកម្មការគ្រប់គ្រងសាលាសម្រាប់ធ្វើផែនការកែលម្អសាលរៀន។

លោក **សៅ វណ្ណា** នាយកប្រតិបត្តិ អង្គការ ខេប បានមានប្រសាសន៍ថា **"ក្រោយពេលប្រតិបត្តិគម្រោងងាយស្រួលរៀនអស់រយៈពេល៣ឆ្នាំនៅសាលារៀនគោលដៅចំនួន១១ក្នុងស្រុកកំពង់ត្របែកកន្លងមកនេះ យើងមានមោទនភាពដោយសារយើងបានធ្វើដំណើរជាមួយគ្នាតាំងពីឆ្នាំទី១រហូតដល់ឆ្នាំទី៣នេះ ជាពិសេសជាមួយលោកគ្រូអ្នកគ្រូ លោកអ៊ុំ ពូ បងទាំងអស់នៅក្នុងស្រុកកំពង់ត្របែកនេះ។ យើងពិនិត្យឃើញថាជាសមិទ្ធិផលដែលយើងពេញចិត្តក្រោយពេលអនុវត្តដោយមានការចូលរួមគាំទ្រទាំងអស់គ្នា។ ខ្ញុំសូមស្នើដ៏ទទូចថា យើងទាំងអស់គ្នាគួរតែប្រឹងប្រែង រួបរួមគ្នា ក្នុងនាមជាម្ចាស់ផ្ទះម្ចាស់ប្រទេស ដើម្បីស្វែងរកថវិកាពីប្រភពផ្សេងៗសម្រាប់បន្តសកម្មភាពគម្រោងងាយស្រួលរៀន ក្រោយពីអង្គការឆាលហ្វាន កម្ពុជា បញ្ចប់ការគាំទ្រថវិកាចាប់ពីខែកក្កដា ឆ្នាំ ២០២៣នេះទៅ"។**

ទាំងនេះតម្រូវឱ្យមានការរៀបចំកម្មវិធីសិក្ខាសាលាជួបជុំគ្នាដើម្បីជូនដំណឹង និងចែករំលែកផលប៉ះពាល់នៃគម្រោងការវិនិ-យោគ ការអនុវត្តល្អបំផុត សមិទ្ធិផល មេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនៃគម្រោងទៅកាន់ភាគីពាក់ព័ន្ធដូចជា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រុមប្រឹក្សាកុមារ គណៈកម្មការគ្រប់គ្រងសាលា នាយក/នាយិកាសាលា គ្រូបង្រៀន នាយករងសាលា គ្រូបង្វឹកអក្ខរកម្ម ក្រុមប្រឹក្សាឃុំ និងតំណាងសហគមន៍។ ម្យ៉ាងវិញទៀត សិក្ខាសាលានេះបានប្រមូលគំនិតយោបល់ពីអ្នកចូលរួមលើផ្នែកដែលនៅតែត្រូវការការគាំទ្របន្ថែម ដើម្បីធានានិរន្តរភាពសម្រាប់ប្រើប្រាស់ផែនការយុទ្ធសាស្ត្ររបស់អង្គការ ខេប បន្ទាប់ពីគម្រោងបញ្ចប់។



តំណាងសាលារៀនគោលដៅបានធ្វើបទបង្ហាញអំពីផែនការអភិវឌ្ឍន៍សាលាបន្ទាប់ពីគម្រោងនឹងបញ្ចប់។

លោក **ប្រាស្សាន វើម៉ា** នាយកប្រចាំប្រទេស អង្គការឆាលហ្វាន កម្ពុជាបានមានប្រសាសន៍ថា **"ក្រោយពេលចាប់ដៃគូជាមួយអង្គការ ខេប កន្លងមក យើងផ្ទេរគម្រោងនេះជាមួយសមិទ្ធិផលជាច្រើនទៅឱ្យសាលា អង្គការ ខេប ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត ដើម្បីបន្តកែលម្អគុណភាព និងការសិក្សាតាមរយៈគម្រោងងាយស្រួលរៀន និងចម្លងភាពជោគជ័យដែលទទួលបានទៅសាលារៀនផ្សេងៗទៀត ដើម្បីពង្រីកភាពជោគជ័យនេះឱ្យបានច្រើន។ ទាំងនេះជាហេតុដែលយើងហៅសិក្ខាសាលានៅថ្ងៃនេះថាជាសិក្ខាសាលាផ្ទេរទៅសាលា មន្ទីរ និងសហគមន៍មូលដ្ឋាន។ អង្គការឆាលហ្វាន កម្ពុជា ក្នុងនាមជាអង្គការអន្តរជាតិមិនមានចេតនានៅមួយកន្លែងយូរទេ ឬមិនមានប្តូរតំបន់គោលដៅរបស់ខ្លួនឡើង"។**

លោក **សូ សុវណ្ណា** ប្រធានការិយាល័យអប់រំស្រុកកំពង់ត្របែក បានមានប្រសាសន៍ថា **"ខ្ញុំសូមកោតសរសើរ និងសូមថ្លែងអំណរគុណនិងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការឆាលហ្វាន កម្ពុជា ក៏ដូចជាអង្គការ ខេប ដែលបានយកចិត្តទុកដាក់ចាប់**

**សូមអានបន្តទំព័រ៣២**




លោកស្រីមេឃុំបានឆ្លើយតបនឹងសំណូមពរពីសាលារៀនថានឹងជួយគាំទ្រថវិកាចំនួន៦០០០០រៀលក្នុងមួយខែសម្រាប់សាលានីមួយៗដើម្បីចូលរួមអភិវឌ្ឍ។

**តពីទំព័រ ៣១** យកស្រុកកំពង់ត្របែករបស់យើងជាដៃគូសហការអភិវឌ្ឍន៍សាលារៀនឱ្យទៅជាសាលាគំរូទៅថ្ងៃអនាគត។ នៅក្នុងស្រុកកំពង់ត្របែកមានវិទ្យាល័យចំនួន៤ អនុវិទ្យាល័យចំនួន១៥ សាលាបឋមសិក្សាចំនួន៥៨រួម សាលាបឋមសិក្សាខ្មែរអ៊ីស្លាមចំនួន១ សាលាមត្តេយ្យរដ្ឋចំនួន៤៦ មត្តេយ្យជាប់ចំនួន៤សាលា និងសាលាមត្តេយ្យសហគមន៍ចំនួន៤៦។ ចាប់តាំងពីខែមិថុនា ឆ្នាំ២០២០មកដល់ពេលនេះ គម្រោងងាយស្រួលរៀនបានជួយជាអគារសិក្សា បណ្ណាល័យនិងសម្ភារបណ្ណាល័យ ថាប់ប្លែត ទូរទស្សន៍ឆ្លាតវៃ ទូរដាក់សម្ភារកុំព្យូទ័រ LCD បង្គន់អនាម័យ ធុងចម្រុះទឹកស្អាត កន្លែងលាងដៃអាកុល ទូរបាញ់អាកុល កន្លែងនោមសម្រាប់កុមារ៉ា និងសម្ភារៈជាច្រើនទៀត។ អង្គការ ខេប បានជួយបង្រៀនផលិតសម្ភារបង្រៀន កែលម្អបរិស្ថាន បណ្តុះបណ្តាលដល់លោកនាយក/នាយិកា លោកគ្រូអ្នកគ្រូ អ៊ុំៗជាគណៈ**កម្មការគ្រប់គ្រងសាលារៀននូវជំនាញទន់ និងជំនាញរឹងជាប្រចាំរៀងរាល់ខែ និងការបណ្តុះបណ្តាលផ្នែកបច្ចេកទេស "**។ អ្នកចូលរួមទាំងអស់ ព្រមទាំងតំណាងក្រុមប្រឹក្សាកុមារបានចូលរួមធ្វើការងារក្រុមតំណាងពីសាលាទាំង១១ ដើម្បីពិភាក្សាគ្នាអំពីបញ្ហាប្រឈម បទពិសោធន៍អនុវត្តក្នុងពេលកន្លងមក ប្រមូលគំនិតធ្វើផែនការសកម្មភាព និងលើកទិសដៅប្រតិបត្តិបន្តក្រោយគម្រោងបញ្ចប់អាណត្តិខ្លួននៅដំណាច់ខែមិថុនានេះ។

លោកស្រី **ប៊ុន សារ៉ាន** នាយិកាសាលាបឋមសិក្សាត្នោតកាងបានមានប្រសាសន៍ថា "**គម្រោង E2L បានជួយច្រើនផ្នែកដល់សាលានាងខ្ញុំឱ្យបានរីកចម្រើន រួមមាន៖ ការគាំទ្រកុមារងាយរងគ្រោះ និងកុមារពិការ បណ្តុះបណ្តាគ្រូអក្ខរកម្មថ្នាក់ដំបូង រៀបចំបរិស្ថានថ្នាក់រៀន និងបរិស្ថានសិក្សាទូទៅ ការការពារកុមារ សុខភាពរបស់កុមារ វិធីធ្វើឱ្យមានការចូលរួមពីកុមារ ការចូលរួមរបស់មាតាបិតា និងសហគមន៍ ការកសាងសមត្ថភាពគណៈកម្មការគ្រប់គ្រងសាលា (SMC) និងការបណ្តុះបណ្តាលគ្រូ និងនាយសាលា។ សាលានាងខ្ញុំប្តេជ្ញាថានឹងខិតខំថែរក្សា ការពារ ឱ្យបានល្អប្រសើរនូវសមិទ្ធិផលនានាដែលគម្រោងបានជួយ។ បុគ្គលិកសាលាបឋមសិក្សាត្នោតកាងទាំងអស់នឹងយកចំណេះដឹង ជំនាញ បទពិសោធន៍ល្អៗ ដែលខាងគម្រោងផ្តល់ឱ្យ ទៅអនុវត្ត ផ្សព្វផ្សាយ ដល់សិស្ស មាតាបិតាសិស្ស និងសហគមន៍ "**។

សិក្ខាសាលាក្នុងរយៈពេល១ថ្ងៃកន្លះបានបង្ហាញឱ្យឃើញថា គម្រោងងាយស្រួលរៀនពិតជាបានជួយច្រើនដល់សាលារៀនគោលដៅទាំង១១ ជាពិសេសបានជួយបន្ថយបន្ទុកចំណាយថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡាក្នុងការដឹកនាំ និងអភិវឌ្ឍន៍សាលារៀននៅមូលដ្ឋានរបស់ខ្លួន។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងនៅសាលប្រជុំស្រុកកំពង់ត្របែក ខេត្តព្រៃវែង កាលពីថ្ងៃទី២៣ ដល់ ២៤ ខែឧសភា ឆ្នាំ២០២៣ ដោយមានអ្នកចូលរួមប្រមាណជា៧៥នាក់ ដែលជានាយក នាយិកា គណៈកម្មការគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ បណ្ណារក្ស ក្រុមប្រឹក្សាកុមារ អាជ្ញាស្រុក ប្រធានមន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា នាយកនិងបុគ្គលិកអង្គការ ខេប និងអង្គការឆាលហ្វាន កម្ពុជា ក្រុមប្រឹក្សាឃុំ មេឃុំ និងអភិបាលស្រុកកំពង់ត្របែក៕



តំណាងសាលារៀនគោលដៅបានទទួលលិខិតសរសើរក្នុងការអនុវត្តការងារដឹកនាំសាលារៀនបានល្អ និងថតរូបសិក្ខាកាមរួមគ្នាបន្ទាប់ពីសិក្ខាសាលាបិទបញ្ចប់។

# វគ្គបំប៉នដល់គ្រូមត្តេយ្យសិក្សារដ្ឋស្តីពីសៀវភៅសិក្សាគោល



សិស្សនៅអនុវិទ្យាល័យ បឹងព្រាវ បានទទួលកង់ពីគម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម។

គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED) ក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងសហប្រតិបត្តិដោយអង្គការ Aide et Action (AEA) អង្គការបណ្តុះកុមារ (BK) អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) និងអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) បានរៀបចំកម្មវិធីចែកសម្ភារអាហារូបករណ៍ដល់សិស្សក្រីក្រចំនួន២១៦នាក់ ដែលមកពីសាលារៀនគោលដៅចំនួន៧ ស្ថិតក្នុងស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣។

កម្មវិធីចែកសម្ភារអាហារូបករណ៍នេះមានគោលបំណងជួយសិស្សក្រីក្រមានមធ្យោបាយធ្វើដំណើរទៅសាលា និងមានសម្ភារសម្រាប់សិក្សា។ កម្មវិធីនេះក៏លើកកម្ពស់ការយល់ដឹងដល់ដៃគូអនុវត្តកម្មវិធីអន្តរាគមន៍ដោយសហការគ្នាក្រោមជំនួយរបស់គម្រោង CO-SAVED នៅតាមតំបន់ឆ្នេរសមុទ្រ ធ្វើយ៉ាងណាដើម្បីកាត់បន្ថយសិស្សបោះបង់ការសិក្សាក្នុងឆ្នាំសិក្សា ២០២៣នេះ។

លោកស្រី **ឃួក មុំ** ជាម្តាយរបស់សិស្សអាហារូបករណ៍ម្នាក់បានមានប្រសាស-ន៍ថា **"នាងខ្ញុំពិតជាសប្បាយចិត្ត ដោយសារអង្គការ ខេប បានផ្តល់ជាកង់ដល់កូនរបស់ខ្ញុំបានជិះទៅរៀន។ គ្រួសារនាងខ្ញុំមានការខ្វះខាតណាស់។ វាបានចូលរួមចំណែកកាត់បន្ថយបន្ទុកចំណាយគ្រួសារខ្ញុំ ហើយធ្វើឱ្យកូនខ្ញុំមានភាពងាយស្រួលធ្វើដំណើរទៅសាលារៀន"**។

កម្មវិធីនេះបានជំរុញឱ្យសិស្សក្រីក្រដែលទទួលបានសម្ភារអាហារូបករណ៍មានសេចក្តីសប្បាយរីករាយ និងប្តេជ្ញាចិត្តក្នុងការសិក្សាឱ្យកាន់តែប្រសើរឡើង។ សិស្សឈ្មោះ នី ដាលីន រៀនថ្នាក់ទី៨ បាននិយាយថា **"នាងខ្ញុំពិតជាសប្បាយចិត្តណាស់ដែលនាងខ្ញុំទទួលបានកាតាប ប៊ិច និងសៀវភៅ។ នាងខ្ញុំនឹងថែរក្សាសម្ភារទាំងនេះឱ្យបានល្អ និងបន្តទៅប្អូនខ្ញុំទៀត។ នាងខ្ញុំ សូមអរគុណចំពោះអង្គការ ខេប ដែលបានចែកជាសៀវភៅ ប៊ិច កាតាប និងសម្លៀកបំពាក់ដល់សិស្ស ហើយបានជួយបន្ថយការចំណាយថវិការបស់ខ្ញុំ។ នាងខ្ញុំនឹងប្តេជ្ញាខិតខំប្រឹងប្រែងរៀនសូត្រឱ្យបាននិទ្ទេសល្អ។ ទៅថ្ងៃអានាគត នាងខ្ញុំចង់ក្លាយទៅជាគ្រូបង្រៀនព្រោះខ្ញុំអាចជួយបង្រៀនក្មេងៗជំនាន់ក្រោយឱ្យយល់ដឹងអំពីវប្បធម៌ សាសនា និងចេះគោរពចាស់ទុំ ដោយសារជាចំណូលចិត្តខ្ញុំតាំងពីក្មេង"**។

នេះជាឆ្នាំទី៣ហើយដែលអង្គការ ខេប បានអនុវត្តគម្រោង COSAVED នៅសាលារៀនគោលដៅដោយបានសហការជាមួយមន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត/ស្រុក ក្នុងការចូលរួមអភិវឌ្ឍសមត្ថភាព និងពង្រឹងភាពដៃគូ ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន។ ជាពិសេសពង្រឹងនូវការផ្តល់សេវាអប់រំ និងការទទួលបានសេវាទឹកស្អាត និងអនាម័យ។

លោក **គឹម តាំងណុល** ជាអាណាព្យាបាលសិស្ស និងបានចូលរួមក្នុងកម្មវិធីនេះបានមានប្រាសាសន៍ថា **"ថ្ងៃនេះ ខ្ញុំបានជូនចៅមកទទួលសម្ភារអាហារូបករណ៍ជាកង់ដែលបានជួសម្រាលបន្ទុកសិស្សនៅទីនេះ ក៏ដូចជាចៅខ្ញុំ ដូចជា កង់ សៀវភៅ ប៊ិច និងសម្លៀកបំពាក់។ ខ្ញុំនឹងយកចិត្តទុកដាក់ពន្យល់ណែនាំឱ្យចៅខិតខំរៀន និងថែរក្សាកង់នេះឱ្យបានល្អ និងអាចឱ្យប្អូនៗជំនាន់បន្ទាប់ប្រើប្រាស់បានដែរ។ ខ្ញុំសូមអរគុណដល់អង្គការ ខេប និងលោកគ្រូអ្នកគ្រូដែលបានជួយបង្រៀនចៅខ្ញុំក្លាយជាសិស្សល្អ"**។

លោក **អ៊ា អ៊ាប** នាយកអនុវិទ្យាល័យ ដងពែង ដែលជាតំណាងទទួលកង់២០គ្រឿង កាតាប២៥ សៀវភៅ៣០០ក្បាល សម្លៀកបំពាក់២៥សម្រាប់ និងប៊ិច២៥០ដើម បានមានប្រសាសន៍ថា **"ខ្ញុំមានអារម្មណ៍រំភើបសប្បាយរីករាយ ដែលគម្រោងបានផ្តល់សម្ភារអាហារូបករណ៍នេះដល់សិស្សខ្ញុំ ទោះបីក្នុងចំនួនតិច ប៉ុន្តែវាបានចូលរួមជួយសម្រាលទុក្ខលំបាកដល់សិស្ស**

**សូមអានបន្តទំព័រ៣៤**

**គពីទំព័រ៣៣** ក្រីក្រឱ្យមានមធ្យោបាយសម្រាប់ជិះទៅសាលា និងមានសម្ភារៈសិក្សាគ្រប់គ្រាន់ដូចគេ។ ការផ្ដល់សម្ភារអាហារូបករណ៍ទាំងនេះជាមធ្យោបាយមួយទាក់ទាញសិស្សមកសាលារៀន និងជំរុញឪពុកម្ដាយមកសាលាជួបគ្រូនិងនាយកផងដែរ ”។

លោក **យឹម គឹមហ៊ាង** ជាមន្រ្តីតំណាងការិយាល័យអប់រំ យុវជន និងកីឡាស្រុកស្រែអំបិល បានមានប្រសាសន៍ថា “**ខ្ញុំមានមោទនភាពយ៉ាងខ្លាំងចំពោះអង្គការដៃគូទាំងពីរគឺៈ KAPE និង BSDA ដែលបានយកចិត្តទុកដាក់គាំទ្រចំពោះការជួយជំរុញដល់សាលារៀនលើវិស័យអប់រំ ដោយបានទម្លាក់កញ្ចប់សម្ភារអាហារូបករណ៍ ដូចជា កង់ សម្លៀកបំពាក់ សៀវភៅសរសេរ និងប៊ិចនៅតាមសាលារៀនគោលដៅ និងសាលាដទៃក្នុងដំណើរការកំពុងពង្រីកបន្ថែម ជាពិសេសការចំណាយពេលវេលារបស់ឪពុកម្ដាយចូលរួមជាមួយកូនៗទទួលកញ្ចប់សម្ភារៈ និងកង់** ”។

បើក្រឡេកមើលទិន្នន័យរបស់សាលារៀន វានៅតែបង្ហាញចំនួនសិស្សភាគច្រើនងាយទទួលរងគ្រោះដោយសារកត្តាផ្សេងៗគ្នា។ នៅក្នុងនោះ អង្គការ ខេប បានធ្វើការងារយ៉ាងខ្លាំងក្នុងការកសាងសមត្ថភាពគ្រូបង្រៀន និងកម្មវិធីអន្តរាគមន៍ដទៃទៀតដែលធ្វើឱ្យមានការទទួលស្គាល់ និងពេញចិត្តពីសាលាគោលដៅនីមួយៗ។ ទោះបីថវិកាមានកំណត់ក៏ដោយ ក៏ប្រជាជននៅមូលដ្ឋាន និងអង្គការដៃគូអភិវឌ្ឍដទៃទៀតបានលើកយកសកម្មភាពសាលារៀនជាអាទិភាពចម្បង។

លោក **ឡុច ភារុន** ជាមន្រ្តីតំណាងឱ្យមន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង បានលើកឡើងថា “**ក្នុងនាមតំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ស្រុក ខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងកោតសរសើរដល់អស់លោក លោកស្រី តំណាងការិយាល័យស្រុក លោកនាយក អង្គការដៃគូ ដែលបានសហការគ្នាយ៉ាងជិតស្និទ ធ្វើយ៉ាងណាឱ្យការអប់រំនៅក្នុងខេត្តរបស់យើងមានភាពល្អប្រសើរ និងគុណភាពស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងយុទ្ធសាស្រ្តបញ្ចកោណរបស់រាជរដ្ឋាភិបាល ដែលមានគោលដៅយុទ្ធសាស្រ្តធ្វើឱ្យមានកំណើនសេដ្ឋកិច្ចបង្កើតការងារឱ្យកាន់តែច្រើន ដោយសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ បន្តពង្រឹងសមត្ថភាព អភិបាលកិច្ច លើកកម្ពស់គុណភាពស្ថាប័ន រួមទាំងឱ្យមានគុណភាពការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ការអភិវឌ្ឍធនធានមនុស្សគឺជាបញ្ចកោណទី១ ដែលផ្ដោតលើកិច្ចការជាអទិភាពចំនួន៥ រួមមាន៖ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសលើការលើកកម្ពស់សុខភាព និងសុខមាលភាពប្រជាជន។ ទោះបីសម្ភារៈនេះមានចំនួនតិចក្ដី ប៉ុន្តែវាមានតម្លៃខ្លាំងណាស់ក្នុងការជួយសម្រួលការធ្វើដំណើរ ក៏ដូចជាការសិក្សារៀនសូត្រ** ”។

គម្រោង CO-SAVED បានអនុវត្តវិធីសាស្រ្តរួមជាមួយដៃគូធ្វើឱ្យសហគមន៍នេសាទនៅតាមតំបន់ឆ្នេរសមុទ្របង្កើតបាននូវចំណូលល្អប្រសើរឡើង។ អង្គការ ខេប បានចាប់ដៃគូជាមួយអង្គការ BSDA ដើម្បីបណ្ដុះបណ្ដាលលើកម្មវិធីអាហារូបករណ៍ និងតម្រូវការចាំបាច់ផ្សេងៗទៀត។ ការផ្ដល់កញ្ចប់អាហាររូបករណ៍ និងកង់ដល់សិស្សក្រីក្រពិតជាជះឥទ្ធិពលវិជ្ជមានដល់ការសិក្សា និងការចំណាយប្រចាំថ្ងៃ៕



លោក ផល សុវណ្ណធី មន្ត្រីជំនាញរបស់គម្រោង COSAVED បានប្រគល់កញ្ចប់អាហារូបករណ៍ដល់ក្រីក្រ។

អនុវិស័យទី ៥

# កម្មវិធីអំណានថ្នាក់ដំបូង

"នៅពេលអ្នករៀនអាន អ្នកនឹងមានសេរីភាពរហូត"។

# Early Grade Reading

*Once you learn to read, you will be forever free.*



# ហេតុអ្វីបានជាមានសិស្សរៀនយឺតនៅក្នុងសាលារៀន ?



ការផ្តល់សេវាអប់រំប្រកបដោយបរិយាបន្នធ្វើឱ្យសិស្សទទួលបានការអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅតាមសាលារៀនគោលដៅ។

សិស្សរៀនយឺត គឺជាបញ្ហាចម្បងដែលមាននៅក្នុងប្រព័ន្ធអប់រំ ជាពិសេសនៅថ្នាក់បឋមសិក្សាកំរិតទាបៗ ពីថ្នាក់ទី១ ដល់ថ្នាក់ទី៣។ ដើម្បីជួយកែលម្អគុណភាពអប់រំ និងបង្កភាពងាយស្រួលចូលសាលារៀនដល់កុមារនៅតំបន់ដាច់ស្រយាលក្នុងការឆ្លើយតបទៅនឹងគោលដៅអប់រំសម្រាប់ទាំងអស់គ្នា របស់រាជរដ្ឋាភិបាលកម្ពុជា អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា មានគម្រោងចំនួនប្រាំបីដូចជា គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED) គម្រោងងាយស្រួលរៀន (E2L-Kratie) គម្រោងពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា(EQUAL) គម្រោងសហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិចតំបន់១ (FOSTER) គម្រោងកុមារកម្ពុជារីករាយ (HCC) កម្មវិធីសាលារៀនជំនាន់ថ្មី (NGS) និងគម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH IV/BMZ)ដែលកំពុងអនុវត្តសកម្មភាពនៅក្នុងសាលារៀនគោលដៅសរុបចំនួន ១៨៧សាលា ស្ថិតនៅក្នុងខេត្តចំនួន ១២ខេត្ត រួមមាន៖ កំពង់ចាម សៀមរាប ត្បូងឃ្មុំ ក្រចេះ រតនគិរី ស្វាយរៀង កំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ កំពង់ឆ្នាំង បន្ទាយមានជ័យ និងបាត់ដំបង។

គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលដល់លោកគ្រូអ្នកគ្រូដើម្បីកសាងសមត្ថភាពបន្ថែមលើវិធីសាស្ត្របង្រៀន និងរៀនថ្មី បង្កើតសម្ភារៈជំនួយដល់ការបង្រៀន និងប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ។

ដើម្បីចូលរួមកាត់បន្ថយសិស្សរៀនយឺតក្នុងសាលារៀនគោលដៅ គម្រោងបានលើកកម្ពស់អក្ខរកម្មនៅថ្នាក់បឋមសិក្សាដោយប្រើគំរូនៃការអាន កញ្ចប់ឧបករណ៍សម្រាប់អាន កញ្ចប់ឯកសារបំប៉នបន្ថែម និងបច្ចេកវិទ្យាអប់រំ។ ទន្ទឹមនឹងនោះ គម្រោងក៏បានជួយគាំទ្រសកម្មភាពសិស្សធំជួយបង្រៀនសិស្សតូច បំប៉នសិស្សរៀនយឺត និងធ្វើការវាយតម្លៃអំណានថ្នាក់ដំបូងដើម្បីស្វែងយល់ពីលទ្ធផលសិក្សារបស់សិស្សបន្ទាប់ពីសាលារៀនទទួលបានការគាំទ្រសកម្មភាពពីគម្រោងផងដែរ។

អត្រាសិស្សរៀនត្រួតថ្នាក់ធ្លាក់ចុះនៅតាមសាលារៀនគោលដៅ វាជាផលជះវិជ្ជមានមួយរបស់គម្រោងដែលបានចូលរួមជួយអន្តរាគមន៍ និងគាំទ្រដល់សាលារៀនកន្លងមក៕



ការកាត់បន្ថយអត្រាត្រួតថ្នាក់នៅតាមសាលារៀនគោលដៅជាផលជះវិជ្ជមាន និងជាសមិទ្ធិផលដ៏ល្អក្នុងការអនុវត្តគម្រោង។

អនុវិស័យទី ៦

# កម្មវិធីមត្តេយ្យសិក្សា

“បង្កើនគំនិតមួយសម្រាប់កុមារមួយនាក់ក្នុងពេលតែមួយ”។

## Preschool Programming

*Enriching the mind one child at a time.*



# វគ្គបំប៉ន់ដល់គ្រូមត្តេយ្យសិក្សារដ្ឋស្តីពីសៀវភៅសិក្សាគោល



តំណាងសាលារៀនគោលដៅបានទទួលលិខិតសរសើរក្នុងការអនុវត្តការងារដឹកនាំសាលារៀនបានល្អ និងថតរូបសិក្ខាកាមរួមគ្នាបន្ទាប់ពីសិក្ខាសាលាបិទបញ្ចប់។

គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (BMZ/REACH IV) ជាគម្រោងមួយដែលបង្កើនការការពារកុមារ និងផលប៉ះពាល់នៃការសិក្សារបស់កុមារក្នុងវិស័យជាច្រើន រួមមាន៖ លេខ អក្សរសាស្ត្រ និងបំណិនជីវិតតាមរយៈយុទ្ធសាស្ត្ររួមបញ្ចូលគ្នាដែលលើកកម្ពស់អភិបាលកិច្ចដែលប្រសើរឡើង និងប្រកបដោយនិរន្តរភាព ព្រមទាំងបរិយាកាសសិក្សាដែលមានគុណភាពខ្ពស់ទាំងនៅក្នុងសាលា និងនៅផ្ទះ។

កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០២៣ គម្រោងBMZ/REACH IV បានរៀបចំវគ្គបំប៉ន់ដល់គ្រូមត្តេយ្យសិក្សារដ្ឋស្តីពីសៀវភៅសិក្សាគោលមុខវិជ្ជាសិក្សាសង្គម ដែលធ្វើឡើងនៅមន្ទីរអប់រំយុវជន និងកីឡាខេត្ត ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ២០នាក់ ជាស្រី មកពីសាលារៀនគោលដៅចំនួន១៤ ក្នុងខេត្តស្វាយរៀង។

វគ្គបំប៉ន់នេះ មានគោលបំណង៖ ១-ពង្រឹងសមត្ថភាពគ្រូមត្តេយ្យសិក្សារដ្ឋ ។ ២-បង្ហាញការបង្រៀន និងរៀនលើមុខវិជ្ជាសិក្សាសង្គម ថ្នាក់និទស្សន៍ ព្រមទាំងគំរូកិច្ចតែងការបង្រៀន។ ៣-រំលឹកឡើងវិញ មុខវិជ្ជាទាំង៥ ការរៀបចំជ្រុងសិក្សា និងតេស្តកុមារ៥ឆ្នាំ និង៤-រៀបចំផែនការបន្តសម្រាប់ការបង្រៀន និងរៀន។

ការកសាងសមត្ថភាពគ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលារៀនលើវិធីសាស្ត្របង្រៀនថ្មី បង្កើតសម្ភារៈជំនួយការបង្រៀន និងប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ ជាសកម្មភាពដ៏សំខាន់មួយរបស់គម្រោង។

គម្រោងកំពុងអនុវត្តន៍សកម្មភាពក្នុងខេត្តចំនួនបួន រួមមាន៖ ស្វាយរៀង ព្រៃវែង កំពង់ឆ្នាំង និងពោធិ៍សាត់។ ការអប់រំនៅមត្តេយ្យសិក្សាជាគ្រឹះយ៉ាងមាំមួនក្នុងការជួយកុមារដែលរៀនថ្នាក់ទី១ នៃបឋមសិក្សាឱ្យទទួលបានជោគជ័យ។ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចចិត្តការអប់រំទាំងអស់គ្នា និងគោលការណ៍អប់រំជាតិក្រសួង អប់រំ យុវជន និងកីឡាបានសហការជាមួយក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលក្នុងការកែលម្អគុណភាពអប់រំនៃការអភិវឌ្ឍកុមារតូច។

គម្រោងតែងតែបំប៉ន់សមត្ថភាពដល់គ្រូមត្តេយ្យសិក្សារដ្ឋពីវិធីសាស្ត្របង្រៀន ការគ្រប់គ្រងកុមារ បច្ចេកទេសគ្រប់គ្រងថ្នាក់រៀន និងចែករំលែកចំណេះដឹង ព្រមទាំងបទពិសោធន៍ដើម្បីបង្កលក្ខណៈសប្បាយរីករាយដល់កុមារក្នុងការសិក្សារៀនសូត្រ៕



កុមារជាទំពាំងស្នងឫស្សី តែកាលណាទំពាំងដុះពន្លកចេញពីកន្លែងល្អ នោះឫស្សីក៏ប្រែក្លាយទៅជាមានប្រយោជន៍ដែរ។

អនុវិស័យទី ៧

# រចនាបថហេដ្ឋារចនាសម្ព័ន្ធ

“ធ្វើឱ្យទម្រង់ការអប់រំស្របតាមតម្រូវការ និងដើរតួនាទីថ្មីៗ”។

## Infrastructure Design

*Making educational forms that follow new needs and functions.*



# ការធ្វើទំនើបកម្មបណ្ណាល័យក្នុងតំបន់ដាច់ស្រយាល



*បណ្ណាល័យទំនើបនៅសាលាបឋមសិក្សាប៉ក់ធំស្រុកអូយ៉ាដាវ ខេត្តរតនគីរី ។*



ការធ្វើទំនើបកម្មបណ្ណាល័យ ជាសូចនាករដ៏សំខាន់មួយនៃគម្រោងកុមារកម្ពុជារីករាយ(HCC) នៅតាមសាលារៀនគោលដៅចំនួន៤៣ ដែលគ្របដណ្តប់លើខេត្តចំនួន៥ រួមមាន៖ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ និងខេត្តរតនគិរី។ គម្រោងបានវិនិយោគយ៉ាងច្រើនក្នុងការធ្វើទំនើបកម្មបណ្ណាល័យដោយប្រើគំនិតរចនាបថចុងក្រោយបង្អស់ដើម្បីបង្កើនមុខងារបណ្ណាល័យ។ ម្យ៉ាងទៀត គម្រោងបានផ្តល់ថវិកាគ្រឿងសង្ហារិមល្អៗ សៀវភៅរឿងនិទានល្បែងសិក្សាជាច្រើនជាមួយបរិស្ថានប្រកបដោយផាសុកភាពដែលមានកន្លែងសម្រាប់អានសៀវភៅ។ ដើម្បីឱ្យបណ្ណាល័យដំណើរការទៅយ៉ាងសកម្ម គម្រោងក៏បានផ្តល់វគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពដល់បណ្ណារក្សដើម្បីទាក់ទាញសិស្សានុសិស្សអាណាព្យបាលសិស្សចូលក្នុងបណ្ណាយ។

លោក សំ រឿន នាយកសាលាបឋមសិក្សាប៉ក់ធំ បានថ្លែងអំណរអរគុណចំពោះគម្រោងកុមារកម្ពុជារីករាយ(HCC)របស់អង្គការ ខេប ដោយមានប្រសាសន៍ថា **"ការទទួលបានការអន្តរាមន៍ពីគម្រោងធ្វើឱ្យសាលារៀនមានការអភិវឌ្ឍ និងរីកចម្រើន ជាពិសេសគម្រោងបានជួយគាំទ្រក្នុងការបានកែលម្អបណ្ណាល័យឱ្យមានលក្ខណៈស្តង់ដាល្អប្រសើរថែមទាំងផ្តល់ជូននូវសម្ភារសិក្សា និងសៀវភៅរឿងបន្ថែមទៀតដាក់ក្នុងបណ្ណាល័យឱ្យមានលក្ខណៈសម្បូរបែបសម្រាប់សិស្សានុសិស្ស ហើយក៏សូមអរគុណចំពោះលោកគ្រូអ្នកគ្រូសប្បុរសជន និងសហគមន៍ ដែលបានចូលរួមសហការជាមួយសាលារៀនផងដែរ"។**

សិស្សានុសិស្ស មាតាបិតា អាណាព្យាបាលទាំងអស់ អាចធ្វើការខ្ចីសៀវភៅរឿងនិទាន និងល្បែងសិក្សាសម្រាប់បង្រៀនកូនៗនៅផ្ទះបាននៅតាមសាលរៀនគោលដៅរបស់គម្រោង៕

អនុវិស័យទី

# ៨

# ការអភិវឌ្ឍបណ្ណាល័យ

"បណ្ណាល័យសាលារៀនៈ ជាសោរសម្រាប់អតីតកាល និងជាទ្វារសម្រាប់អនាគត"។

# Library Development

*The School Library Key to the Past and Gateway to the Future.*



# ហេតុអ្វីបានបណ្ណាល័យមានតួនាទីសំខាន់ក្នុងសាលារៀន ?



លោក នួន វុទ្ធី នាយកសាលាបឋមសិក្សាឃុំកោះជីវាំង ដែលស្ថិតនៅឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

អង្គការ Aide et Action និងអង្គការដៃគូ (អង្គការ ខេប) បានបញ្ចប់ការបង្កើតបណ្ណាល័យ១សម្រាប់កុមាររស់នៅតំបន់ទឹកលិច (តាមរដូវ) នៅតំបន់ទន្លេសាប ស្ថិតនៅក្នុងសាលាបឋមសិក្សាឃុំកោះជីវាំង ដែលស្ថិតនៅក្នុងភូមិអន្លង់តាអួរ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី២១ ខែកញ្ញា ២០២៣។ ការបង្កើតបណ្ណាល័យនេះ ជាផ្នែកមួយដើម្បីលើកកម្ពស់អក្ខរកម្ម និងកសាងវប្បធម៌អាន និងរៀនក្នុងចំណោមក្មេងស្រី ក្មេងប្រុស និងមនុស្សពេញវ័យ។

លោក **នួន វុទ្ធី** នាយកសាលាបឋមសិក្សាឃុំកោះជីវាំង បានមានប្រសាសន៍ថា **“ពីដើមឡើយ សាលារៀននៅទីនេះ ជាសាលាបណ្តែតទឹក ប៉ុន្តែដោយសារតែមានការជួយគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា បានកែប្រែសាលាបណ្តែតទឹកទៅជាសាលារៀនមានសសរផុតពីទឹក។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយចិត្តដែលសាលារៀនទទួលបានការជួយគាំទ្រពីគម្រោង FOSTER ដែលមន្រ្តីគម្រោងតែងតែចុះមកដល់សាលារៀនផ្ទាល់ ជាពិសេសបានបង្កើតបណ្ណាល័យសម្រាប់សិស្សានុសិស្សនៅទីនេះ”។** លោកបន្តទៀតថា មុនបង្កើតបណ្ណាល័យ គម្រោងបានគាំទ្រសកម្មភាពបណ្ណាល័យចល័តដោយធ្វើដំណើរតាមទូក ឬកាណូតជាមួយកាលវិភាគច្បាស់លាស់ពីសាលារៀនមួយទៅសាលារៀនមួយទៀតដោយមានលោកគ្រូអ្នកគ្រូជាអ្នកដឹកជាប្រចាំខែ។ ប៉ុន្តែពេលនេះ ដោយមានការជួយគាំទ្រពីគម្រោង សាលារៀនរបស់ខ្ញុំមានបន្ទប់បណ្ណាល័យត្រឹមត្រូវសម្រាប់សិស្សក្នុងការសិក្សារៀនសូត្រ។ ខ្ញុំសង្ឃឹមថា សិស្សានុសិស្សទីនេះសប្បាយចិត្តដូចខ្ញុំដែរ ដោយសារពួកគាត់មានបន្ទប់សម្រាប់អានសៀវភៅ និងសម្ភារសិក្សា។

បណ្ណាល័យបានផ្សារភ្ជាប់ជាមួយផ្នែកអានដែលពាក់ព័ន្ធទៅនឹងការពង្រឹងផ្នែកអំណានដែលក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងដើម្បីធ្វើយ៉ាងណាឱ្យកុមារចេះអានបានតាំងពីកម្រិតដំបូង ចាប់ពីថ្នាក់ទី១ ដល់ ទី៦ទៅ។ ជាការពិតណាស់ ការមានបណ្ណាល័យនៅក្នុងសាលារៀន ជាកត្តាចម្បងសំខាន់មួយជួយជំរុញឱ្យសិស្សពង្រឹងជំនាញអាន។ បន្ទាប់ពីការអាននៅក្នុងថ្នាក់ សិស្សានុសិស្សអាចចូលក្នុងបណ្ណាល័យធ្វើការស្រាវជ្រាវ និងមើលឃើញសៀវភៅសម្រាប់អានជាច្រើន ហើយមានរូបភាពប្លែកៗដែលទាក់ទាញពួកគេឱ្យចង់ដឹងពីសៀវភៅនោះ។ ដូច្នេះ ភាពចង់ចេះចង់ដឹងក្នុងសៀវភៅជំរុញឱ្យសិស្សានុសិស្សបង្កើនការអានកាន់តែច្រើនឡើង។

បណ្ណាល័យ ជាកន្លែងផ្ទុកនូវចំណេះដឹងជាច្រើនសម្រាប់អ្នកសិក្សាស្រាវជ្រាវ។ បើសិស្សានុសិស្សផ្សារភ្ជាប់ខ្លួនឯងជាមួយនឹងបណ្ណាល័យ នឹងធ្វើឱ្យសិស្សរៀនកាន់តែពូកែ។ ជាទូទៅ សៀវភៅមួយក្បាលៗបានបង្កប់នូវគំនិតល្អៗជាច្រើន ដែលធ្វើឱ្យអ្នកអានកាន់តែមានគំនិតចាស់ទុំនិងជួយបង្កើនទម្លាប់ក្នុងការអានសៀវភៅ។ ដូច្នេះបណ្ណាល័យ ជាផ្នែកមួយនៃការជួយជំរុញការអានដល់សិស្សានុសិស្ស បណ្តុះទម្លាប់អាន និងលើកកម្ពស់វប្បធម៌អាន តាមរយៈការផ្តល់នូវធនធានឯកសារសម្បូរបែបនិងផ្សារភ្ជាប់ការសិក្សាពេញមួយជីវិត។

គម្រោងFOSTER មានគោលបំណងចង់ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងភាពធន់របស់សហគមន៍នេសាទនៅតំបន់ទន្លេសាប និងកាត់បន្ថយផលប៉ះពាល់បរិស្ថាននៅទីនេះ៕



កុមារី ចន្ធូ ណារី ថ្នាក់ទី៣ ខ បាននិយាយថា “ខ្ញុំសប្បាយចិត្តព្រោះមានសៀវភៅច្រើន ពួកយើងអាចចេះ”។

អនុវិស័យទី ៥

# កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព

"បំណិនជីវិតទទួលបានអត្ថប្រយោជន៍ពីការអប់រំសកម្មភាពគ្រូបង្រៀន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកម្មវិធីសិក្សាឌីណាមិក"។

## Life Skills Education & Career Counseling

*Life Skills benefit from proactive education, Qualified Instructors, Dynamic Curriculum.*













# ហេតុអ្វីសិស្សត្រូវយល់ដឹងអំពីការប្រើប្រាស់ធុងចម្រោះទឹកស្អាត ?



*គម្រោងFOSTER ជាគម្រោងមួយដែលមានគោលបំណងកែលម្អជីវភាពរស់នៅប្រកបដោយនិរន្តរភាព និងបង្កើនលទ្ធភាពទទួលបានសេវាសំខាន់ៗទឹកស្អាត អនាម័យ និងការអប់រំសម្រាប់សហគមន៍នេសាទនៅតំបន់បឹងទន្លេសាប។*

គម្រោងសហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបខាងលិច តំបន់១ ហៅកាត់ថា (FOSTER) សហការជាមួយគម្រោងដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា (CCOSC) បានរៀបចំផ្តល់ធុងចម្រោះ និងវគ្គតម្រង់ទិសស្តីពី បច្ចេកទេសប្រើប្រាស់ និងថែទាំនៃប្រព័ន្ធចម្រោះទឹកស្អាត ដែលធ្វើឡើងនៅសាលាបឋមសិក្សាវត្តស្ដី និងសាលាបឋមសិក្សាមុនប៉ែន ខេត្តសៀមរាប។ សិក្ខាកាមចូលរួមសរុបចំនួន៩០នាក់ រួមមាន៖ គណៈអភិបាលស្រុក ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា លោកគ្រូអ្នកគ្រូក្រុមប្រឹក្សាឃុំ មេភូមិ សិស្សានុសិស្ស និងអាណាព្យាបាល។

វគ្គតម្រង់ទិសនេះ ផ្តល់ឱ្យសិក្ខាកាមបានស្វែងយល់ពីសារៈសំខាន់នៃការទទួលទានទឹកដែលមានសុវត្ថិភាព និងការថែទាំប្រព័ន្ធចម្រោះទឹកស្អាត ជាពិសេសកុមារទាំងអស់នៅក្នុងសាលាគោលដៅមានទឹកស្អាត ទឹកសុវត្ថិភាពដើម្បីទទួលទាន។

ក្នុងសាលារៀននីមួយៗទទួលបានធុងចម្រោះទឹកស្អាតមានចំនួនផ្សេងគ្នារួមមាន៖ សាលាបឋមសិក្សាវត្តល្វា ទទួលបាន RO ចំនួនពីរ២, បឋមសិក្សាទួលទទួលបាន RO មួយ, បឋមសិក្សាតាផ្លុង ទទួលបានRO មួយ, បឋមសិក្សាកន្ទួ ROមួយ, បឋមសិក្សាវត្តឃ្លាំង RO មួយ, បឋមសិក្សាចុងប្រឡាយ RO មួយ, បឋមសិក្សាវត្តស្ដី RO មួយ, បឋមសិក្សាភ្នំក្រោមស្ទ័រុន RO ចំនួនបី, បឋមសិក្សាចុងឃ្នៀស RO មួយ, បឋមសិក្សាមេជ្រៃទទួលបាន Bravo ចំនួនពីរ, បឋមសិក្សាពោធិ៍ទ្រាយ ទទួលបានBravo ចំនួនបី, បឋមសិក្សាមុខប៉ែន ទទួលបានRO មួយ, បឋមសិក្សាគោកខ្ពស់ RO មួយ និងបឋមកំពង់ភ្លុក ទទួលបាន RO ចំនួនបី។ ដូច្នេះ ធុងចម្រោះទឹកស្អាតចំនួន ២១ ត្រូវបានប្រគល់ដល់សាលារៀនគោលដៅ។ សូមបញ្ជាក់ផងដែរថា RO ជាប្រភេទធុងចម្រោះដែលប្រើដោយប្រព័ន្ធអេឡិចត្រូនិក និង Bravo ជាប្រភេទធុងចម្រោះដែលមិនប្រើប្រព័ន្ធអេឡិចត្រូនិក នេះជាការចូលរួមចំណែកលើកកម្ពស់សុខភាពអនាម័យតាមសាលារៀន និងពង្រឹងការយល់ដឹងផ្នែកអនាម័យ ជាពិសេសការបរិភោគទឹកស្អាត និងទឹកមានសុវត្ថិភាពដល់សិស្សានុសិស្ស ក្រុមគ្រួសារ និងសហគមន៍ទាំងមូល។ ម្យ៉ាងវិញទៀត ការមានធុងទឹកចម្រោះស្អាត បានធ្វើឱ្យសាលារៀនសម្រេចបាននូវសូចនាករ ហើយទទួលបានផ្កាយតាមការវាយតម្លៃអនាម័យទឹកស្អាតរបស់ក្រសួងអប់រំ យុវជន និងកីឡា។

លោក កែវ វណ្ណនី ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុកពួក បានមានប្រសាសន៍ថា **"ការប្រើប្រាស់ទឹកស្អាត និងទឹកដែលមានសុវត្ថិភាព គឺមានសារៈសំខាន់ណាស់សម្រាប់ការរស់នៅប្រចាំថ្ងៃ ហើយរឹតតែសំខាន់នោះ គឺការបរិភោគទឹកដែលចម្រោះត្រឹមត្រូវ។ លោកគ្រូអ្នកគ្រូដែលទទួលបានធុងចម្រោះទឹកស្អាតពីគម្រោងសូមយកចិត្តទុកដាក់ថែរក្សា និងប្រើប្រាស់ឱ្យបានល្អ ដូច្នេះសិស្សានុសិស្សបាន ទទួលទានទឹកស្អាត មានអនាម័យ និងមានសុខភាពល្អ"។**

គម្រោង FOSTER ទទួលបានហិរញ្ញប្បទានពីសហភាពអឺរ៉ុប ដែលអនុវត្តសកម្មភាពក្នុងខេត្តចំនួន៣ រួមមាន៖ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវប្រសិទ្ធភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀន ដោយផ្អែកលើលទ្ធផលវាយតម្លៃទឹកស្អាត និងអនាម័យតាមសាលារៀន៕

# វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E.

គម្រោងអប់រំបំណិនជីវិតសំរាប់កុមារី (LSLAG) បានរៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលគ្រូបង្គោលកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E. ដើម្បីផ្ដល់នូវឱកាសដល់សិក្ខាកាមស្វែងយល់អំពីវិធីសាស្ត្របង្រៀន និងការប្រើប្រាស់សៀវភៅកម្មវិធីបំណិនជីវិត P.A.C.E. សកម្មភាពសិក្សាបែបសហការ និងវិធីសាស្ត្រសិក្សាតាមបែបចូលរួម ការអនុវត្តការបង្រៀនកម្មវិធីបំណិនជីវិត P.A.C.E. ជាក់ស្ដែង ការយល់ដឹងអំពីការប្រើប្រាស់ទម្រង់ត្រួតពិនិត្យ និងការវាយតម្លៃការបង្រៀនរបស់គ្រូ និងសិស្ស ការយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់គ្រូឧទ្ទេស និងការរៀបចំធ្វើផែនការបណ្ដុះបណ្ដាលកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E. បន្ត។



*កម្មវិធី P.A.C.E ផ្ដល់នូវចំណេះដឹង ជំនាញ និងសមត្ថភាពដែលលើកកម្ពស់លទ្ធភាពដល់កុមារីបានស្វែងយល់ពីការប្រែប្រួលរាងកាយ។*

កម្មវិធីបំណិនជីវិត Gap Inc. P.A.C.E. មានគោលបំណងដើម្បីធ្វើឱ្យដំណើរផ្លាស់ប្ដូរប្រកបទៅដោយសុខភាពនិងវិជ្ជមានទៅជាមនុស្សពេញវ័យខណៈពេលដែលទទួលស្គាល់និងដោះស្រាយភាពងាយរងគ្រោះផ្នែកយេនឌ័រ និងវិសមភាព។ ជំនឿស្នូលនិងសក្ដានុពលនៃកម្មវិធីសិក្សាគឺថាក្មេងស្រីអាចផ្លាស់ប្ដូរជីវិតរបស់ពួកគេផ្ទាល់ជាមួយនឹងជំនាញសំខាន់ៗដែលត្រូវបានផ្ដល់ឱ្យពួកគេនៅពេលដែលពួកគេមានវ័យជំទង់។

សិក្ខាសាលានេះរៀបចំឡើងកាលពីថ្ងៃទី២៥-២៩ ខែធ្នូ ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) នៃវិទ្យាស្ថានជាតិអប់រំ (NIE) រាជធានីភ្នំពេញ ក្រោមអធិបតីភាពដោយលោក នួន វណ្ណសឿន អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈនៃក្រសួងអប់រំ យុវជន និងកីឡា និងបណ្ដុះបណ្ដាលដោយលោកបណ្ឌិត ស៊ុន សុម៉ារ៉ា អ្នកសម្របសម្រួលការបណ្ដុះបណ្ដាលនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) និងលោក វ៉ា សុខលីន មន្ត្រីនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ (VOD) ក្រោមការជួយសម្របសម្រួលដោយលោកស្រី ហ៊ឹម ម៉ារី អ្នកសម្របសម្រួលកម្មវិធី នៃគម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី របស់អង្គការ ខេប និងលោកលោកស្រីដែលអញ្ជើញចូលរួមពីនាយកដ្ឋាននៃក្រសួងអប់រំ យុវជន និងកីឡា លោកលោកស្រី ក្រុមការងារគម្រោងមកពីមន្ទីរអប់រំ យុវជន និងកីឡា និងលោក លោកស្រីដែលជាគ្រូបង្រៀនបំណិនជីវិតមកពីសាលារៀនគោលដៅទាំង២៥រាជធានី-ខេត្ត។

គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារីត្រូវបានប្រតិបត្តិដោយក្រសួងអប់រំ យុវជននិងកីឡា និងអង្គការ ខេប៕



*ការអប់រំបំណិនជីវិត គឺជាផ្នែកមួយនៃគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សារបស់ក្រសួង អប់រំ យុវជន និងកីឡា ដែលនឹងត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់សិស្សដែលកំពុងរស់នៅក្នុងយុគសម័យសកលភាវូបនីយកម្ម។*

អនុវិស័យទី ១០

# កម្មវិធីឆ្លើយតបនឹងវិស័យអប់រំ ក្នុងបរិបទជំងឺកូវីដ-១៩

## Covid19 Response & Recovery Programming



# ព្រឹត្តិការណ៍ ចំណេះដឹង កំណាព្យ និងការសិក្សាស្រាវជ្រាវផ្សេងៗ

“ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន”។

# Events, Knowledge, Poems, and Other Researches

*Development through Networking and Outreach.*



# អបអរសាទរទិវាកុមារអន្តរជាតិ



ការអប់រំមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍ និងសុខុមាលភាពរបស់កុមារ។

ប្រទេសជាច្រើននៅលើសកលលោករួមទាំងប្រទេសកម្ពុជាផង បានប្រារព្ធទិវាកុមារអន្តរជាតិ នៅថ្ងៃទី០១ ខែមិថុនា ចាប់តាំងពីឆ្នាំ១៩៥០មក ដែលគេកំណត់ថាជាទិវាមួយសម្រាប់បំផុសស្មារតីដល់មនុស្សជាតិទាំងមូលឱ្យយកចិត្តទុកដាក់អំពីសុខមាលភាពកុមារ និងការសាមគ្គីជាអន្តរជាតិរបស់កុមារទាំងក្នុងជីវភាពរស់នៅ និងផ្នែកច្បាប់។ ទិវានេះរៀបចំឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់សិទ្ធិកុមារក្នុងមូលដ្ឋាន ផ្សព្វផ្សាយអំពីសិទ្ធិកុមារដល់សហគមន៍ ក្រុមគ្រួសារ អាណាព្យាបាល និងអាជ្ញាធរ។ ទិវានេះបានផ្តល់នូវចំណេះដឹងអំពីសិទ្ធិកុមារដល់អ្នកពាក់ព័ន្ធនានា ឱ្យសហការចូលរួមផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ និងការការពារកុមារពីការរំលោភបំពានគ្រប់ទម្រង់ និងផ្លាស់ប្តូរឥរិយាបថជាវិជ្ជមានស្តីពីការការពារកុមារ ក្នុងសហគមន៍ សាលារៀន និងគ្រួសារ។

គម្រោងសហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាប ភាគខាងលិច តំបន់១ ឬហៅកាត់ថា គម្រោង FOSTER បានប្រារព្ធទិវាកុមារអន្តរជាតិ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២៣ នៅសាលាបឋមសិក្សាវត្តកំពង់ភ្លុក ដែលជាសាលាមួយក្នុងចំណោមសាលាគោលដៅស្ថិតក្នុងស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ទិវានេះមានអ្នកចូលរួមចំនួនជាង៥០០នាក់ ដែលជាបុគ្គលិកគម្រោង FOSTER និងក្រុមការងារនៃអង្គការ Oxfam ប្រធានកម្មវិធីកុមារក្រៅសាលានៃអង្គការ Aide et Action និងក្រុមការងារ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប ប្រធានការិយាល័យបឋមសិក្សា អភិបាលនៃគណៈអភិបាលស្រុកប្រាសាទបាគង ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកប្រាសាទបាគង ប្រធានក្រុមប្រឹក្សាឃុំ និងមេឃុំកំពង់ភ្លុក ប្រធាន គ.ក.ន.ក មេភូមិទាំងបីក្នុងឃុំកំពង់ភ្លុក ឪពុកម្តាយ អាណាព្យាបាល សិស្សានុសិស្ស គណៈកម្មការគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូ។ទិវានេះបានរៀបចំជាកម្មវិធីសម្រាប់កុមារចូលរួមសូត្រកំណាព្យ ច្រៀងចម្រៀង ចាប់និងឆ្លើយសំណួរ និងការសម្តែងរឿងខ្លីរបស់កុមារស្តីពីហិង្សាក្នុងគ្រួសារ។ ទិវានេះបានផ្តល់ឱកាសដល់ឪពុកម្តាយបានឡើងបញ្ចេញមតិ និងប្តេជ្ញាចិត្តជំរុញកូនឱ្យមកសាលារៀនទៀងទាត់ពេល។ ម្យ៉ាងវិញទៀត កុមារមានការរំភើបរីករាយដោយកាន់ជាបដាសារអប់រំជាច្រើនផ្ទាំង ព្រមទាំងទទួលបានរង្វាន់លើកទឹកចិត្តសម្រាប់កុមារដែលឆ្លើយសំណួរត្រូវ និងការចែកសៀវភៅសរសេរដល់សិស្សចូលរួមទាំងអស់គ្នា។

ទិវានេះទទួលបានការឧបត្ថម្ភគាំទ្រហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងសហប្រតិបត្តិដោយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) អង្គការ Aide et Action អង្គការប្រតិបត្តិកុមារកម្ពុជា និងអង្គការ Oxfam៕



សាលារៀន អាជ្ញាធរ អាណាព្យាបាល និងមាតាបិតា មានកិច្ចទំនួលខុសត្រូវចម្បងដើម្បីធានាថាកុមារទាំងអស់មានសិទ្ធិទទួលបានការអប់រំ។

# ដំណើរទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយក្នុងសាលារៀននៅខេត្តក្រចេះ



លោក ប្រាស្សាន នាយកប្រចាំប្រទេសនៃអង្គការឆាលហ្វានកម្ពុជា  បានអញ្ជើញមកទស្សនានៅសាលាបឋមសិក្សាសង្គមខេត្តក្រចេះដែលជាសាលារៀនគោលដៅក្នុងគម្រោងE2L។

រយៈពេល២ឆ្នាំជាងមកនេះ គម្រោងងាយស្រួលរៀន(E2L) បានអនុវត្តសកម្មភាពរបស់ខ្លួននៅក្នុងបឋមសិក្សាចំនួន ៧ និងសាលាឧបសម្ព័ន្ធចំនួន២ដែលជាសាលារៀនគោលដៅរបស់គម្រោងដែលស្ថិតនៅក្នុងខេត្តក្រចេះ។ សាលារៀនទាំងនេះមានការផ្លាស់ប្តូរនូវមុខមាត់ថ្មីពីការអភិវឌ្ឍនូវធនធានអប់រំដែលបានទាក់ទាញម្ចាស់ជំនួយឱ្យមកទស្សនកិច្ចសិក្សា។ នេះបានបង្ហាញថាសកម្មភាពគម្រោងអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការជួយគាំទ្រលើផែនការអភិវឌ្ឍសាលារៀន។ សមិទ្ធផលរបស់គម្រោង បានបង្ហាញតាមរយៈផលសម្រេចបាននៃការអនុវត្តតាមសាលារៀនគោលដៅនីមួយៗ ដែលធ្វើឱ្យម្ចាស់ជំនួយចង់មកទស្សនា,ស្វែងយល់ និងរៀនពីបទពិសោធន៍ជាក់ស្តែង។

សាលាបឋមសិក្សាស្វាយចេក និងសាលាបឋមសិក្សាសណ្តាន់១ គឺជាសាលារៀនគោលដៅរបស់គម្រោងដែលទទួលរៀបចំដំណើរទស្សនកិច្ចសិក្សារបស់លោក ប្រាស្សាន វើម៉ា នាយកប្រចាំប្រទេសអង្គការឆាលហ្វាន កម្ពុជា និងអមដំណើរដោយប្រធានការិយាល័យអប់រំស្រុកសំបូរ គណៈកម្មការគ្រប់គ្រងសាលារៀន លោកនាយក លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ ម្ចាស់ជំនួយទទួលបានបទពិសោធន៍ និងរៀនសូត្រពីការអនុវត្តរបស់សាលារៀនពីការផ្លាស់ប្តូរជាវិជ្ជមាន និងបញ្ហាប្រឈមនានា។

បន្ទាប់ពីជួបសំណេះសំណាល ជាមួយនាយក លោកគ្រូអ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀន សិស្សានុសិស្ស អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងៗ គណៈប្រតិភូបានសិក្សារៀនសូត្រ ស្វែងយល់ពីដំណើរការអភិវឌ្ឍសាលារៀន ផលសម្រេចបានជាវិជ្ជមាន បញ្ហាប្រឈម និងពិនិត្យវឌ្ឍនភាពសាលារៀន។ ទន្ទឹមនឹងនោះលោកគ្រូអ្នកគ្រូក៏បានធ្វើបទបង្ហាញ និងឆ្លុះបញ្ចាំងពីវិធីសាស្ត្របង្រៀន ការបង្រៀន និងរៀន ការគ្រប់គ្រងបរិស្ថាន បរិស្ថានក្នុងថ្នាក់រៀន សកម្មភាពក្នុងបណ្ណាល័យ ការប្រើប្រាស់សៀវភៅ សកម្មភាពសិស្ស បញ្ជីខ្ទីសងសៀវភៅ និងស្វែងយល់ពីការចូលរួមរបស់សហគមន៍។ បន្ទាប់មក គណៈប្រតិភូបន្តទស្សនាជុំវិញ **សូមអានបន្តទំព័រ៥០**


បន្ទាប់ពីលោកបានស្តាប់ពីរបាយការណ៍ និងដើរទស្សនាក្នុងបរិវេណសាលារៀនរួចថតរូបភាពជុំគ្នា។

**តពីទំព័រ៤៩** ទីធ្លាសាលាសួនជីវៈចម្រុះ សាលាកុមារមេត្រី និងចូលរួមដាំឈើអនុស្សាវរីយ៍។



ម្ចាស់ជំនួយបានចូលទស្សនាក្នុងបណ្ណាល័យមើលពីសៀវភៅខ្ញីសងរបស់សិស្ស។

លោក **ប្រាសូវាន** បានបង្ហាញចំណាប់អារម្មណ៍ថា **"លោកពិតជាសប្បាយចិត្តដែលបានឃើញសមិទ្ធិផលថ្មីៗនៅក្នុងសាលារៀន បរិស្ថានស្អាត នាយកសាលាមានឆន្ទៈខ្ពស់ នេះដោយសារតែការខិតខំប្រឹងប្រែង និងមានការចូលរួមពីលោកគ្រូអ្នកគ្រូ គណៈគ្រប់គ្រងសាលារៀន និងសិស្សានុសិស្ស ព្រមទាំងមានការគាំទ្របច្ចេកទេស ពីមន្ត្រីអង្គការ ខេប"។**

គម្រោងងាយស្រួលរៀន ជាគម្រោងរួមបញ្ចូលគ្នាដែលមានវិធីសាស្ត្រចម្រុះពហុវិស័យក្នុងការអភិវឌ្ឍសាលារៀន ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំបឋមសិក្សាសម្រាប់កុមារទាំងអស់នៅស្រុកសំបូរ និងស្រុកអូរគ្រៀងសែនជ័យ ក្នុងទឹកដីខេត្តក្រចេះ។ គម្រោងបានផ្តល់ផលជះទៅកាន់សាលារៀនចំនួន៩ ដែលបានធ្វើ សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ នាយក គណៈគ្រប់គ្រងសាលារៀន និងអាណាព្យាបាលសិស្សមានមោនភាពចំពោះសាលារៀនក្នុងដំណើរការអភិវឌ្ឍសាលារៀន។

គម្រោងមានសកម្មភាពសំខាន់ៗ ចំនួន ៧ ដើម្បីជំរុញដំណើរការចូលរៀនរបស់កុមារគ្រប់អាយុបានចូលរៀន ទាំងពិការភាព និងគ្មានពិការភាពនៅក្នុងសាលារៀនគោលដៅទាំងអស់ឱ្យប្រសើរឡើង។ ម៉្យាងទៀត គម្រោងបានកែលម្អបរិស្ថានសាលារៀន ការបង្រៀន និងការរៀនស្របតាមគោលនយោបាយសាលាកុមារមេត្រី ជាពិសេស គម្រោងក៏បានកសាងសមត្ថភាពនាយក លោកគ្រូ អ្នកគ្រូពីការដឹកនាំ និងវិធីសាស្ត្របង្រៀនថ្មីៗផងដែរ។ គម្រោងបានពង្រឹងបន្ថែមលើភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀនដើម្បីធ្វើឱ្យមានគណនេយ្យភាព តម្លាភាព ភាពជាអ្នកម្ចាស់ការ និងយេនឌ័រ។

ដោយមើលឃើញពីសមិទ្ធផលសម្រេចបានជាច្រើនអំឡុងពេលទស្សនកិច្ចសិក្សា កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ គណៈប្រតិភូ និងគណៈគ្រប់គ្រងសាលារៀនបានបង្ហាញចំណាប់អាម្មរណ៍ចំពោះគ្នាទៅវិញទៅមកក្នុងការសិក្សារៀនសូត្រ បន្ទាប់ពីទទួលបានការអន្តរាគមន៍ពីគម្រោងក្នុងការគាំទ្រទាំងហិរញ្ញវត្ថុ និងបច្ចេកទេស ។ លទ្ធផលល្អៗទាំងអស់នេះនឹងនាំឱ្យសាលារៀនមានអភិវឌ្ឍបន្ថែមទៀត ទាំងពេលបច្ចុប្បន្ន និងអនាគត។ គម្រោងងាយស្រួលរៀន ប្រតិបត្តិដោយអង្គការខេប ទទួលបានហិរញ្ញប្បទានពីអង្គការឆ្វាលហាន់កូរ៉េ ចាប់តាំងពីឆ្នាំ២០២១៕



កុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ និងការលើកទឹកចិត្តឱ្យទៅសាលារៀន ដើម្បីរៀនបានខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន។

# កម្មវិធីផ្លាស់ប្តូរការសិក្សាពីសាលារៀនមួយទៅសាលារៀនក្នុងគម្រោង



លោកស្រី តុង បូតេ អនុប្រធានការិយាល័យអប់រំស្រុកបរកែវ បានអញ្ជើញចូលរួមកម្មវិធីផ្លាស់ប្តូរការសិក្សានៅសាលាបឋមសិក្សាឡុំ។

គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំទស្សនកិច្ចសិក្សាដល់លោកគ្រូអ្នកគ្រូទៅកាន់សាលាបឋមសិក្សាឡុំ ដើម្បីស្វែងយល់ពីបទពិសោធន៍របស់សាលារៀនគោលដៅរបស់គម្រោង។ ដំណើរទស្សនកិច្ចនេះ មានអ្នកចូលរួមសរុបចំនួន ៧៩ នាក់ រួមមាន៖ មន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក នាយក នាយិកា និងលោកគ្រូអ្នកគ្រូដែលមកពីសាលារៀនគោលដៅចំនួនដប់មួយក្នុងខេត្តរតនគិរី។

ដំណើរទស្សនកិច្ចនេះ ធ្វើឡើងនៅថ្ងៃទី១៦-១៧ ខែមិថុនា ឆ្នាំ២០២៣ ដើម្បីសិក្សារៀនសូត្រពីបទពិសោធន៍សាលារៀនដែលបានអនុវត្តកម្មវិធីសាលាកុមារមេត្រីល្អ ឆ្លើយតបនឹងគោលនយោបាយក្រសួងអប់រំ៖ ១)ការគ្រប់គ្រងសាលារៀន ២)ការចូលរួមរបស់សហគមន៍ ៣)ការរៀបចំថ្នាក់រៀន ៤)វិធីសាស្ត្របង្រៀន ៥)ការរៀបចំបរិស្ថានសាលារៀន ៦)បំណិនជីវិត ៧)ការដឹកនាំ និងដំណើរការក្រុមប្រឹក្សាកុមារ។

លោកស្រី **តុង បូតេ** អនុប្រធានការិយាល័យអប់រំស្រុកបរកែវ បានមានប្រសាសន៍ថា **"សូមកោតសរសើរចំពោះគម្រោងកុមារកម្ពុជារីករាយរបស់អង្គការ ខេប ដែលបានរៀបចំកម្មវិធីទស្សនកិច្ចសិក្សានេះឡើង វាពិតជាមានសារសំខាន់ណាស់ ពីព្រោះយើងបានស្វែងយល់នូវអ្វីដែលថ្មីៗ និងបានចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក រួមទាំងគន្លឹះអភិវឌ្ឍន៍សាលារៀន។ មិនតែប៉ុណ្ណោះ អ្នកចូលរួមបានឃើញដោយផ្ទាល់ពីភាពជោគជ័យ ដើម្បីធ្វើការកែលម្អនូវចំណុចខ្វះខាតខ្លួនឯងបន្ថែមទៀត និងសង្ឃឹមថាសកម្មភាពនេះ នៅតែមានជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ"។**

តាមរយៈដំណើរទស្សនកិច្ចសិក្សានេះ បានផ្តល់ឱកាសឱ្យអ្នកចូលរួមបានរៀនសូត្រអ្វីដែលថ្មីៗ និងទទួលបានចំណេះដឹង និងបទពិសោធន៍ល្អៗដោយមើលឃើញផ្ទាល់ គឺប្រសើរជាងការរៀនពីសៀវភៅ ឬតាមរយៈការចែករំលែក ហើយវានឹងជួយបណ្តុះគំនិតល្អៗដល់អ្នកចូលរួមដើម្បីកែលម្អពីវិធីសាស្ត្របង្រៀន និងរៀនរបស់ខ្លួន ឱ្យមានភាពល្អប្រសើរឡើងនៅក្នុងថ្នាក់រៀនជាក់ស្តែង។

គម្រោងកុមារកម្ពុជារីករាយ ទទួលហិរញ្ញប្បទានពីមូលនិធិគីនធាន់ ដើម្បីកែលម្អសមត្ថភាពគ្រប់គ្រងដៃគូនៅមូលដ្ឋាន បង្កើនលទ្ធភាពទទួលបានសេវាអប់រំ និងគុណភាពបង្រៀន និងរៀន ក៏ដូចជាការផ្សព្វផ្សាយនៅតាមសហគមន៍៕



លោកគ្រូអ្នកគ្រូទទួលបានចំណេះដឹង និងបទពិសោធន៍ល្អៗបន្ថែមថែមពីវិធីសាស្ត្របង្រៀន និងរៀនដើម្បីឱ្យកុមារទទួលបានការអប់រំប្រកបដោយប្រសិទ្ធភាព។

# កម្មវិធីផ្លាស់ប្តូរការសិក្សាពីសាលារៀនមួយទៅសាលារៀនក្នុងគម្រោង



សម្រាប់សិស្សដែលរស់នៅពីឆ្ងាយសាលារៀន ហើយមានជីវភាពខ្វះខាត គម្រោងនឹងផ្តល់កង់មួយបន្ថែមទៀត។

គម្រោងពង្រឹងការអប់រំ និងលទ្ធភាពទទួលបានការងារសមរម្យតាមរយៈការចូលរួមពីសហគមន៍ (REACH/BMZ) បានរៀបចំកម្មវិធីផ្តល់សម្ភារៈសិក្សាដល់សិស្សអាហារូបករណ៍ និងកុមារងាយរងគ្រោះ នៅតាមសាលារៀនគោលដៅក្នុងខេត្តចំនួនបួនរួមមាន៖ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់។ អ្នកចូលរួមក្នុងកម្មវិធីសរុបចំនួន១៤៧០នាក់ ៨៨៥ ជាស្រី រួមមាន៖ សិស្សអាហារូបករណ៍ចំនួន ៤៤០ នាក់ (២៣២ កុមារី) កុមារងាយរងគ្រោះចំនួន២៤៣នាក់ (១១៨កុមារី ) ជានាយកនាយិកា មាតាបិតា អាណាព្យាបាលសិស្ស លោកគ្រូអ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀន និងអាជ្ញាធរឃុំភូមិ។

កម្មវិធីនេះ ធ្វើឡើងដើម្បីផ្តល់សម្ភារៈសិក្សាដល់សិស្សអាហារូបករណ៍ និងកុមារងាយរងគ្រោះ តាមរយៈចូលរួមចំណែកដោះស្រាយការលំបាករបស់សិស្សានុសិស្សដែលមិនមានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់សម្រាប់ការសិក្សាទាំងនៅសាលា និងនៅផ្ទះ ព្រមទាំងជំរុញឱ្យកុមារចូលរួមគ្រប់សកម្មភាពរបស់សាលារៀន ហើយវាជាផ្នែកជួយកាត់បន្ថយអត្រាបោះបង់ការសិក្សា។

លោក **ជា នាង** នាយកសាលាបឋមសិក្សាព្រះឈរ មានប្រសាសន៍ថា "**ក្នុងនាមជានាយកសាលាពិតជាមានសេចក្តីត្រេកអរដែលគម្រោងបានរៀបចំកម្មវិធីនេះឡើងដើម្បីជួយគាំទ្រដល់សិស្សានុសិស្សដែលមានជីវភាពខ្វះខាតក្នុងការសិក្សា និងសូមឱ្យមាតាបិតាយកចិត្តទុកដាក់ និងជម្រុញលើការសិក្សាឱ្យបានមករៀនទៀតទាត់ ជាពិសេសត្រូវចេះជួយថែរក្សាសម្ភារៈដែលបានទទួល**"។

កម្មវិធីចែកសម្ភារៈសិក្សានេះ បានផ្តល់ជូនដល់សិស្សានុសិស្សតាំងពីចុងខែឧសភា រហូតមកដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២៣។ សិស្សម្នាក់ទទួលបានសម្ភារៈសិក្សាដូចជា សៀវភៅ ដប់ប្រាំក្បាល ប៊ិក ប្រាំដើម ស្បែកជើង មួយគូ ឯកសណ្ឋានសិស្សពីរកំប្លេ និងកាតាបមួយ។ សម្រាប់សិស្សដែលរស់នៅពីឆ្ងាយសាលារៀន ហើយមានជីវភាពខ្វះខាត គម្រោងនឹងផ្តល់កង់មួយបន្ថែមទៀត។

កម្មវិធីផ្តល់អាហារូបករណ៍ និងសិស្សងាយរងគ្រោះ ពិតជាចូលរួមចំណែកដល់ការសិក្សារបស់កុមារ មានទាំងសម្លៀកបំពាក់សមរម្យ សម្ភារៈសិក្សាគ្រប់គ្រាន់ ដូចកុមារដទៃទៀត ដែលមានសិទ្ធិទទួលបានការអប់រំ និងចូលរួមគ្រប់សកម្មភាពដែលពួកគាត់ចង់ធ្វើ និងស្មើរភាពគ្នា ក្នុងកំរិតសាលារៀនដែលមិនមានការរើសអើង និងឈានដល់ទប់ស្កាត់ ឬកាត់បន្ថយការបោះបង់ការសិក្សា។

គម្រោងពង្រឹងការអប់រំ និងលទ្ធភាពទទួលបានការងារសមរម្យតាមរយៈការចូលរួមពីសហគមន៍ (REACH/BMZ) ប្រតិបត្តិដោយអង្គការ ខេប ទទួលហិរញ្ញប្បទានពីអង្គការវីវើល (WeWorld) និងអង្គការធ្វាលហ្វានអាឡឺម៉ង់៕



សិស្សម្នាក់ទទួលបានសម្ភារៈសិក្សាដូចជា សៀវភៅ ដប់ប្រាំក្បាល ប៊ិក ប្រាំដើម ស្បែកជើង មួយគូ ឯកសណ្ឋានសិស្សពីរកំប្លេ និងកាតាបមួយ។

# ការបង្ហាញលទ្ធផលរបស់គម្រោងទៅដល់ភាគីពាក់ព័ន្ធ



សកម្មភាពប្រជុំឆ្លុះបញ្ចាំងការអនុវត្តគម្រោងនៅខេត្តរតនគិរីដោយមានការអញ្ជើញចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡា

គម្រោងកុមារកម្ពុជារីករាយ(HCC) គឺជាគម្រោងដែលធ្វើការផ្តោតសំខាន់ លើការអភិវឌ្ឍសមត្ថភាពកុមារមត្តេយ្យសិក្សា ដើម្បីមានសមត្ថភាពមូលដ្ឋានអាចបន្តរៀន នៅបឋមសិក្សាប្រកបដោយសក្តានុពល និងប្រសិទ្ធភាពខ្ពស់។ ជារៀងរាល់ឆ្នាំ គម្រោងតែងតែរៀបចំវគ្គសិក្ខាសាលាស្តីពី ការបង្ហាញលទ្ធផលរបស់គម្រោងទៅដល់ភាគីពាក់ព័ន្ធទាំងអស់ពីផលសម្រេចបាន បញ្ហាប្រឈម និងពង្រឹងសមត្ថភាពលើផែនការអភិវឌ្ឍសាលារៀន។

សិក្ខាសាលានេះ មានគោលបំណងបង្ហាញពីលទ្ធផលនៃការអនុវត្តគម្រោងកុមារកម្ពុជារីករាយ ជូនដល់មន្ទីរអប់រំ យុវជន និងកីឡាក្នុងខេត្តគោលដៅចំនួន៥ រួមមាន៖ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តសៀមរាប និងចែករំលែកផែនការគម្រោងសម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ និងផែនការត្រូវអនុវត្តបន្ត ដើម្បីដោះស្រាយបញ្ហាប្រឈមនានា។

គម្រោងបានបង្ហាញពីសមិទ្ធផលនៃការចូលរួមចំណែកក្នុងការអភិវឌ្ឍសាលារៀនគោលដៅរួមមាន៖ កែលម្អផែនទីសិក្សា ការគ្រប់គ្រងទិន្នន័យព័ត៌មាន កែលម្អបណ្ណាល័យផ្សាភ្ជាប់សកម្មភាពអំណាន(អំណានថ្នាក់ដំបូង) បណ្តុះបណ្តាលគ្រូបង្រៀន(រួមទាំងគ្រូកិច្ចសន្យា) រៀបចំកម្មវិធីបំណិនជីវិតនៅក្នុងសាលារៀន(ទន់ និងរឹង)កែលម្អថ្នាក់រៀនរួមបញ្ចូលទាំងការជួសជុលបន្ទប់រៀន ផ្តល់សម្ភារៈជំនួយសម្រាប់ការរៀន និងបង្រៀន ផ្តល់អំណោយដល់សាលាតាមរយៈផែនការសាលារៀន ពង្រឹងសមត្ថភាពគណៈកម្មការសាលារៀន អ្នកថែទាំ និងចុងភៅ លើកកម្ពស់សកម្មភាពមត្តេយ្យសិក្សា និងមានសកម្មភាពផ្សេងៗមួយចំនួនទៀត។

លោក **ទូន មិថុនា** ប្រធានការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាបបានមានប្រសាសន៍ថា **"ក្នុងនាមតំណាងឱ្យមន្ទីរអប់រំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គម្រោងកុមារកម្ពុជារីករាយ ដែលបានប្រតិបត្តិការងារគម្រោងនៅក្នុងខេត្តសៀមរាបកន្លងមក ខ្ញុំសង្កេតឃើញថាការអនុវត្តគម្រោងនៅក្នុងសាលាគោលដៅពិតជាបានជួយអភិវឌ្ឍន៍សាលារៀនឱ្យមានភាពល្អប្រសើជាងមុន ជាពិសេសលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងបណ្ណាល័យបែបសតវត្សទី២១ ដែលបានផ្តល់នូវផាសុកភាពដល់លោកគ្រូអ្នកគ្រូ**

**សូមអានបន្តទំព័រ៥៤**


សកម្មភាពប្រជុំឆ្លុះបញ្ចាំងការអនុវត្តគម្រោងនៅខេត្តត្បូងឃ្មុំដោយមានការអញ្ជើញចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធផ្សេងរបស់គម្រោង

**ផតិចំព័រ៥៣** និងសិស្សានុសិស្សក្នុងការសិក្សាស្រាវជ្រាវឯកសារផ្សេងៗ ហើយសាលារៀនទៀតសោត ក៏មានលក្ខណៈគម្រូមួយដ៏ល្អក្នុងស្រុក ដើម្បីឱ្យសាលាដទៃទៀតយកជាគម្រូ។ បន្ថែមពីនេះ ប្រសិនបើគម្រោងមានលទ្ធភាព ខ្ញុំសូមសំណូមពរឱ្យគម្រោងពង្រីកសាលារៀនគោលដៅបន្ថែមដល់ស្រុកទាំងអស់ក្នុងខេត្តសៀមរាប ដើម្បីបង្កើតគម្រូសាលារៀនល្អនៅក្នុងស្រុកនីមួយៗ”។

លោក **តាត់ មាន** អភិបាលរងនៃគណៈអភិបាលស្រុកក្រឡាញ់បានមានប្រសាសន៍ថា“**ខ្ញុំពិតជាកោតសរសើរដល់គម្រោងដែលបានគាំទ្រ និងអភិវឌ្ឍន៍សាលារៀនគោលដៅក្នុងស្រុករបស់ខ្ញុំឱ្យមានភាពរីកចម្រើននិងមានលក្ខណៈល្អប្រសើរឡើងហើយខ្ញុំរីករាយក្នុងការបន្តសហការជំរុញឱ្យសាលារៀនគោលដៅមានវិវឌ្ឍន៍ទៅមុខទៀត**”។

ក្នុងឱកាសនេះផងដែរ **លោក ប៉ុក ទ្រី** នាយករងប្រតិបត្តិអង្គការកុមារកម្ពុជារីករាយតំណាងឱ្យម្ចាស់ជំនួយមានប្រសាសន៍ថា“**សាលារៀនមានការអភិវឌ្ឍទៅមុខ ដោយសារតែមានការចូលរួមយ៉ាងសកម្មពីនាយកនាយិកា និងតំណាងគណៈកម្មការគ្រប់គ្រងសាលារៀន ដែលតែងតែសហការចូលរួមក្នុងការអនុវត្តកម្មវិធីជាមួយគម្រោងកន្លងមកដូច្នេះធ្វើឱ្យសាលារៀនមានការផ្លាស់ប្តូរមុខមាត់ថ្មី ក្លាយជាសាលារៀនគំរូមួយនៅក្នុងសហគមន៍**”។

លោក **អោ កឿត** នាយកសាលាបឋមសិក្សាសំបួរស្ថិតក្នុងស្រុកក្រឡាញ់ខេត្តសៀមរាប បានលើកឡើងថា “**រយៈពេល ៥ ឆ្នាំនៃការអនុវត្តគម្រោង ខ្ញុំកត់សម្គាល់ឃើញថា គម្រោងបានជួយអភិវឌ្ឍន៍សាលាបានច្រើនទាំងការពង្រឹងគុណភាពគ្រូបង្រៀនពង្រឹងសមត្ថភាពការគ្រប់គ្រងដល់នាយកនិងគណៈកម្មការគ្រប់គ្រងសាលារៀន ផ្តល់សៀវភៅរឿង ការកែលម្អអគាសិក្សា បណ្ណាល័យ និងមានសមិទ្ធផលជាច្រើនទៀត។ កត្តាទាំងនេះវាបានកើតចេញពីខិតខំប្រឹងប្រែងពីគ្រប់អ្នកពាក់ព័ន្ធ និងធ្វើឱ្យសហគមន៍ និងអាណាព្យាបាលសិស្សមានការចូលរួមច្រើនជាងមុន និងមានទំនុកចិត្តក្នុងការបញ្ជូនកូនមកសាលារៀន ជាក់ស្តែងមកដល់ពេលបច្ចុប្បន្ននេះ សិស្សមានកំណើនពី ៦ថ្នាក់ រហូត ៨ថ្នាក់ ហើយវាអាចនឹងកើនសម្រាប់ឆ្នាំបន្តបន្ទាប់**”។

ទន្ទឹមនឹងការផ្លាស់ប្តូររីកចម្រើនគម្រោងក៏មានបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពក្នុងសាលារៀនគោលដៅដូចជាបរិស្ថានសាលានៅមានសម្រាម កន្លែងលាងដៃសម្អាតមិនទាន់បានស្អាត ក្រុមប្រឹក្សាកុមារ និងទីប្រឹក្សាកុមារីមិនដំណើរការសកម្មភាពសិស្សធំជួយសិស្សតូចមិនសូវដំណើរការ សាលារៀនមិនបានអនុវត្តបំណិនជីវិត ការរៀបចំរដ្ឋបាលបណ្ណាល័យ និងទីចាត់ការមិនទាន់បានត្រឹមត្រូវ និងការគាំទ្រប្រាក់ឧបត្ថម្ភពីឃុំមិនទៀងទាត់ និងមិនគ្រប់ចំនួន ព្រមទាំងសហគមន៍មិនសូវចូលរួមក្នុងសកម្មភាពប្រជុំការអភិវឌ្ឍសាលា។

គម្រោងក៏មានការសំណូមពរដល់នាយក គណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធទាំងអស់ សូមចូលរួមសម្អាត និងថែទាំធនធានដែលមានស្រាប់ឱ្យបានល្អពង្រឹងវិន័យ និងធ្វើការប្រកបដោយមនសិការបង្ហាញតម្លាភាព និងភាពស្មោះត្រង់ ព្រមទាំងបន្តកិច្ចសហការល្អជាមួយគ្នា ដើម្បីធ្វើឱ្យការអប់រំឱ្យកាន់តែប្រសើរឡើង។

វគ្គសិក្ខាសាលានេះ រៀបចំឡើងចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ដែលធ្វើឡើងតាមទីតាំងផ្សេងៗគ្នាតាមតំណាងខេត្តនីមួយៗ។ គម្រោងកុមារកម្ពុជារីករាយ ប្រតិបត្តិដោយអង្គការ ខេប ទទួលហិរញ្ញប្បទានពីមូលនិធិគីនឆាន់ ដែលផ្តោតទៅលើអភិវឌ្ឍគំរូកម្មវិធីសាលាកុមារមេត្រីដែលមាន៦សមាសភាគ និងរួមបញ្ចូលទាំង គុណភាពអប់រំ ការអប់រំបញ្ចូលគ្នានិងមានការចូលរួមពីអ្នកពាក់ព័ន្ធសាលារៀន ក្នុងគោលបំណងដើម្បីធានាឱ្យមានការផ្លាស់ប្តូរយ៉ាងល្អនូវការសិក្សាពីកម្រិតសាលាមត្តេយ្យសិក្សាឆ្លងទៅសាលាបឋមសិក្សា៕



ការប្រជុំឆ្លុះបញ្ចាំងអំពីសកម្មភាពគម្រោងក្នុងខេត្តសៀមរាប អំពីផលសម្រេចបាន បញ្ហាប្រឈម និងការស្នើសុំការជួយអន្តរាគមន៍បន្ថែមមន្ទីរអប់រំ យុវជន និងកីឡា។

# ដំណើរទស្សនកិច្ចសិក្សាទីប្រឹក្សាអង្គការអប់រំកុមារ (EAC)តំបន់គោលដៅ


ទីប្រឹក្សាអង្គការអប់រំកុមារបានជួបសំណេះសំណាលជាមួយគណៈកម្មាការគ្រប់គ្រងសាលារៀន នាយកសាលា។

គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍ ប្រកបដោយចេរភាពនិងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម (CO-SAVED) បាន រៀបចំទទួលដំណើរទស្សនកិច្ចសិក្សាទីប្រឹក្សា អង្គការអប់រំកុមារ (EAC)នៅសាលាបឋម សិក្សាវត្តតូចដែលស្ថិតនៅក្នុងខេត្តកំពត។

ដំណើរទស្សនកិច្ចនេះ ប្រព្រឹត្តទៅ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៣ ក្នុងគោល បំណងសិក្សាស្វែងពីដំណើរការគាំទ្រដល់ កុមារក្រៅសាលារៀនតាមរយៈការអន្តរាគមន៍ របស់គម្រោងដែលបានអនុវត្តសកម្មភាពក្នុង សាលារៀនគោលដៅរបស់ខ្លួន និងជួប សំណេះសំណាលជាមួយដៃគូអភិវឌ្ឍស្វែង យល់ពីផលជះនៃកម្មកម្មវិធី និងនិរន្តរភាព។

ទីប្រឹក្សាអង្គការអប់រំកុមារបានជួប សំណេះសំណាលជាមួយអាណាព្យាបាល សិស្ស គណៈកម្មាការគ្រប់គ្រងសាលារៀន នាយកសាលា ប្រធានការិយាល័យអប់រំយុវ ជន និងកីឡាស្រុក និងបុគ្គលិកអង្គការខេប ដែលបានយកចិត្តទុកដាក់ និងជួយគាំទ្រ ដល់កុមារក្រៅសាលារៀន ព្រមទាំងផ្តល់អា ហារូបករណ៍, សម្ភារសិក្សា(In-kind)និង សកម្មភាពអន្តរាគមន៍នានា។

តួយ៉ាង គម្រោងបានធ្វើការយ៉ាង ជិតស្និទ្ធជាមួយភ្នាក់ងាររបស់រដ្ឋាភិបាល និង អង្គការដៃគូជាច្រើន ដែលបានចូលរួម ចំណែកដល់ការអភិវឌ្ឍន៍សាលារៀននៅក្នុង សហគមន៍។ ទន្ទឹមនឹងនោះ លោក ផល សុវណ្ណជី អ្នកឯកទេសគុណភាពអប់រំអង្គការ ខេប បានចែករំលែកពីសកម្មភាពគម្រោង ដែលអនុវត្តក្នុងសាលារៀនគោលដៅរួមមាន ៖ ការកសាងសមត្ថភាពគ្រូបង្រៀន ការតាម ដានលទ្ធផលនៃការបោះបង់ការសិក្សារបស់ សិស្ស និងការវិលត្រលប់មកសាលារៀនវិញ តាមរយៈការអន្តរាគមន៍ពីកម្មវិធី និងការ ឆ្លើយតបទាន់ពេលដល់សិស្សានុសិស្សបន្ទាប់ ពីជំងឺកូវីដ-១៩ជាពិសេសការគាំទ្រដល់សិស្ស យឺតតាមរយៈកញ្ចប់ឯកសារបំប៉នបន្ថែម។

គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍ ប្រកបដោយចេរភាពនិងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម (CO-SAVED) ប្រតិបត្តិដោយអង្គការខេប ទទួលបានហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងអង្គការ Aide et Action ដែលកំពុងអនុវត្តសកម្មភាពនៅ តំបន់ធ្វេរដើម្បីប្រែក្លាយមានជីវភាពរស់រវើក ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានប្រកប ដោយចេរភាព ដោយពង្រឹងការផ្តល់សេវាកម្ម អប់រំដែលជាការចូលរួមចំណែកកាត់បន្ថយ ភាពក្រីក្រ៕

# ដំណើរទស្សកិច្ចសិក្សារបស់ម្ចាស់ជំនួយ មកពីប្រទេសអ៊ីតាលី

គម្រោងពង្រឹងការអប់រំនិងលទ្ធភាព ទទួលបានការងារតាមរយៈការចូលរួមពីសហ គមន៍(REACH / BMZ) បានរៀបចំទទួល ដំណើរទស្សកិច្ចសិក្សារបស់ម្ចាស់ជំនួយ មក ពីប្រទេសអ៊ីតាលី និងបានរៀបចំកម្មវិធីចែក ស្បៀងអាហារដល់សិស្សក្រីក្រ ក្រោមអធិបតី ភាព ឯកឧត្តម យិន សារ៉េន អភិបាលរងខេត្ត កំពង់ឆ្នាំងដល់សាលារៀនគោលដៅចំនួនប្រាំ រួមមាន៖ សាលាបឋមសិក្សាស្នែត សាលា បឋមសិក្សាភូមិចាស់ សាលាបឋមសិក្សាខ្លង ពពក សាលាបឋមសិក្សាក្រាំងស្គារ និង សាលាបឋមសិក្សាសាន់បាក់យ។

ដំណើរទស្សនកិច្ចនេះ ម្ចាស់ជំនួយ បានជួបសំណេះសំណាលជាមួយគណៈ អភិបាលរងខេត្ត នាយក លោកគ្រូអ្នកគ្រូ សហគមន៍ និងកុមារអំពីការគាំទ្រ និងការ អន្តរាគមន៍របស់គម្រោង ព្រមទាំងស្វែងរក ចំណុចខ្វះខាតដែលត្រូវកែលម្អ និងបំពេញ បន្ថែមដើម្បីជួយលើកកម្ពស់ការអប់រំ ប្រកបដោយបរិយាប័ន្ន។

កម្មវិធីចែកស្បៀងអាហារដល់សិស្សក្រីក្រ ជា ការលើកទឹកចិត្តដល់កុមារខិតខំប្រឹងប្រែង រៀនសូត្រ និងមករៀនឱ្យបានទៀងទាត់ និង បានចូលរួមចំណែកកាត់បន្ថយការចំណាយ ប្រចាំថ្ងៃបានមួយចំណែកផងដែរ។ សិស្ស ម្នាក់ទទួលបានស្បៀងអាហារដូចជា អង្ករ ២០ គីឡូ, មី ១ កេស, ប្រេងឆា ១ ដប, ទឹក ស៊ីអ៊ីវ ១ យួរ និងត្រីខ ១ យួរ។

ដំណើរទស្សនកិច្ចនេះ និងកម្មវិធី ចែកស្បៀងដំណើរការទៅយ៉ាងល្អដោយមាន ការអញ្ជើញចូលរួមពីអភិបាលរងខេត្ត ប្រធាន មន្ទីរ-ការិយាល័យអប់រំយុវជន និងកីឡាខេត្ត- ស្រុក មេឃុំ

**សូមអានបន្តទំព័រ៥៦**



ដំណើរទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយ មកពីប្រទេសអ៊ីតាលី បានជួបសំណេះសំណាលជាមួយនាយក លោកគ្រូអ្នកគ្រូ អាជ្ញាធរមូលដ្ឋាន និងកម្មវិធីចែកស្បៀងអាហារដល់សិស្សក្រីក្រក្នុងខេត្តកំពង់ឆ្នាំង។

**សូមអានបន្តទំព័រ៥៥** នាយក នាយិកា គណៈគ្រប់គ្រងសាលារៀន អាណាព្យាបាលសិស្ស និងសិស្សានុសិស្សចូលរួមជាមួយគម្រោងយ៉ាងសកម្ម។

គម្រោងគម្រោងពង្រឹងការអប់រំនិងលទ្ធភាពទទួលបានការងារតាមរយៈការចូលរួមពីសហគមន៍(REACH / BMZ) ប្រតិបត្តិដោយអង្គការខេប ទទួលហិរញ្ញប្បទានពីអង្គការ វីវើល ដើម្បីចូលរួមចំណែកក្នុងការបំពេញសិទ្ធិសង្គម និងសេដ្ឋកិច្ចរបស់កុមារ និងយុវជនកម្ពុជាដែលងាយរងគ្រោះពីការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព៕

# កម្មវិធីជួបសំណេះសំណាលរវាងនិស្សិតអាហារូបករណ៍ជាមួយគណៈប្រតិភូ



ការផ្តល់ឱកាសដល់ក្មេងស្រីដើម្បីអាចបន្តការសិក្សានៅឧត្តមសិក្សា និងទទួលបានជោគជ័យក្នុងការងារគឺជាការជួយលើកស្ទួយការផ្លាស់ប្តូរជាវិជ្ជមាននិងកាត់បន្ថយការរើសអើងយេនឌ័រនៅក្នុងសង្គមកម្ពុជា។

នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ អង្គការ ខេប បានរៀបចំកម្មវិធីជួបសំណេះសំណាលរវាងនិស្សិតអាហារូបករណ៍ស្រីជាមួយគណៈប្រតិភូអញ្ជើញមកពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) និងសាកលវិទ្យាល័យ California, Berkeley នៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) រាជធានីភ្នំពេញ។

និស្សិតស្រីទាំង១២នាក់ ដែលបានទទួលអាហារូបករណ៍ដោយជោគជ័យទាំងអស់ដើម្បីបន្តការសិក្សាជំនាញនៅថ្នាក់ឧត្តមសិក្សារយៈពេល៤ឆ្នាំនៅសាកលវិទ្យាភូមិន្ទភ្នំពេញ ឯកទេស វិស្វកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាក្រោមជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) និងសាកលវិទ្យាល័យ California, Berkeley។ អង្គការខេប(KAPE) បានទទួលហិរញ្ញប្បទានតាមរយៈមូលនិធិអាស៊ី (TAF) ដើម្បីជួយគាំទ្រដល់និស្សិតស្រី ១២នាក់សិក្សានៅសាកលវិទ្យាល័យពីឆ្នាំ ២០២៣-២០២៧។

វាពិតជាកិត្តិយសខ្លាំងណាស់សម្រាប់និស្សិតអាហារូបករណ៍ដែលបានជួបជាមួយលោក ប៉ែន ចិន្តា ប្រធានទទួលបន្ទុកកម្មវិធីបង្កើតការងារក្នុងវិស័យឌីជីថល (DWD) នៃទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ(USAID) លោកស្រី Samatha Alvis លោក George Scharffenberger និងក្រុមការងារ។ កិច្ចជំនួបនេះ **សូមអានបន្តទំព័រ៥៧**

**តពីទំព័រ៥៦** ពិតជាមានផលផ្លែផ្កាយ៉ាងច្រើន ដោយសារនិស្សិតអាហារូបករណ៍បានធ្វើឱ្យមានទំនាក់ទំនងល្អទៅវិញទៅមក និងបានចែករំលែកបទពិសោធន៍ដ៏ល្អៗ អំពីការចាកចេញពីផ្ទះទៅនៅទីក្រុង ក្នុងបំណងបន្តការសិក្សាថ្នាក់ឧត្តមសិក្សាសម្រាប់អនាគតការងាររបស់ពួកគេ។

ម្យ៉ាងវិញទៀត និស្សិតអាហារូបករណ៍បានចែករំលែកនូវកម្មវិធីសិក្សាបន្ថែមផ្សេងៗទៀតដែលគេរៀនសូត្របានក្រៅពីសាកលវិទ្យាល័យ។«**ខ្ញុំពិតជាមានមោទនភាពដែលជានិស្សិតដែលទទួលបានអាហារូបករណ៍ គាំទ្រដោយ USAID ។ វាពិតជាមានតម្លៃមហិមាសម្រាប់ដំណើរជីវិតរបស់ខ្ញុំ។ ខ្ញុំរៀនពីរបៀបរស់នៅ ការចែករំលែក និង ការជួយគ្នាប្រៀបដូចបងប្អូននិងមិត្តភក្តិ។**» ណារីជានិស្សិតឆ្នាំទីមួយបានលើកឡើង។ នាងបានបន្ថែមទៀតថា ខេប ប្រៀបដូចជាអាណាព្យាបាលទី២ ក្នុងការជួយគាំទ្រ និង ប្រឹក្សាដល់និស្សិតអាហារូបករណ៍ទាំងអស់ដែលរស់នៅក្នុងអន្តេវាសិកដ្ឋាន។ ពួកយើងត្រូវបានលើកទឹកចិត្តឱ្យចូលរួម វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំស្ម័គ្រចិត្តជួយសង្គម និងចូលរួមក្លឹបសិក្សា ដើម្បីពង្រឹងលើមុខវិជ្ជារៀននៅសាលាទៀតផង។



និស្សិតអាហារូបករណ៍បានរៀបរាប់ពីការផ្លាស់ប្តូរបន្ទាប់ពីទទួលការអន្តរាគមន៍ពីគម្រោងនៅថ្នាក់ឧត្តមសិក្សា។

ជាលទ្ធផលពីជំនួបនេះ គណៈប្រតិភូបានសម្តែងនូវការពេញចិត្ត និងបានលើកទឹកចិត្តពួកគេឱ្យព្យាយាមអស់ពីសមត្ថភាពក្នុងការសិក្សានៅសាកលវិទ្យាល័យ ហើយទទួលបានលទ្ធផលល្អ។ ពួកគាត់បន្ថែមទៀតថានិស្សិត គួរតែចូលរួមមជ្ឈមណ្ឌលអាជីពរបស់ USAID ឬអង្គការអាមេរិកខន័រ (American Corner) ដើម្បីទទួលបានឱកាសសិក្សាបន្ថែមទៀត និង ឱកាសអាហារូបករណ៍ទៅក្រៅប្រទេស៕

# ការកៀរគរសិស្សក្រៅសាលាឱ្យពួកគេបានត្រឡប់មកចូលរៀនវិញ

គម្រោងសហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិចតំបន់១ (FOSTER) បានរៀបចំកម្មវិធីយុទ្ធនាការតាមខ្នងផ្ទះ ដើម្បីកៀរគរសិស្សក្រៅសាលាឱ្យពួកគេបានត្រឡប់មកចូលរៀនវិញ និងលើកកម្ពស់សិទ្ធិកុមារក្នុងមូលដ្ឋាន ជាពិសេសធ្វើការផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំដល់សហគមន៍ ក្រុមគ្រួសារ អាណាព្យាបាល និងអាជ្ញាធរ។

យុទ្ធនាការនេះរៀបចំឡើងក្នុងគោលបំណង៖១-កំណត់ និងស្វែងរកកុមារក្រៅសាលា។ ២-ផ្តល់ចំណេះដឹងអំពីសិទ្ធិកុមារដល់អ្នកពាក់ព័ន្ធនានា។ ៣-ផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ និងការការពារកុមារពីការរំលោភបំពានគ្រប់ទម្រង់ និង៤-ផ្សព្វផ្សាយពីសារៈសំខាន់នៃអប់រំដល់សហគមន៍។

លោក ឆេង វណ្ណា ជាគណៈគ្រប់គ្រងសាលាបឋមសិក្សាមុខប៉ែន បង្ហាញនូវភាពសប្បាយរីករាយ និងមានប្រសាសន៍ថា **"ការរៀបចំកម្មវិធីយុទ្ធនាការតាមខ្នងផ្ទះបានធ្វើឱ្យគណៈកម្មការសាលារៀន សហគមន៍ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងអាជ្ញាធរមូលដ្ឋានបានជួបជជែក និងពិភាក្សាគ្នាបន្ថែមពីគុណតម្លៃនៃការអប់រំ ដល់អាណាព្យាបាលឱ្យចេះតាមដានការរៀនសូត្ររបស់កូន ជាពិសេសធ្វើឱ្យអ្នកពាក់ព័ន្ធបានដឹងពីដំណើរការអភិវឌ្ឍសាលា និងផែនការអនុវត្តបន្ត"**។

កម្មវិធីយុទ្ធនាការតាមខ្នងផ្ទះ ប្រព្រឹត្តទៅបានយ៉ាងល្អដោយសារមានការចូលរួមពីនាយកសាលារៀន អាជ្ញាធរមូលដ្ឋាន មាតាបិតា លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សដើម្បីផ្សព្វផ្សាយការអប់រំដល់សហគមន៍កាន់តែទូលំទូលាយ។

គម្រោងសហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិចតំបន់១ (FOSTER) ប្រតិបត្តិដោយអង្គការ ខេប ទទួលហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងអង្គការ AeA ដែលមានគោលបំណងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងភាពធន់របស់សហគមន៍នេសាទនៅតំបន់បឹងទន្លេសាប៕



ការអប់រំនឹងជួយឱ្យកុមាររស់នៅប្រកបដោយសុខសន្តិភាព ការពារបរិស្ថាន ជាពិសេសជាផ្នែកមួយជួយអភិវឌ្ឍសង្គម។

# កិច្ចប្រជុំឆ្លុះបញ្ចាំងអំពីសកម្មភាពរបស់គម្រោងក្នុងសាលារៀនគោលដៅ



បន្ទាប់ពីបូកសរុបលទ្ធផលការងារកន្លងមក ដោយទទួលបានសមិទ្ធផល និងផលសម្រេចជាច្រើន គម្រោងHCC នឹងធ្វើការពង្រីកសាលារៀនបន្ថែមក្នុងខេត្តគោលដៅរបស់ខ្លួនក្នុងឆ្នាំ២០២៤។

គម្រោងកុមារកម្ពុជារីករាយ(HCC) បានរៀបចំកិច្ចប្រជុំស្ដីពីការឆ្លុះបញ្ចាំងសកម្មភាពរបស់គម្រោងដែលធ្វើឡើងនៅការិយាល័យកណ្ដាលខេប ក្នុងក្រុងកំពង់ចាម។ កិច្ចប្រជុំនេះ ធ្វើឡើងនៅថ្ងៃទី៥ ដល់ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣ ក្នុងគោលបំណង៖ ១.ឆ្លុះបញ្ចាំងអំពីសកម្មភាពគម្រោងរួមមាន៖ សមិទ្ធផល បញ្ហាប្រឈម អនុសាសន៍ម្ចាស់ជំនួយ និងរៀបចំផែនការបន្ត។ ២. បង្ហាញពីយន្តការអនុវត្តគម្រោងក្នុងឆ្នាំថ្មី និង កំណត់យុទ្ធសាស្ត្រ និងលទ្ធផលក្នុងផែនការថ្មី។

សមាសភាពអ្នកចូលរួម គឺជាមន្ត្រី និងអ្នកពាក់ព័ន្ធរបស់គម្រោងដែលបានរបាយការណ៍ពីសកម្មភាពតាមខេត្តនីមួយៗរួមមាន ៖ ផ្នែកងាយស្រួលចូលសាលា, ការងារប្រឹក្សាគរុកោសល្យគ្រូកិច្ចសន្យា, ការងារអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន, ការបណ្ដុះបណ្ដាលគ្រូកិច្ចសន្យា និងតាមដាន, ផ្នែកជួយសិស្សរៀនយឺតលើការអាន និងសរសេរថ្នាក់ដំបូង, សកម្មភាពចុះសង្កេតគ្រូបង្រៀនជាមួយក្រុមការងារមន្ត្រីមន្ទីរ-ការិយាល័យអប់រំយុវជន និងកីឡាខេត្ត-ស្រុក, ការតាមដានលើការងារជួយសិស្សរៀនយឺតនៅថ្ងៃព្រហស្បតិ៍, ការងាររដ្ឋបាល និងហិរញ្ញវត្ថុ, ឆ្លុះបញ្ចាំងលើការងារតាមដាន និងវាយតម្លៃ (វាយតម្លៃកម្មវិធី, ប្រមូលនិងទុកដាក់ទិន្នន័យ, ផែនការ M&Eគម្រោងប្រចាំឆ្នាំ) យន្តការ និងយុទ្ធសាស្ត្រថ្មី, ការផ្ដល់ធាតុចូលពីមន្ត្រីតាមខេត្ត និងផ្សេងៗ, ការបូកសរុប និងយុទ្ធសាស្ត្រក្នុងគម្រោង, ការងារតាមដានត្រួតពិនិត្យលើសំណង់ អនាម័យ និង ការគ្រប់គ្រង។

បច្ចុប្បន្ននេះ គម្រោងកុមារកម្ពុជារីករាយកំពុងអនុវត្តសកម្មភាពក្នុងសាលារៀនគោលដៅចំនួន៤១ ក្នុងខេត្តចំនួន៥ រួមមាន ៖ សៀមរាប កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និង រតនគិរី។

ជាលទ្ធផល កិច្ចប្រជុំនេះប្រមូលបានធាតុចូលជាច្រើនតាមផ្នែកនីមួយៗដើម្បីឱ្យការអនុវត្តសកម្មភាពគម្រោងក្នុងសាលារៀនគោលដៅទទួលបានសមិទ្ធផលល្អៗ ជាពិសេសក្នុងឆ្នាំនេះ គម្រោងនឹងពង្រីកសាលារៀនគោលដៅបន្ថែមទៀត ក្នុងការពង្រឹងលទ្ធភាពទទួលបានសេវាអប់រំឱ្យកាន់តែល្អប្រសើរឡើងនៅតំបន់គោលដៅ៕

# កម្មវិធីផ្លាស់ប្តូរការសិក្សាជូនដល់លោកគ្រូអ្នកគ្រូសាលារៀនគោលដៅ

គម្រោងលើកកម្ពស់គុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសាន (EQUAL) បានរៀបចំកម្មវិធីផ្លាស់ប្ដូរការសិក្សាជូនដល់លោកគ្រូអ្នកគ្រូសាលារៀនគោលដៅរបស់គម្រោង ទៅកាន់សាលាបឋមសិក្សា និងវិទ្យាល័យ ហ៊ុន សែន កំពង់ចាម បឋមសិក្សាទួលថ្ម និងរភាពប្រាំដែលស្ថិតនៅក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សិក្ខាកាមសរុបចំនួន ៣៦ នាក់មកពីសាលារៀនគោលដៅចំនួន ១៥ ពីខេត្តរតនគិរី ដើម្បីស្វែងយល់ពីដំណើរការអភិវឌ្ឍន៍សាលារៀន។



លោកគ្រូអ្នកគ្រូទស្សនកិច្ចនៅសាលារៀនជំនាន់ថ្មីវិទ្យាល័យហ៊ុន សែន កំពង់ចាមក្នុងបន្ទប់កុំព្យូទ័រ។

ដំណើរទស្សនកិច្ចនេះ ប្រព្រឹត្តទៅនៅថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០២៣ ក្នុងគោលបំណងសិក្សារៀនសូត្រពីបទពិសោធន៍ល្អៗ ដើម្បីយកទៅអនុវត្តន៍ និងអភិវឌ្ឍន៍តាមសាលារៀនព្រមទាំងលើកកម្ពស់គុណភាពការសិក្សារបស់សិស្សានុសិស្ស។

សិក្ខាកាមបានដើរទស្សនកិច្ចជុំវិញទីធ្លាសាលារៀន

សូមអានបន្តទំព័រ៥៩



លោកសឿង វ៉ាន់ នាយកវិទ្យាល័យ ហ៊ុន សែន កំពង់ចាម (រាប់ពីស្តាំមក) បានរៀបរាប់បង្ហាញពីប្រវត្តិសាលារៀន លទ្ធផលសម្រេចបាន និងបញ្ហាប្រឈមដែលបានជួបប្រទះកន្លងៗ

**សូមអានបន្តទំព័រ៥៨** និង បានស្វែងយល់ពីការរៀបចំបរិស្ថានក្នុង និង ក្រៅថ្នាក់រៀន សកម្មភាពបណ្ណាល័យសតវត្សរ៍ទី២១ ក្លឹបសិក្សា បន្ទប់ពិសោធន៍ ទស្សនកិច្ចសិក្សា សួនបំណិនជីវិត ការដឹកនាំក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារ ជាពិសេសនាយក ព្រមទាំងលោកគ្រូអ្នកគ្រូបានសហការរីករាយក្នុងការចែករំលែកពីបទពិសោធន៍ និងចំណេះដឹងល្អៗជាមួយសិក្ខាកាម។ ដំណើរទស្សនកិច្ចនេះ ធ្វើឱ្យសិក្ខាកាមបានស្វែងយល់ពីការដឹកនាំ និងគ្រប់គ្រងសាលារៀន ពង្រឹងសមត្ថភាព ជំរុញឱ្យមានការគិតបែបច្នៃប្រឌិត ដើម្បីផ្តល់សេវាអប់រំកាន់តែមានប្រសិទ្ធភាពដល់សិស្សានុសិស្ស។

គម្រោងEQUAL មានសាលារៀនគោលចំនួន១៥ ក្នុងនោះមានសាលាបឋមសិក្សាចំនួនដប់បី និងអនុវិទ្យាល័យចំនួនពីរ ដែលស្ថិតនៅស្រុកបរកែវ និងអណ្តូងមាស។

គម្រោងEQUAL ទទួលបានហិរញ្ញប្បទានពីអង្គការភ្លែនអន្តរជាតិកម្ពុជាដែលមានគោលបំណងចម្បងផ្តោតលើកុមារនៅក្រៅសាលា និងកុមារជនជាតិភាគតិចក្នុងខេត្តរតនគិរីឱ្យមានឱកាសបំពេញសិទ្ធិក្នុងការអប់រំនៅកម្រិតបឋមសិក្សា និងបន្តទៅអនុវិទ្យាល័យដោយរលូនតាមរយៈការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងការផ្លាស់ប្តូរយេនឌ័រ។

# កិច្ចប្រជុំឆ្លុះបញ្ចាំងអំពីសកម្មភាពរបស់គម្រោងក្នុងសាលារៀនគោលដៅ




លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការប្រចាំ ក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញចូលរួមជាអធិបតីភាពក្នុងកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរ ។

កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០២៣ ក្រសួងអប់រំ យុវជន និងកីឡា ក្រុមហ៊ុន Meta និងអង្គការ ខេប បានសហការគ្នារៀបចំកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរ (KDLP) សម្រាប់ប្រើប្រាស់នៅសាលារៀនជំនាន់ថ្មី ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការប្រចាំ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានសមាសភាពអ្នកចូលរួមសរុបចំនួន៥០នាក់ រួមមាន៖ ក្រុមការងារក្រសួងអប់រំ យុវជន និងកីឡា ក្រុមការងារបច្ចេកទេស នាយកសាលា និងគ្រូបង្គោលទាំង១២ដែលមកពីសាលារៀនជំនាន់ថ្មីទាំងប្រាំមួយ តំណាងក្រុមហ៊ុន Meta និងក្រុមការងារអង្គការ ខេប។ កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ(KDLP)គឺជាគំនិតផ្តួចផ្តើមមួយរបស់

**សូមអានបន្តទំព័រ៦០**

**តពីទំព័រ៥៩** WeThinkDigital ដែលបង្កើតឡើងដោយក្រុមហ៊ុន Meta (Facebook) ក្នុងឆ្នាំ 2019 ដើម្បីជួយអភិវឌ្ឍជំនាញដែលយើងត្រូវការ ដើម្បីបង្កើតពលរដ្ឋឌីជីថលដែលមានទំនួលខុសត្រូវ ការគិតបែបស៊ីជម្រៅ ការយល់ចិត្តគ្នា និងការសន្ទនាបែបឌីជីថល។ KDLP គឺជាកម្មវិធីរយៈពេលមួយឆ្នាំ ដែលមានគោលបំណងក្នុងការផ្តល់សនិទានភាព និងការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា ICT សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៧-៩) នៅក្នុងសាលារៀនជំនាន់ថ្មី (NGS)។ កម្មវិធីនឹងផ្តល់ឱ្យសិស្សនូវជំនាញមូលដ្ឋានគ្រឹះទាក់ទងទៅនឹងអក្ខរកម្មឌីជីថល តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាដោយប្រើប្រាស់កម្មវិធីសិក្សារបស់ WeThinkDigital។

លោក បណ្ឌិត **ហេង ភក្តី** ជាប្រធានគោលនយោបាយសារធារណៈប្រចាំនៅកម្ពុជា តំណាងឱ្យក្រុមហ៊ុន មេតា បានមានប្រសាសន៍ថា "**ក្រុមហ៊ុនមេតាផ្តោតសំខាន់ទៅលើអក្ខរកម្មឌីជីថល ពីព្រោះវាជាមូលដ្ឋានគ្រឹះដ៏សំខាន់នៅក្នុងបរិបទសម័យអប់រំបែបឌីជីថល នាពេលបច្ចុប្បន្ននេះ។ សិស្សគួរតែទទួលបានបំណិនអក្ខរកម្មឌីជីថល រួចជាស្រេចតាំងពីកម្រិតអនុវិទ្យាទៅ ហើយគាត់អាចយកទៅអនុវត្តនៅកន្លែងការងារ និងចូលរួមអភិវឌ្ឍប្រទេសជាតិ។ ការសហការជាមួយអង្គការ ខេប សម្រាប់ការតាក់តែងឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរ ជាផលសម្រេចបានដ៏សំខាន់មួយ ហើយយើងសង្ឃឹមថា ឯកសារដែលដាក់ឱ្យអនុវត្តសាកល្បងនេះ នឹងប្រមូលធាតុចូលសំខាន់ៗជាច្រើន ដូចជា បញ្ហាប្រឈម ផលលំបាក និងការផ្តល់មតិត្រឡប់ ដើម្បីធ្វើការកែលម្អឱ្យមានលក្ខណៈល្អប្រសើរឡើង ជាពិសេស កម្មវិធីនឹងផលិតឯកសារបន្ថែមក្នុងការពង្រីកវិសាលភាពឱ្យកាន់តែទូលំទូលាយ**"។

លោក **សៅ វណ្ណា** នាយកប្រតិបត្តិអង្គការ ខេប បានមានប្រសាសន៍ថា "**ការគាំទ្រពីក្រុមហ៊ុនមេតា ពិតជាបានឆ្លុះបញ្ចាំងពីការចូលរួមយ៉ាងសកម្មនៅក្នុងវិស័យឯកជន ដែលបានជួយគាំទ្រដល់កំណែទម្រង់វិស័យអប់រំ ដើម្បីឆ្លើយតបទៅនឹងទិសដៅសេដ្ឋកិច្ចឌីជីថលកម្ពុជា។ ដូច្នេះ លោកគ្រូអ្នកគ្រូនឹងទទួលបានវិធីសាស្ត្រ និងចំណេះដឹងថ្មីៗបន្ថែមពីឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរ ក្នុងការបង្រៀន និងរៀន ជាពិសេសសិស្សានុសិស្សនឹងទទួលបានចំណេះដឹងអក្ខរកម្មឌីជីថលច្បាស់លាស់មួយសម្រាប់ប្រើប្រាស់ក្នុងសម័យបច្ចេកវិទ្យានេះ**"។

លោកជំទាវ **គឹម សេដ្ឋានី** បានលើកឡើងថា "**ក្នុងរាជរដ្ឋាភិបាលនីតិកាលទី៧ ក្រោមការដឹកនាំរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត វិស័យអប់រំត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយ ក្នុងចំណោមកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្រសួងអប់រំបានយកចិត្តទុកដាក់ និងផ្តោតសំខាន់ទៅលើគុណភាពអប់រំចាប់ពីកម្រិតមត្តេយ្យរហូតដល់មធ្យមសិក្សា ធ្វើយ៉ាងណាបណ្តុះបាននូវបំណិនទន់ បំណិនរឹង អប់រំតវិយាបថ សុជីវធម៌ និងសីលធម៌ ដើម្បីអាចក្លាយជាពលរដ្ឋពេញលេញ ឬមូលធនមនុស្សសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ ជាពិសេសចំណេះដឹងទាក់ទងនឹងបច្ចេកវិទ្យា (ICT) នេះតែម្តង**"។ លោកជំទាវ បានកោតសរសើរ និងអបអរសាទរចំពោះក្រុមការងារក្រោមការគាំទ្រដោយក្រុមហ៊ុន មេតា ដែលសម្រេចបានការងារ និងឈានដល់ការសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរនេះឡើង ដែលជាផ្នែកមួយក្នុងការលើកកម្ពស់ការអប់រំឌីជីថលនៅកម្ពុជា។ ការដាក់ឯកសារឱ្យប្រើប្រាស់នេះ បង្កើនកិច្ចសហការល្អរវាងក្រហ៊ុន Meta ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ ខេប៕



អង្គការ ខេប ជាអង្គការក្នុងស្រុកមួយដែលទទួលបានការគាំទ្រ និងហិរញ្ញប្បទានពីក្រសួង អប់រំ យុវជន និងកីឡាក្នុងការកែប្រែវិស័យអប់រំមានភាពរីកចម្រើននាពេលអនាគត។

# ដំណើរទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយអង្គការឆាលហ្វានកូរ៉េ


ដំណើរទស្សនកិច្ចសិក្សានៅសាលាបឋមសិក្សារលួសដែលស្ថិតនៅក្នុងខេត្តក្រចេះ។

គម្រោងងាយស្រួលរៀន(E2L) បានរៀបចំទទួលដំណើរទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយអង្គការឆាលហ្វានកូរ៉េនៅសាលារៀនគោលដៅចំនួនបីរួមមាន៖ សាលាបឋមសិក្សាស្វាយចេក សង្គម និងរលួស ដើម្បីស្វែងយល់ពីលទ្ធផល និងបញ្ហាប្រឈមនៃការអនុវត្តគម្រោង។

ដំណើរទស្សនកិច្ចនេះ ប្រព្រឹត្តទៅកាលពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២៣ ដោយមានការអញ្ជើញចូលរួមពីអភិបាលរងស្រុក និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ស្រុក អង្គការឆាលហ្វានកម្ពុជា និងអង្គការខេប។

ម្ចាស់ជំនួយផ្តោតសំខាន់ទៅលើសមិទ្ធផលនានាដែលគម្រោងបានអនុវត្តរយៈពេល២ឆ្នាំកន្លងមក ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងការបន្តនិរន្តរភាពគម្រោង។

គម្រោងងាយស្រួលរៀន កំពុងអនុវត្តសកម្មភាពក្នុងសាលារៀនគោលដៅចំនួនប្រាំបួន ដែលមានគោលបំណងលើកកម្ពស់គុណភាពអប់រំកម្រិតបឋមសិក្សានៅស្រុកសំបូរខេត្តក្រចេះ៕

# កម្មវិធីសម្ពោធអគារសិក្សាថ្មី និងសមិទ្ធផលនានានៅក្នុងសាលារៀន


កម្មវិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាឈើខ្លឹម ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម វង ភិរុណ អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា និង លោក ហាតមុត ហ្គីស៊ីកេ ប្រធានមូលនិធិគីនចានពីប្រទេសអាល្លឺម៉ង់។

គម្រោងកុមារកម្ពុជារីករាយ(HCC) បានរៀបចំកម្មវិធីសម្ពោធអគារសិក្សាថ្មី និងសមិទ្ធផលនានានៅក្នុងសាលារៀនគោលដៅចំនួន៤១សាលា ដែលគាំទ្រហិរញ្ញប្បទានពីមូលនិធិគីនចាន និងផ្តល់នូវលិខិតថ្លែងអំណរគុណ ជូនដល់អង្គការម្ចាស់ជំនួយ និងដៃគូប្រតិបត្តិគម្រោងក្រោមអធិបតីភាពឯកឧត្តម វង ភិរុណ អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ដែលប្រព្រឹត្តទៅនៅបឋមសិក្សាឈើខ្លឹម ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣។

លោក **អ៊ីនពៅ សម្បត្តិ** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំបានលើកឡើងថា "**ក្នុងអណត្តិថ្មីឆ្នាំសិក្សា២០២៣នេះ ក្រសួងអប់រំបានកំណត់ឱ្យខេត្តនីមួយៗជ្រើសរើសសាលាចំនួន២០ ដោយជ្រើសរើសជាសាលាគម្រូរបស់ខេត្តដោយផ្តោតលើ ៧ ចំណុចគឺ៖១.សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនគម្រូ។ ២.សាលារៀនមានស្វ័យភាព**

សូមអានបន្តទំព័រ៦២

**តពីទំព័រ៦១** កែលម្អសាលារៀន ថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។ ៣. សិស្សមានសមត្ថភាព និងធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌។ ៤.គ្រូបង្រៀនអាចប្រើប្រាស់លទ្ធភាពតេស្តដើម្បីកែលម្អការបង្រៀន និងការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំហើយថែមទាំងអាចជួយសិស្សរៀនយឺត និងផ្តល់។ ៥.បង្កើនសកម្មភាពក្រៅម៉ោងសិក្សាដើម្បីអប់រំគុណធម៌ សីលធម៌ សុជីវធម៌ដល់សិស្សានុសិស្ស។ ៦.មានការយកចិត្តទុកដាក់លើគុណភាពសិក្សា និងអាហារូបត្ថម្ភរបស់សិស្សនុសិស្ស និងមានការចូលរួមពអាណាព្យាបាល មាតាបិតា និងសហគមន៍ក្នុងការគាំទ្រ និងអភិវឌ្ឍសាលារៀន"។

លោក **នេត សុឃាន់** នាយកសាលាបឋមសិក្សាឈើខ្លឹមបានមានប្រសាសន៍ថា "សាលារៀនមានការអភិវឌ្ឍពីមួយឆ្នាំទៅមួយឆ្នាំ នេះក៏ដោយសារមានការចូលរួមពីសហ-គមន៍ គណកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរមូលដ្ឋានជាពិសេសទទួលបានការអន្តរា-គមន៍ពីគម្រោងកុមារកម្ពុជារីករាយរបស់អង្គការ ខេប ដែលទទួលជំនួយពី លោក ហាតមុត ហ្គីស៊ីកេ។ គម្រោងបានជួយកសាងអគារសិក្សាមួយខ្នងស្មើនឹង២បន្ទប់ កសាងបន្ទប់ឃ្លាំងធ្វើពីដែកដាក់សម្ភារៈ ជួសជុលអគារសិក្សាចាស់ ផ្តល់សម្ភារៈសម្រាប់ការបង្រៀន និងរៀន និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់លោកគ្រូអ្នកគ្រូក្របខណ្ឌរដ្ឋ លោកគ្រូអ្នកគ្រូកិច្ចសន្យា និងនាយកព្រមទាំងបច្ចេកទេសមួយចំនួនថែមទៀតផង។ នេះសបញ្ជាក់ឱ្យឃើញថា គម្រោងមានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍសាលារៀន និងពង្រឹងសេវាអប់រំនៅតំបន់ដាច់ស្រយាល"។

លោក **សៅ វណ្ណា** នាយកប្រតិបត្តិអង្គការ ខេប បានមានប្រសាសន៍ថា "គម្រោងកុមារកម្ពុជារីករាយបានជួសជុល និងកែលម្អអគារសិក្សាឡើងវិញមានចំនួន៤១អគារ តាំងពីឆ្នាំ២០១៧ជាឆ្នាំផ្តើមអនុវត្តគម្រោង រហូតដល់ពេលបច្ចុប្បន្ននេះ ដែលប្រតិបត្តិដោយអង្គការខេប និងសមាគមន៍គ្រួសារយើងនៅក្នុងខេត្តគោលដៅចំនួន៥រួមមាន៖ ខេត្តសៀមរាប រតនគីរី ក្រចេះ ត្បូងឃ្មុំ និងខេត្តកំពង់ចាម។ គម្រោងមានសកម្មភាពសំខាន់ៗរួមមាន៖ ការគាំទ្រសកម្មភាពមត្តេយ្យសិក្សាមួយក្នុងឃុំហាន់ជ័យ ការធ្វើទំនើបកម្មបណ្ណាល័យ ការកសាងសមត្ថភាពគ្រូកិច្ចសន្យា ការតាមដានការប្រើប្រាស់ថវិកាអភិវឌ្ឍសាលារៀន ការបញ្ចូលមុខងារអ្នកមើលថែទាំសាលារៀន ការគ្រប់គ្រងការវាយតម្លៃអំណានថ្នាក់ដំបូង(EGRA) ការពង្រឹងថ្នាក់រៀន ការគ្រប់គ្រងសាលារៀន និងការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់ ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការប្រតិបត្តិរបស់ក្រុមប្រឹក្សាកុមារដើម្បីឆ្លើយតបតាមគោលបំណងរួមរបស់សហគមន៍ និងម្ចាស់ជំនួយដែលចង់ឃើញសាលាទាំងអស់មានសមត្ថភាពរឹងមាំមានម្ចាស់ការលើគ្រប់ផ្នែកគ្រប់វិស័យក្នុងការឆ្ពោះទៅរកនិរន្តរភាព"។

គម្រោងកុមារកម្ពុជារីករាយបានរៀបចំឡើងមានគោលបំណងដូចជា ១)ជួយពង្រឹងលទ្ធភាពទទួលបានសេវាអប់រំឱ្យកាន់តែមានភាពប្រសើរឡើងនៅតំបន់គោលដៅ(ពិសេសសំដៅលើកុមារី និងកុមារងាយរងគ្រោះ)។ ២)ពង្រីកប្រសិទ្ធិភាពបង្រៀន និងរៀន(សង្កត់ធ្ងន់លើគុណភាពអប់រំ) សំដៅធ្វើយ៉ាងណាឱ្យមានភាពប្រសើរជានិរន្តតាមរយៈការអភិវឌ្ឍទាំងក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀនដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារជាពិសេសកុមារី និងកុមារងាយរងគ្រោះ។ ៣)ពង្រឹងសកម្មអំណាន និងគណិតវិទ្យាថ្នាក់ដំបូងរបស់កុមារពីថ្នាក់ទី១ដល់ទី៣ឱបានប្រសើរឡើង។ ៤)កែលម្អសមត្ថភាពគ្រប់គ្រងដៃគូរកម្រិតមូលដ្ឋានសាលារៀន ដើម្បីបង្កើនលទ្ធភាពផ្តល់សេវាអប់រំ និងគុណភាពបង្រៀន និងរៀន រួមទាងការផ្សព្វផ្សាយនៅតាមសហគមន៍ និងបង្កើនគុណភាពនៅកម្រិតមតេយ្យសិក្សានៅតាមសហគមន៍និង **សូមអានតទំព័រ៦៣**



គម្រោងបានជួយគាំទ្រដល់វិធីសាស្រ្តបង្រៀន និងរៀនឱ្យមានភាពប្រសើរឡើងតាមសាលារៀនគោលដៅទាំងអស់របស់គម្រោង។

**តពីទំព័រ៦២** តាមសាលារៀនគោលដៅព្រមទាំងសកម្មភាពនម្មិតជាច្រើនទៀតដែលសម្រាប់ជាប្រយោជន៍រួមនិងឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកំណែទម្រង់នៃវិស័យអប់រំប្រកបដោយគុណភាពនាអនាគត ជាពិសេសនៅក្នុងយុទ្ធសាស្ត្របញ្ចកោណនាអាណត្តិថ្មីនេះ"។

លោក ហាតមុត ហ្គីស៊ីកេ ប្រធានមូលនិធិគីនថាន បានមានប្រសាសន៍ថា "**កម្មវិធីកុមារកម្ពុជារីករាយ (HCC) មានលក្ខណៈពិសេសត្រង់ថា កម្មវិធីមិនមានការកំណត់ក្នុងការជួយគាំទ្រទៅលើសកម្មភាពសាលារៀននោះទេ ប៉ុន្តែមានការកំណត់ទៅលើគោលការណ៍របស់អង្គការ។ គោលដៅរបស់អង្គការកុមារកម្ពុជារីករាយ ចង់ឃើញកុមាររៀនចប់បឋមសិក្សាទាំងអស់ អាចអានបាន សរសេរបាន និងអាចគណនាលេខបាន។ វាដូចជាសា**



គម្រោងកុមារកម្ពុជារីករាយបានចាប់ផ្តើមអនុវត្តគម្រោងតាំងពីឆ្នាំ២០១៨រហូតមកដល់ពេលបច្ចុប្បន្ននេះ ដោយទទួលបានការគាំទ្រពីក្រសួង អប់រំយុវជន និងកីឡា អាជ្ញាធរមូល លោកគ្រូអ្នកគ្រូ អាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធ។

**មញ្ញ តែមិនងាយស្រួលក្នុងការសម្រេចនោះទេ ដូចជាប្រទេសរបស់ខ្ញុំក៏មានកុមារមួយភាគបីដែលមិនចេះអានអក្សរ បន្ទាប់ពីចប់កម្រិតបឋមសិក្សា។ ដើម្បីសម្រេចគោលដៅនេះបានត្រូវការការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដូចជាក្រសួង មន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡា អាជ្ញាធរថ្នាក់ខេត្ត-ស្រុក សហគមន៍លោកគ្រូអ្នកគ្រូ ជាពិសេសថ្នាក់ឃុំដែលបានចូលរួមយ៉ាងសកម្មថែមទាំងផ្តល់ថវិកាសម្រាប់ចូលរួមដំណើរការអភិវឌ្ឍសាលារៀន។ លទ្ធផលដែលសម្រេចបាននាបច្ចុប្បន្ននេះ បានសបញ្ជាក់ឱ្យឃើញពីការខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងពីភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសលោកគ្រូអ្នកគ្រូ"៕**

# ការជួបសម្តែងការគួរសមជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាល

លោក ហាតមុត ហ្គីស៊ីកេ ប្រធានមូលនិធិគីនថាន អមដំណើរដោយ លោកស្រី អ៊ុលឡា ហ្គីស៊ីកេ, លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ ខេប, ថ្នាក់ដឹកនាំជាន់ខ្ពស់របស់អង្គការ ខេប និងសមាគមគ្រួសារយើងជាច្រើនរូប បានជួបសម្តែងការគួរសមជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ក្នុងគោលបំណងជម្រាបជូនពីទិសដៅ និងយុទ្ធសាស្ត្ររបស់គម្រោងកុមារកម្ពុជារីករាយនៅសាលាខេត្តរតនគិរី ដើម្បីជួយលើកកម្ពស់ការអប់រំនៅតំបន់ដាច់ស្រយាលកាន់តែល្អប្រសើរ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ។ បច្ចុប្បន្ននេះ គម្រោងកុមារកម្ពុជារីក(HCC)មានសាលារៀនគោលដៅចំនួន ៤១ និងពង្រីកសាលារៀន ចំនួន១៤ បន្ថែម ដែលស្ថិតនៅក្នុងខេត្តចំនួនប្រាំរួមមាន ៖ ត្បូងឃ្មុំ កំពង់ចាម ក្រចេះ សៀមរាប និងរតនគិរី។

គម្រោងកុមារកម្ពុជារីក(HCC) មានលក្ខណៈពិសេសត្រង់ថា ម្ចាស់ជំនួយមិនបានកំណត់រយៈពេលក្នុងការផ្តល់ហិរញ្ញប្បទាននោះឡើយ រាល់សកម្មភាសំខាន់ៗរបស់គម្រោងគឺចង់ឃើញកុមារកម្ពុជាអាចសរសេរបាន អានបាន និងគណនាលេខបានសមរម្យចាប់ពីកម្រិតបឋមសិក្សាឡើងទៅ៕



ម្ចាស់ជំនួយគម្រោងកុមារកម្ពុជារីករាយបានជួបសម្តែងការគួរសមជាមួយឯកឧត្តម ញ៉ែម សំអឿន អភិបាលខេត្តរតនគិរីក្នុងគោលបំណងសំណេះសំណាលពីសកម្មភាពគម្រោង។

# ការជួបសម្ដែងការគួរសមនិងពិភាក្សាការងារអប់រំជាមួយឯកឧត្តម ពុធ សាមិត្ត



គម្រោងកុមារកម្ពុជារីករាយបានចាប់ផ្ដើមអនុវត្តគម្រោងតាំងពីឆ្នាំ២០១៨រហូតមកដល់ពេលបច្ចុប្បន្ននេះ ដោយទទួលបានការគាំទ្រពីក្រសួង អប់រំយុវជន និងកីឡា អាជ្ញាធរមូល លោកគ្រូអ្នកគ្រូ អាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធ។

នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២៣ លោក Hartmut Giesecke ជាស្ថាបនិក និងប្រធានមូលនិធិគីនចាន នៃប្រទេសអាឡឺម៉ង់ បានអញ្ជើញចូលរួមសម្ដែងការគួរសម និងពិភាក្សាការងារអប់រំជាមួយឯកឧត្តម ពុធ សាមិត្ត អនុរដ្ឋលេខាធិការ ជាតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា ក្រោមបរិយាកាសសហការដ៏រីករាយ និងស្និទស្នាល។ នៅក្នុងជំនួបនេះ លោក Hartmut ក៏បានបង្ហាញនូវសេចក្ដីរីករាយ និងគោលបំណងក្នុងការជួយអភិវឌ្ឍវិស័យអប់រំពីកម្រិតមត្តេយ្យដល់បឋមសិក្សាតាមរយៈគម្រោងកុមារកម្ពុជារីករាយ ធ្វើយ៉ាងណាឱ្យកុមារកម្ពុជាចេះគណនាលេខ និងអានអក្សរបានល្អប្រសើរ។ បន្ទាប់ធ្វើទស្សនកិច្ចពិនិត្យ និងសិក្សានៅតាមសាលារៀនគោលដៅក្នុងខេត្តទាំង៥រួចមក លោក Hartmut បានចាប់អារម្មណ៍ច្រើនទៅលើការប្រែប្រួលជាវិជ្ជមានរបស់គ្រូបង្រៀន នាយកឪពុកម្ដាយ អាណាព្យាបាល សហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់នៅមូលដ្ឋាន ដែលបានចូលរួមធ្វើឱ្យកុមារទទួលបានសេវាអប់រំប្រកបដោយគុណភាព រួមទាំងបរិស្ថានសាលារៀន ការបង្រៀន ការគ្រប់គ្រង ជាពិសេសការថែទាំកុមារដោយផ្ដល់អាហារពេលព្រឹក។

គម្រោងកុមារកម្ពុជារីករាយ (HCC) ត្រូវបានសហប្រតិបត្តិដោយអង្គការ ខេប និងសមាគមគ្រួសារយើងនៅក្នុងខេត្តគោលដៅចំនួន៥ (សៀមរាប កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងរតនគិរី) ដែលមានអ្នកទទួលផលចំនួនជាង ១៣ ៤៤០នាក់ ក្រោមជំនួយហិរញ្ញប្បទានរបស់មូលនិធិគីនចាន ចាប់តាំងពីឆ្នាំ២០១៨រហូតដល់បច្ចុប្បន្ន។ គម្រោង HCCមិនមានកាលបរិច្ឆេទបិទបញ្ចប់នេះទេ៕

# គម្រោងFOSTER ទទួលបានប័ណ្ណសរសើរក្នុងកម្មវិធីរំលឹកខួបលើកទី២០




ឯកឧត្តមបណ្ឌិត ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានប្រគល់ប័ណ្ណសរសើរដល់គម្រោង FOSTER។

កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០២៣ តំណាងអង្គការ ខេប តាមរយៈគម្រោងសហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិចតំបន់១ ឬហៅកាត់ថា FOSTER ត្រូវបានអញ្ជើញឱ្យចូលរួមជាកិត្តិយសក្នុងកម្មវិធីរំលឹកខួបលើកទី២០របស់អង្គការ Aide et Action និងទទួលបានប័ណ្ណសរសើរពីឯកឧត្តមបណ្ឌិត ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ នេះឆ្លុះបញ្ចាំងអំពីការទទួលស្គាល់ជាសក្ខីភាពមួយនៃការប្ដេជ្ញាចិត្តរបស់អង្គការ Aide et Action និងអង្គការ ខេប ចំពោះការអប់រំ និងផលជះជាវិជ្ជមាននៅក្នុងសហគមន៍។

អង្គការ Aide et Action បានស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងស្មោះអស់ពីដួងចិត្តចំពោះអ្នកគ្រប់គ្នាដែលបានចូលរួមក្នុងដំណើរនេះ! រួមគ្នា ពួកគេបន្តធ្វើឱ្យមានការផ្លាស់ប្ដូរនៅក្នុងជីវិតរបស់មនុស្សជាច្រើននាក់។ គម្រោង FOSTER កំពុងអនុវត្តន៍សកម្មភាពរបស់ខ្លួននៅក្នុងខេត្តចំនួនបី រួមមាន៖ បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប ដោយមានសាលារៀនគោលដៅទាំងអស់ចំនួន ៤៨ ដែលក្នុងនោះមាន១៦សាលាគឺជាសាលាមត្តេយ្យសិក្សា និងមត្តេយ្យសហគមន៍ ២០សាលា គឺជាសាលាបឋមសិក្សា និង១២សាលាទៀតគឺជាអនុវិទ្យាល័យ។ គម្រោងមានគោលបំណងសំខាន់ ក្នុងការរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងភាពធន់របស់សហគមន៍នេសាទនៅតំបន់បឹងទន្លេសាប៕

# វេទិកាភាពជាដៃគូដើម្បីចីរភាពកម្ពុជា បច្ចុប្បន្ន និងថ្ងៃអនាគត

អង្គការ អេដ អេ អាក់ស្យុង បាន សហការជាមួយអង្គការខេប បានការរៀបចំ វេទិកាស្តីពីភាពជាដៃគូដើម្បីចីរភាពកម្ពុជា នាពេលបច្ចុប្បន្ន និងអនាគត នៅរាជធានីភ្នំពេញ។

វេទិកាភាពជាដៃគូនេះនឹងបង្កើន ទំនាក់ទំនង និងគុណតម្លៃនៃកិច្ចការងាររួមគ្នារបស់អង្គការសង្គមស៊ីវិលជាមួយភាគីរដ្ឋាភិបាល និងវិស័យឯកជន ឱ្យមានឱកាសរួមគ្នាវាយតម្លៃនូវបញ្ហាប្រឈមនៃបរិយាបន្ន និងបង្កើតជាផែនការសកម្មភាពរួមគ្នាមួយ តាមគោលវិធីពហុវិស័យ និងពហុភាគី ដែលរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសដើម្បីធានាថានឹងមិនមាននរណាម្នាក់ត្រូវបានទុកចោល។

វេទិកានេះផ្តោតសំខាន់ទៅលើវត្ថុបំណងដូចខាងក្រោម៖ ១-បង្កើនការយល់ដឹង និងអភិវឌ្ឍន៍បំណិនភាពជាដៃគូ និងសមត្ថភាពរបស់តួអង្គអភិវឌ្ឍន៍នៅតាមមូលដ្ឋានដែលជាលទ្ធផលនឹងនាំឱ្យមានការអភិវឌ្ឍភាពជាដៃគូបានឆាប់រហ័ស បង្កើតនូវផលជះធំទូលាយ និងភាពជាដៃគូកាន់តែមានប្រសិទ្ធភាព។ ២-គាំទ្រដល់ការផ្លាស់ប្តូរក្នុងស្ថាប័ន ដែលទាមទារឱ្យភាគីពាក់ព័ន្ធបង្កើនប្រសិទ្ធភាពនៃវិធីធ្វើការងារដើម្បីផលិតភាពការងារកាន់តែខ្ពស់ តាមរយៈភាពជាដៃគូមួយដែលកាន់តែមានប្រសិទ្ធភាព។ ៣-ចែករំលែកនូវការអនុវត្តល្អៗ បញ្ហាប្រឈម និងបទពិសោធន៍កន្លងមក ក្នុងការគាំទ្រដល់សកម្មភាពនៃការអភិវឌ្ឍន៍ភាពជាដៃគូប្រកបដោយចីរភាព និង៤-បង្កើនអន្តរកម្ម និងទំនាក់ទំនងកាន់តែល្អប្រសើររវាង ភាគីដៃគូអភិវឌ្ឍន៍ និងសហគមន៍។

វេទិការនេះនឹងរួមចំណែកក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងបង្កឱ្យមានបរិយាកាសរស់នៅប្រកបដោយភាពសុខដុមរមនា និងចែករំលែកនូវបទពិសោធន៍ ស្តីពីកិច្ចអន្តរាគមន៍ក្នុងការអភិវឌ្ឍសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាមូលដ្ឋាន តួអង្គសង្គមស៊ីវិល តំណាងវិស័យឯកជន និងអ្នកសហគ្រាសសង្គម ដើម្បីជំរុញនូវនវានុវត្តន៍កំណើនសេដ្ឋកិច្ចជាតិ។

វេទិកានេះនឹងពិភាក្សាអំពីផលជះនៃការវិនិយោគរួមគ្នា ចីរភាពហិរញ្ញវត្ថុសម្រាប់គាំទ្រដល់សហគមន៍ ការចាប់ផ្តើមអាជីវកម្ម និងសហគ្រាសធុនតូច និងមធ្យម ដែលបញ្ជាក់ច្បាស់អំពីសារៈសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ផលចំណេញជាអតិបរមាដែលទទួលបានពីការវិនិយោគតាមរយៈថវិកាហិរញ្ញប្បទាន។ ទន្ទឹមនឹងនោះ វេទិកានេះ នឹងលើកកម្ពស់ដល់គណនេយ្យភាពដែលត្រូវទទួលខុសត្រូវរួមគ្នា ក្នុងចំណោមរដ្ឋបាលមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងការឆ្លើយតបទៅនឹងតម្រូវការ ជីវភាពរស់នៅ ការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់សេវាសាធារណៈនានា។

វេទិកានេះ មានគោលបំណង អភិវឌ្ឍភាពជាដៃគូក្នុងចំណោមប្រព័ន្ធអេកូឡូស៊ី ដែលអាចសម្រួលដល់ការធ្វើអាជីវកម្មជាប្រព័ន្ធ ដែលជាដៃគូមួយនៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាព និងពន្លឿនចំនួន និងប្រសិទ្ធភាពនៃភាពជាដៃគូ ដើម្បីរួមចំណែកសម្រេចបានគោលដៅអភិវឌ្ឍជាតិប្រកបដោយចីរភាពឆ្នាំ២០០៣។

វេទិកានេះ ធ្វើឡើងនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលមានសិក្ខាកាមចូលរួមប្រមាណ ១០០ នាក់ រួមមាន៖ តំណាងដៃគូអភិវឌ្ឍន៍ សម្ព័ន្ធជាតិក្រុមប្រឹក្សាមូលដ្ឋានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរអប់រំ យុវជន និងកីឡា នាយកដ្ឋានពាក់ព័ន្ធ និងរដ្ឋបាលខេត្ត និងស្រុក តំណាងនាយកសាលា គ្រូបង្រៀន សហគមន៍នេសាទ សហគមន៍ព្រៃឈើ សហករណ៍កសិកម្ម សហគមន៍ទេសចរណ៍ សហគ្រាសក្រៅប្រព័ន្ធ និងយុវជន ដើម្បីចែករំលែកពីភាពជាដៃគូក្នុងការលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានអាជ្ញាធរមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ/សង្កាត់ មានតួនាទីជាមន្ត្រីរាជរដ្ឋាភិបាលធ្វើសកម្មភាពបម្រើសេវាដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ដែលជាម្ចាស់សិទ្ធ៕




*វេទិកាភាពជាដៃគូដើម្បីចីរភាពកម្ពុជា បច្ចុប្បន្ន និងថ្ងៃអនាគត រៀបចំឡើងដើម្បីបង្កើនទំនាក់ទំនង និងគុណតម្លៃនៃកិច្ចការងាររួមគ្នារបស់អង្គការសង្គមស៊ីវិលជាមួយភាគីរដ្ឋាភិបាល និងវិស័យឯកជន។*